01071702 E1/267.1

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Mar-2015, 14:14
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៤៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា រ៉ូប៊ីន្នី ក្រហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក សេង លាង

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de Wilde d'Estmael)*

លោក ឌេល លីសាក់*(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ស្នួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក មឿន សុវណ្ណ | ខ្មែរ |
| លោក ស្រី ថន ហៅ ឌុច (2-TCW-944) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក ស្រី ថន ហៅ ឌុច** (2-TCW-944)

សួរបន្តដោយលោក ឌែល លីសាក់ ផ្តើមពី ....................................................ទំព័រ ៣

សួរដោយលោក ឡៅ ជុនធី ផ្តើមពី....................................................ទំព័រ ៣១

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី....................................................ទំព័រ ៤១

សួរដោយលោក វិុចទ័រ កូប៉េ ផ្តើមពី....................................................ទំព័រ ៥០

សួរដោយលោក សួន វិសាល ផ្តើមពី....................................................ទំព័រ៧៣

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-944 ជាបន្ត។

អ្នកក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ហើយលោក គង់ សំអុន មេធាវីជាតិការពារឲ្យលោក ខៀវ សំផន នឹងមកយឺតបន្តិចនៅពេលព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅ -- ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ត គឺសាក្សីដែលមានរហស្សនាម TCW-944 លោកមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ។ ហើយមេធាវីប្រឹក្សារបស់លោកនៅពេលព្រឹក គឺលោកមេធាវី មឿន សុវណ្ណ ហើយលោកមេធាវី ឌុច ផារី នឹងមានវត្តមាននៅពេលរសៀល។

សាក្សីបម្រុងនៅថ្ងៃនេះមានរហស្សនាម 2-TCW-852 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនេះនឹងធ្វើសម្បថនៅចំពោះលោកតាដំបងដែកនៅវេលាម៉ោងដប់ព្រឹក មុនពេលមកផ្ដល់សក្ខីកម្ម។ សាក្សីរូបនេះ នឹងមានមេធាវីប្រឹក្សា គឺលោកមេធាវី មឿន សុវណ្ណ ផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ហើយជាបឋមនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំ

របស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់គាត់បានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៦:៣៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះខ្លាំង វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនេះនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៧:៤៨]

ហើយជាបន្តនេះ អង្គជំនុំជម្រះសូមបញ្ជាក់លើលោកមេធាវី មឿន សុវណ្ណ។ លោកមេធាវី មឿន សុវណ្ណ លោកជាទី -- មេធាវីប្រឹក្សាសាក្សីដែលអង្គជំនុំជម្រះបានរៀបចំដើម្បីផ្តល់ជូនទៅសាក្សីតាមសំណើសុំរបស់គាត់នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនេះ។

លោក មឿន សុវណ្ណ លោកអាចប្រាប់ អំពីអាសយដ្ឋាន និងអត្តលេខ -- អាសយដ្ឋានការិយាល័យមេធាវីរបស់លោក ហើយនិងអត្តលេខរបស់លោកដែលនៅក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដល់អង្គជំនុំជម្រះបានដែរឬទេ?

**លោក មឿន សុវណ្ណ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទឈ្មោះ មេធាវី មឿន សុវណ្ណ អត្តលេខ៥៦១ មានការិយាល័យនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ ការិយាល័យមេធាវីរបស់ខ្ញុំឈ្មោះ សម្ព័ន្ធអ្នកច្បាប់ -- ក្រុមមេធាវីសម្ព័ន្ធអ្នកច្បាប់ដើម្បីយុត្តិធម៌។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយអង្គជំនុំជម្រះសូមជម្រាបរំឭកដល់សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយព្រឹកនេះ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:០៩:២៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។

**ស៖** ជម្រាបសួរលោកសាក្សី ពីម្សិលមិញយើងបញ្ចប់ត្រឹមការសួរចម្លើយនៅក្រាំងតាចាន់។ នៅក្នុងកិច្ចសម្ភាសន៍លើកទី១ ជាមួយសហចៅក្រមស៊ើបអង្កេតដែលមានបង្ហាញផែនទីពាក់ព័ន្ធទៅនឹងបរិវេណនៃក្រាំងតាចាន់ ឯកសារ D125/129។ សូមលោកពិនិត្យមើលទំព័រចុងក្រោយនៃឯកសារ D125/129 និយាយអំពីគំនូសបង្ហាញគុកក្រាំងតាចាន់។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។

លោកសាក្សី គឺផែនទីរបស់សហចៅក្រមស៊ើបអង្កេតដែលខ្ញុំបង្ហាញពីសប្តាហ៍មុន គឺថាលោកបានគូសគឺនៅខាងលើ -- ប្រអប់ខាងលើ។ តើវាជួយបង្ហាញដល់ការចងចាំរបស់លោកថានេះគឺជាទីតាំងសួរចម្លើយ កន្លែងសួរចម្លើយនៅ១ទិសខាងត្បូងនៃភាគខាងត្បូងនៃគុកក្រាំងតាចាន់ដែរឬទេ?

[០៩:១១:២៩]

**លោក ស្រី ថន៖**

**ធ៖** បាទ ទីតាំងកន្លែងសួរចម្លើយគឺពិតជានៅត្រង់ហ្នឹងមែន។

**ស៖** ហើយផែនទីដែលលោកគូសនេះក៏បង្ហាញពីអគារពីរ និយាយអំពីអគារដាក់អ្នកទោសគឺមួយនៅខាងកើត និងមួយនៅទិសខាងលិច។ ហើយខ្ញុំមានបញ្ហាអក្សរដៃរបស់លោកបន្តិចដោយសារលោកសរសេរពីចម្ងាយរវាងចន្លោះពីបន្ទប់សួរចម្លើយ និងអគារដាក់អ្នកទោស។ គឺអ៊ីចឹងសូមលោកជួយបញ្ជាក់អំពីអក្សរដៃរបស់លោកៗសរសេរថាម៉េច ពាក់ព័ន្ធទៅនឹងអគារដាក់អ្នកទោសនៅទិសខាងកើត និងអគារមួយទៀតនៅទិសខាងលិច?

**ធ៖** ចម្ងាយ ទាក់ទងនឹងចម្ងាយពីអគារមួយទៅអគារមួយ ចម្ងាយប្រហែលជា៤0ម៉ែត្រ រំលងគ្នា ចន្លោះកណ្ដាលគឺប្រវែងប្រហែល៤0ម៉ែត្រ។

**ស៖** នៅចំកណ្ដាលផែនទីមានអគារដែលលោកសរសេរថាជាផ្ទះបាយ។ ហើយនៅខាងក្រោមមកខាងជើង គឺអគារមួយទៀត គឺឃើញថាអគារនេះលោកចែកទៅជាពីរបន្ទប់។ តើអគារមួយនេះ នៅខាងជើងចង្ក្រានបាយហ្នឹង សូមលោករៀបរាប់អំពីអគារហ្នឹង ដែលគូសទៅ លោកគូសទៅឃើញមានពីរបន្ទប់ហ្នឹង?

[០៩:១៣:១៩]

**ធ៖** កន្លែងអគារពីបន្ទប់នេះ គឺអគាររបស់ប្រធានគុក។ ប៉ុន្តែអគារនេះមិនមែនអគារធំទេ គឺទទឹងប្រហែលជា ៤ម៉ែត្រ និង ៣ម៉ែត្រតែប៉ុណ្ណោះ ប៉ុន្តែគេចែកខណ្ឌកណ្ដាលហ្នឹងមានបន្ទប់គេមួយ។

**ស៖** តើអគារនេះជាអគារដែលលោកធ្វើការនៅទីនោះឬអត់ នៅពេលដែលលោកធ្វើការជាអ្នកវាយអង្គុលីលេខឲ្យប្រធានគុកនោះ?

**ធ៖** ពេលដែលវាយអង្គុលីលេខ គឺអង្គុលីលេខនៅកន្លែងបន្ទប់របស់ប្រធានហ្នឹង។

**ស៖** តើបន្ទប់របស់ប្រធានគុកមានចម្ងាយប្រវែងប៉ុន្មានពីបន្ទប់សួរចម្លើយ?

**ធ៖** បន្ទប់របស់ប្រធានមានចម្ងាយប្រហែលជា ៧0ម៉ែត្រ ឬក៏លើសពីនេះ។

**ស៖** កាលពីសប្ដាហ៍មុន ខ្ញុំបានអានចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា លោកបានឃើញគេយកអ្នកទោសទៅវាយសួរចម្លើយរាល់ថ្ងៃ។ ហើយលោកបានឮអ្នកទោសស្រែកចេញពី ឮចេញពីបន្ទប់សួរចម្លើយ។ តើលោកអាចស្ដាប់ឮសូរអ្នកទោសស្រែកចេញមកពីបន្ទប់សួរចម្លើយ មកដល់បន្ទប់លោកវាយអង្គុលីលេខទេ? ឬក៏ឮជុំវិញបរិវេណនៃគុកហ្នឹង អាចស្ដាប់ឮទេ?

**ឆ៖** បាទ ឮសូរ តែនៅខាងក្នុងដែលកន្លែងវាយអង្គុលីលេខបានឮ។ បើសិនជាចេញមកក្រៅរបង នៅកន្លែងរោងយាមខាងក្រៅ គឺស្តាប់អត់ឮទេ។

**ស៖** ទាក់ទងទៅនឹងអគារប្រើប្រាស់សម្រាប់សួរចម្លើយអ្នកទោស សូមលោកជម្រាបជូនអង្គជំនុំជម្រះថាតើអគារនេះមានជញ្ជាំងទេ ឬគ្រាន់តែជាអគារមួយដែលៗចំហមិនមានជញ្ជាំងមិនមានអីទេ?

**ឆ៖** បាទរោងនេះ បើសិនជាយើងនិយាយសាមញ្ញទៅ មិនមែនជាអគារអីធំដុំទេ គឺរោងជញ្ជាំងព័ទ្ធជុំវិញ ប៉ុន្តែជញ្ជាំងវាយក្តារ ដំបូលប្រកស្លឹកទេ ប៉ុន្តែជិតវាយជិត យើងអាចមើលអត់ឃើញទេ។

[០៩:១៦:៥៥]

**ស៖** ខ្ញុំសូមបញ្ជាក់។ តើលោកនិយាយអំពីបន្ទប់សួរចម្លើយ ឬក៏លោកនិយាយអំពីបន្ទប់ដែលមានប្រធានគុកធ្វើការនៅទីហ្នឹង ហើយកន្លែងដែលលោកវាយអង្គុលីលេខ?

**ឆ៖** បាទបន្ទប់ គឺបន្ទប់សួរចម្លើយ។

**ស៖** ខ្ញុំចង់អានចម្លើយដែលលោកបានឆ្លើយរួចហើយនៅក្នុងសវនាការ អំពីបន្ទប់សួរចម្លើយ។ នៅក្នុងប្រតិចារឹកចារឹកថ្ងៃ០៤ កុម្ភៈ ឆ្នាំ២០១៥ គឺ E1/256.1 ដែលដើម -- គឺដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានឆ្លើយដូចតទៅ សូមដកស្រង់៖ "សំណួរ៖ តើបន្ទប់សួរចម្លើយមានជញ្ជាំងថ្មឬក៏អត់? បើអត់ទេ តើជញ្ជាំងនោះធ្វើអំពីអ្វី? ចម្លើយ៖ ជញ្ជាំងខាងមុខធ្វើពីឈើៗ ពីៗក្តារ ហើយសម្រាប់ជញ្ជាំងដទៃទៀត គឺគេប្រើធាងដូងស្លឹកដូង"។ ហើយនៅថ្ងៃបន្តបន្ទាប់មកទៀត នៅឯកសារ E1/256.1 នេះ -- គឺ257.1 នៅម៉ោង១០:៥៥:២០វិនាទី, "តើលោកអាចមើលឃើញតាមជញ្ជាំងស្លឹកដូង ឬក៏ក្តារហ្នឹងបានទេ?" យើង -- "ឆ្លើយ៖ យើងអាចឃើញដោយសារជញ្ជាំងបន្ទប់សួរចម្លើយខាងមុខ គឺថាទាប ជញ្ជាំងនោះទាប។ ហើយដូចខ្ញុំនិយាយថាមានជញ្ជាំងនៅ -- គេនៅខាងក្រោយមានគេមានព្យួររបស់របរផ្សេងៗ សម្ភារៈផ្សេងៗ"។ តើនេះជួយបញ្ជាក់ដល់ការចងចាំរបស់លោកថា ជញ្ជាំងខាងមុខនេះបន្ទប់សួរចម្លើយ គឺថាគេអាចមើលឃើញនិងស្តាប់ឮនូវសកម្មភាពផ្សេងៗ ដោយសារវាមិនមែនជាជញ្ជាំងដែលបិទជិតនោះទេ។

**ឆ៖** បាទ ពិតប្រាកដមែន ប៉ុន្តែក្នុងរង្វង់មន្ទីរស្សូរ ដែលបន្ទប់សួរចម្លើយហ្នឹង គឺមានដំណាំពេញទាំងអស់ ជិតមើលអត់ឃើញទេ។ ដំណាំមានដើមចេក ដើមដំឡូង គឺគេដាំដំណាំក្នុងហ្នឹង។ អ៊ីចឹងនៅក្នុងហ្នឹង ដូចជាតំបន់មួយព្រៃអ៊ីចឹង វាមិនអាចមើលឃើញទេ។

[០៩:១៩:៥៨]

**ស៖** ខ្ញុំក៏សូមសួរលោកអំពីចម្លើយដែលឆ្លើយដោយ ស៊ីម លោកថាគឺជាអ្នកដែលនៅកង៦ ជាមួយលោក។ ឯកសារ ក.ស.ច.ស D40/20, ERN ជាភាសាខ្មែរ 00165334, ERN ជាភាសាអង់គ្លេស 00433573 និង ERN ជាភាសាបារាំង 00524322។ នេះគឺអ្វីដែលអ្នកយាមគុកបានឆ្លើយ។ សូមដកស្រង់៖ "តាមអ្វីដែលខ្ញុំអាចលួចមើលនៅពេលដាំស្លនៅជិតនោះ ខ្ញុំបានឃើញពួកគេវាយដំអ្នកទោសសួរចម្លើយ ហើយឆែកឆេរ ហើយជួនកាលគេគ្របថង់ផ្លាស្ទិកលើក្បាលអ្នកទោស។ អ្នកទោសខ្លះត្រូវបានគេវាយដំរហូតដល់បាត់បង់ជីវិត ដល់ស្លាប់"។ បញ្ចប់ការដកស្រង់។ ទី១ តើនេះជួយរំឭកដល់ការចងចាំរបស់លោកថា មានទីតាំងមួយនៅជិតបន្ទប់សួរចម្លើយ ដែលថាយ៉ាងហោចណាស់ក៏អ្នកយាមម្នាក់នៅក្នុងកងរបស់លោក ក្រុមរបស់លោកហ្នឹង គឺពេលខ្លះអ្នកយាមហ្នឹងគឺគាត់ដាំស្ល។ ជួយរំឭកដល់ការចងចាំលោកទេ?

**ឆ៖** បាទ មានខ្លះអ្នកយាមជាមួយខ្ញុំក៏មានដាំស្លដែរ។ ប៉ុន្តែពេលដែលគេសួរចម្លើយ គឺគេមិនឱ្យយើងដើរជិត ហើយក៏យើងមិនអាចដឹងរឿង។ សូម្បីតែសំឡេងអ្នកទោសក៏អត់ បើឮៗតែស្រែកតែមាត់ស្រែកទេ ដែលខ្លាំង បើថាសួរចម្លើយគឺអត់ឮ ស្តាប់ពីក្រៅទៅគឺអត់ឮ។

**ស៖** តើមានថង់ផ្លាស្ទិកដែលត្រូវបានគេរក្សាទុក និងប្រើប្រាស់នៅបន្ទប់សួរចម្លើយទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើមានអាវុធ ឧបករណ៍ផ្សេងៗ ដូចជាដំបង ឬក៏រំពាត់អីគេរក្សាទុកនៅបន្ទប់សួរចម្លើយទេ?

[០៩:២២:៣៨]

**ឆ៖** បាទ ខ្ញុំអត់ដែលចូលទៅជិតកន្លែងបន្ទប់ហ្នឹងទេ។

**ស៖** កាលពីសប្តាហ៍មុន លោកបានជម្រាបជូនអង្គជំនុំជម្រះថាពេលខ្លះ គឺសមាជិកក្រុម៦ បែងចែកទៅជាពីរក្រុមដែលមួយក្រុមមានបីនាក់ ម្នាក់មួយយាមនៅអគារខាងកើត ម្នាក់ទៀតគឺយាមនៅអគារខាងលិច អគារអ្នកទោសខាងលិច។ នៅពេលដែលគេឱ្យលោកទៅយាមកាមនៅអ្នកទោស តើអ្នកយាមណាម្នាក់នៅក្រុមរបស់លោកជួយនាំអ្នកទោសយកចេញពីបន្ទប់ឃុំឃាំងទៅកាន់បន្ទប់សួរចម្លើយ ដើម្បីឱ្យគេសួរចម្លើយដែរទេ?

**ឆ៖** បាទ អត់មានទេ។ ពួកអ្នកយាមគឺគ្រាន់តែយាមការពារខាងក្រៅទេ មិនមែនយាមសម្រាប់បើកទ្វារគុកអត់ៗមានទេ។ អ៊ីចឹងក្រុមខ្ញុំទាំងប្រាំមួយនាក់នេះគឺយាមការពាររបងខាងក្រៅ។ ពេលយប់

បានគេឱ្យចូលមកយាមនៅក្បែរមាត់ទ្វារគុក ពេលថ្ងៃគឺគេឱ្យចេញទៅយាមនៅក្បែររបងខាងក្រៅ គឺមួយក្រុមបីនាក់ ហើយនិងព័ទ្ធបរិវេណជុំវិញរបងតែម្ដង។

**ស៖** នៅពេលដែលលោកឆ្លើយពីសប្ដាហ៍មុនថា គ្នារបស់លោកបីនាក់យាមនៅអគារខាងកើត និងបីនាក់ទៀតយាមនៅអគារខាងលិច។ នៅពេលដែលគេចាត់ឱ្យលោកយាមអ្នកទោសហ្នឹង តើគេឱ្យលោកយាមនៅអគារមួយណា ទិសខាងណា?

**ឆ៖** បាទ ខ្ញុំយាមនៅអគារខាងកើត។

[០៩:២៤:៥១]

**ស៖** ក្នុងអំឡុងពេលដែលយាម លោកយាមនៅអគារខាងកើតហ្នឹងគឺទីតាំងពិតប្រាកដនោះ គឺយាមនៅកន្លែងណានៃអគារ?

**ឆ៖** បាទ ទីតាំងរោងអ្នកយាមគឺនៅរោងខាងកើតអគារ ចម្ងាយប្រហែលជា ២០ម៉ែត្រ ប៉ុន្តែពេលដែលយើងយាមគឺ យើងមកអង្គុយជិតនៅអគារគុកហ្នឹងតែម្ដង។

**ស៖** ហើយនៅក្នុងអំឡុងពេលនោះ នៅពេលលោកនៅជិតនឹងអគារឃុំឃាំង តើមានពេលណាមួយដែលគេឱ្យលោកនាំអ្នកទោសចេញពីអគារឃុំឃាំងទៅបន្ទប់សួរចម្លើយ រួចហើយនាំពីបន្ទប់សួរចម្លើយមកដាក់អគារឃុំឃាំងវិញដែរទេ?

**ឆ៖** បាទ នេះចម្លើយនេះ ខ្ញុំសូមបញ្ជាក់ប្រាប់អស់លោកថា កងការពាររបស់ខ្ញុំ ប្រាំមួយនាក់នេះមិនមែននៅក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវនៅក្នុងគុកហ្នឹងទេ។ គេឱ្យយាមតែខាងវាល អ៊ីចឹងខាងក្នុងដែលការងារគេសួរចម្លើយ គឺគេយកអ្នកទោសចេញទៅនេះទៅនោះនៅក្នុងហ្នឹងគឺយើងអត់បានដឹងទេ។

**ស៖** លោកសាក្សី ខ្ញុំសុំអានសម្រង់មួយទៀតចេញពីសៀវភៅរបស់ អ៊ា ម៉េងទ្រី គឺ E3/2120 មាន -- គឺនៅត្រង់ ERN 00416393 ដូចជាខ្ញុំបានជម្រាបលើកមុនហើយ គឺថាគឺលោកបានឆ្លើយដោយរៀបរាប់អំពី ក្នុងនោះថាលោកមានតួនាទីជាអ្នកវាយអង្គុលីលេខឈ្មោះ សុខ ចាន់ថា ហៅ ឌុច ហើយសៀវភៅរបស់គាត់សរសេរដូចតទៅ សុំដកស្រង់៖ "ចាន់ថា ត្រូវបានគេឱ្យធ្វើការនៃបន្ទប់សួរចម្លើយ ដូច្នេះជាញឹកញាប់គាត់ឮសួរសម្រែកអ្នកទោស។ គាត់បានពន្យល់ថា ការវាយ ការធ្វើទារុណកម្មកើតមានឡើងនៅពេលណាអ្នកទោសមិនបានឆ្លើយទៅតាមសំណួរដែលគេសួរ ហើយពេលខ្លះគឺ គេវាយដំរហូតដល់អ្នកទោសហ្នឹងហូរឈាមពីក្បាលដល់ចុងជើងសន្លប់បាត់ស្មារតី ហើយពេលខ្លះគឺថា

ស្លាប់តែម្តង"។ បញ្ចប់ការដកស្រង់។ តើលោកសាក្សី តើក្រោយពីការវាយដំសួរចម្លើយ លោកឃើញថា អ្នកទោសហ្នឹង ហាក់ដូចជា ទំនងដូចជាគេបានវាយដំដែរទេ?

**ឆ៖** បាទ ត្រង់សំណួរដែលលោកសួរខ្ញុំថា ឈ្មោះ ចាន់ថា ហៅ ឌុច ហ្នឹង គឺខ្ញុំអត់ដែលស្គាល់ទេ។ ខ្ញុំអត់ដែលស្គាល់ទេ។

[០៩:២៨:៣៤]

**ស៖** តើលោកធ្លាប់ដែលឃើញអ្នកទោសដែលមើលទៅត្រូវបានគេធ្វើទារុណកម្ម គេវាយដំដែរទេ?

**ឆ៖** បាទ មាន អ្នកទោសដែលគេ ត្រូវគេវាយដំគឺ ប៉ុន្តែវាមិនមែនបានខ្ញុំឃើញរាល់ថ្ងៃទេ។ ពេលដែលខ្ញុំចូលទៅឃើញ។ មានអ្នកទោសហ្នឹងគេធ្វើទារុណកម្មប្រហែលជាគេធ្វើទារុណកម្មខ្លាំងក្លាមែនទែន ប៉ុន្តែមិនដឹងជាធ្វើតាមវិធីណា វ៉ៃតាមរបៀបម៉េច សួរចម្លើយរបៀបម៉េច ខ្ញុំអត់បានដឹងទេ។

**ស៖** តើក្នុងស្ថានភាពនេះ លោកឃើញអ្នកទោសហ្នឹង នៅត្រង់កន្លែងណា?

**ឆ៖** អ្នកទោសឃើញ ក្រោយពេលដែលគេសួរហើយគឺ បញ្ជូនយកមកដាក់ក្នុងគុកវិញ។

**ស៖** សុំលោកជម្រាបជូនអង្គជំនុំជម្រះផង បើតាមលោកដឹងថា តើអ្នកណាជាអ្នកសួរចម្លើយអ្នកទោសនៅគុកក្រាំងតាចាន់ នៅពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** បាទ ខ្ញុំចាំមិនច្បាស់ទេ។ កាលនោះ ព្រោះខ្ញុំគ្មានតួនាទីអីនៅក្រោមការគ្រប់គ្រងរបស់មន្ទីរក្រាំងតាចាន់ទេ។ មន្ទីរក្រាំងតាចាន់គឺមានប្រធាន ឈ្មោះ ឡេង អាន់ និងអនុប្រធានឈ្មោះ ឌុច។ ហើយខ្ញុំក្រោមការគ្រប់គ្រងរបស់កងទ័ព។ គេបញ្ជូនខ្ញុំទៅកងការពារ មិនមែនទៅឲ្យ -- មិនមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរក្រាំងតាចាន់ទេ។

**ស៖** លោកសាក្សី នៅពេលដែលលោកធ្វើការនៅក្នុងបន្ទប់របស់ប្រធានវាយអង្គុលីលេខ តើលោកស្ថិតនៅក្រោមគ្រប់គ្រងរបស់គាត់ឬក៏អត់ទេ នៅពេលនោះ?

**ឆ៖** បាទ អត់ទេ។ ពេលដែលវ៉ៃ គេដាក់ក្រដាស គេសរសេរហើយគេដាក់នៅលើតុហ្នឹង ហើយគេប្រើមនុស្សម្នាក់ឲ្យទៅហៅខ្ញុំមក មកចូលវ៉ៃឲ្យគេហើយ។ គឺវ៉ៃហើយ ខ្ញុំទុកលើហ្នឹងវិញ ខ្ញុំដើរចេញទៅវិញ។

[០៩:៣១:៣៩]

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីការវាយឯកសារ ប៉ុន្តែនៅពេលដែលលោកធ្វើការនៅ

ក្រាំងតាចាន់ តើអ្នកទោសនៅគុកក្រាំងតាចាន់ មានអ្នកទោសស្រីម្នាក់ឈ្មោះ យាយណា -- ឈ្មោះ យាយញ៉ ហើយនិងក្មេងតូចៗខ្លះទេ?

**ឆ៖** បាទ ពេលដែលខ្ញុំចូលទៅដល់ក្រោយនេះ គឺឃើញមានឈ្មោះហ្នឹងនៅក្នុងគុកហ្នឹងរួចស្រេចទៅហើយ ហើយខ្ញុំក៏មិនដឹងជាគាត់មកជាប់ពីពេលណាមកដែរ។

**ស៖** តាមដែលខ្ញុំយល់ គឺលោកនិយាយថា លោកចាំអ្នកទោសស្រីម្នាក់ឈ្មោះ យាយញ៉ និងក្មេងតូចៗ កូនតូចៗ ជាប់នៅគុកក្រាំងតាចាន់រួចទៅហើយ នៅពេលដែលលោកទៅដល់ឃើញនៅទីហ្នឹងទៅហើយ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ប្រាកដមែន។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទ ស្តីពីការរៀបរាយការណ៍ឯកសារដែលបានរៀបចំនៅគុកក្រាំងតាចាន់ ហើយនៅក្នុងចម្លើយរបស់លោក គឺឯកសារ D2232/93 នៅត្រង់ចម្លើយលេខ១០ លោកបានឆ្លើយថាលោកត្រូវបានគេឱ្យវាយអង្គុលីលេខ។ "ខ្ញុំធ្លាប់ទៅវាយឯកសារស្តីពីរបាយការណ៍អ្នកទោស ហើយគេឱ្យខ្ញុំវាយហ្នឹង វាយចេញពីសៀវភៅសរសេរដោយដៃ"។ តើអ្នកណាមកឱ្យសៀវភៅកំណត់ត្រាសរសេរដោយដៃហ្នឹង មកឱ្យលោកវាយអង្គុយលីលេខ? គឺនៅត្រង់ចម្លើយ៥៩។

[០៩:៣៤:០១]

**ឆ៖** បាទ ចម្លើយដែលគេសរសេរហើយ នៅសៀវភៅដៃ គឺនៅពេលដែលគេសួរចម្លើយហើយគេសរសេរនៅក្នុងសៀវភៅ។ ក្រោយមក គេយកចម្លើយហ្នឹងយកមកដាក់នៅលើតុហ្នឹង ឱ្យខ្ញុំចម្លងចម្លើយហ្នឹងទៅដាក់ក្នុង វាយអង្គុលីលេខ។

**ស៖** អ្នកណាឱ្យលោកវាយចម្លងអក្សរហ្នឹង វាយអង្គុលីលេខនោះ?

**ឆ៖** បាទ ជួនកាល បើសិនជា តាអាន់ អត់នៅ គឺគេឱ្យ ឌុច។ បើសិនជា ឌុច ហ្នឹង អត់នៅក៏គេប្រើឱ្យខ្ញុំមកវៃជំនួស។

**ស៖** សុំអានចម្លើយរបស់លោក គឺ E319.1.25 ត្រង់ចម្លើយលេខ៣៤ សំណួរសួរថា "តើអ្នកណាជាអ្នកឱ្យលោកវាយ? ឆ្លើយ៖ ឡេង អាន់ និង ឌុច បានឱ្យខ្ញុំវាយឯកសារ ហើយពេលដែលខ្ញុំវាយរួចហើយ ខ្ញុំចាកចេញទៅវិញ"។ បញ្ចប់ការដកស្រង់។ តើចំណុចនេះវា ជួយរំឭកដល់ការចងចាំរបស់លោកដែរថា ឌុច ឬក៏មេគុក អាន់ ឬក៏អនុប្រធានឈ្មោះ ឌុច ជាអ្នកឱ្យលោកវាយអង្គុលីលេខនេះ?

**ឆ៖** បាទ ទាំងពីរនាក់នេះ គេអាចហៅខ្ញុំមកប្រើបាន ព្រោះខ្ញុំចេះវាយអង្គុលីលេខ មិនមែនចេះ

ជ្រៅជ្រះទេ គ្រាន់តែចេះបានបន្តិចបន្តួចគ្រាន់តែជំនួសដៃគេខ្លះ។

**ស៖** ខ្ញុំដឹងថា លោកថា លោកមិនមែនជាឈ្មោះ សុខ ចាន់ថា ដែល អ៊ា ម៉េងទ្រី បានសួរចម្លើយហើយដែលបានឆ្លើយថា គឺជាអ្នកវាយអង្គុលីលេខនៅក្រាំងតាចាន់។ ឯកសារលេខ E3/2120 ហើយមាន ERN ដែលជាភាសាអង់គ្លេស គាត់បានឆ្លើយថា គាត់បានទទួលចម្លើយពីអ្នកវាយអង្គុលីលេខ អំពីការរៀបចំចម្លើយសារភាពរបស់អ្នកទោស។ សុំដកស្រង់៖ "មន្ទីរសន្តិសុខក្រាំងតាចាន់មានដំណើរការសួរចម្លើយពីររបៀប៖ ទី១ អាន់ សួរចម្លើយ ហើយ ឆេន ជាអ្នកកត់ត្រា។ ឆេន កត់ត្រាចូលក្នុងសៀវភៅ ហើយពេលខ្លះកម្មាភិបាលគុកហ្នឹង ប្រើខ្សែអាត់ថតសំឡេងក្រោយមក អាន់ បានឲ្យឯកសារទៅឲ្យ ឆេន។ ហើយ ឆេន យកទៅឲ្យ ចាន់ថា វាយអង្គុលីលេខ។ ហើយ ចាន់ថា និយាយថា "ឆេន បានឲ្យខ្ញុំវាយ ហើយបានផ្ញើជូនទៅអង្គការថ្នាក់លើ"។ បញ្ចប់ការដកស្រង់។ សំណួរដំបូងរបស់ខ្ញុំសួរថាតើលោកចាំកម្មាភិបាលម្នាក់ឈ្មោះ ឆេន ដែលជាមនុស្សម្នាក់ក្នុងចំណោមថ្នាក់ដឹកនាំនៅគុកក្រាំងតាចាន់នោះដែរឬទេ?

[០៩:៣៨:០២]

**ឆ៖** បាទ ខ្ញុំសូមជម្រាបអង្គសវនាការថា ឈ្មោះ ឆេន – ទី១ឈ្មោះ ឆេន, ទី២ ឈ្មោះ ដាំ គឺទាំងពីរនាក់នេះគឺគេនៅក្នុងគុកហ្នឹងយូរហើយ ខ្ញុំចូលទៅគឺអត់មានឃើញទេ។ ឃើញតែឈ្មោះ ដាំ ហ្នឹងមួយដែលនៅជាប់គុក។ ហើយឈ្មោះ ឆេនៗ ហ្នឹងដែលគេថាប្រធានហ្នឹង ក៏ខ្ញុំទៅអត់ទាន់ដែរ។ ខ្ញុំចូលទៅគឺអត់ទាន់ទេ មិនដឹងជាគេចេញទៅ ឬក៏គេឡើងទៅណាទៀតក៏ខ្ញុំអត់ដឹងដែរ។ ពេលដែលខ្ញុំចូលទៅដល់នេះ គឺមានតែឈ្មោះ ដាំ មួយទេ ដែលជាប់គុកវិញ។ ប្រធានគុកហ្នឹងហើយ ហើយជាប់គុកក្នុងគុកហ្នឹងវិញ។ ហើយខ្ញុំអត់ស្គាល់ទេ អ្នកទាំងអស់នោះ មិនដែលឃើញមុខផង។ ហើយមិនដឹងគេធ្វើការពីឆ្នាំណាមកផង អត់ដឹង។

**ស៖** តើនៅក្នុងពេលដែលលោកធ្វើការនៅក្រាំងតាចាន់ មានពេលខ្លះ តើលោកនៅទីនោះ ឬក៏អត់លោក ឆេន ហ្នឹង ពេលដែលលោកទៅដល់ហ្នឹង ឬក៏បាត់អត់ឃើញគាត់នៅទីនោះ?

**ឆ៖** បាទ អត់មានទេ អត់មានឈ្មោះទេ។ ពេលខ្ញុំចូលទៅដល់ហ្នឹង គឺអត់មានទេ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក ដែល D232 -- អ៊ំ! 2232/93 ត្រង់ចម្លើយលេខ៤០ លោក ឆ្លើយដូចតទៅអំពីសៀវភៅកត់ត្រាដែលបានផ្តល់ឲ្យលោកវាយអង្គុលីលេខ។ សូមដកស្រង់៖ "ខ្ញុំបានទទួលបញ្ជីឈ្មោះដែលសរសេរដោយដៃពីប្រធាន។ ក្រដាសបញ្ជីនោះ គេសរសេរនៅលើសៀវភៅ

ដែលមានចំណងជើងថា “សៀវភៅសរសេរ” និងមានដាក់ថាជាមេគុណនៅលើក្របទាំងនោះ”។ ក្នុងចម្លើយ៣២ ដល់៣៣ នៅក្នុងចម្លើយតែមួយនេះ សូមដកស្រង់៖ “សំណួរ៖ បញ្ជីឈ្មោះដែលប្រធានឲ្យលោកវាយ តើជាក្រដាស ឬជាសៀវភៅ? ឆ្លើយ៖ ជាសៀវភៅដែលមានកម្រាស់ប្រហែល១០ ឬ២០សន្លឹក គឺជាសៀវភៅសរសេរសម្រាប់ក្មេងៗរៀន។ សួរ៖ នៅលើក្របសៀវភៅ តើមានអ្វីសម្គាល់ផ្សេងទៀតទេ? ឆ្លើយ៖ នៅលើក្របសៀវភៅមិនមានសរសេរអ្វីទៀតទេ ក្រៅពីរូបភាពដូចជា រូបកុមារ រូបអង្គរវត្តជាដើម”។ បញ្ចប់ការដកស្រង់។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3/4092 ជូនទៅដល់សាក្សី ដើម្បីចង់ដឹងថាតើគាត់នៅចងចាំ ឬក៏ចាំ ឬក៏អត់ ហើយក៏សុំបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រផងលោកប្រធាន។

[០៩:៤១:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ដំបូងខ្ញុំចង់ឲ្យលោកមើលក្របសៀវភៅឯកសារ E3/4092 ដែលក្របសៀវភៅហ្នឹងមានរូបកុមារៗកំពុងសរសេរ ហើយនិងមានតារាងមេគុណ។ តើនេះគឺជាសៀវភៅដែលគេឲ្យលោកយកទៅវាយចម្លងជាអង្គុលីលេខនៅក្រាំងតាចាន់ ឬក៏អត់ទេ?

**លោក ស្រី ថន៖**

**ថ៖** បាទ មិនមែនទេ។ សៀវភៅនេះ ខ្ញុំធ្លាប់ឃើញ គេកត់ឈ្មោះអ្នកទោសទេ។ មិនមែនក្រដាសគេសួរចម្លើយទេ។ ក្រដាសគេសួរចម្លើយ គេហែកចេញពីសៀវភៅហ្នឹងហើយ គេសរសេរជាក្រដាស។ ក្រដាសគេហែកចេញពីសៀវភៅ ហើយសរសេរ គេអត់សរសេរនៅក្នុងសៀវភៅហ្នឹងទេ។

**ស៖** លោកសាក្សី សៀវភៅដែលលោកបានឃើញនៅក្រាំងតាចាន់ តើមានក្របនៅខាងមុខ ដូចឯកសារដែលលោកកំពុងតែមើលនេះទេ?

**ថ៖** បាទ ឃើញសៀវភៅហ្នឹងមែន។

**ស៖** សូមលោកពិនិត្យមើលអក្សរដៃនៅត្រង់ឯកសារ E3/4092 បាទគឺឯកសារ E3/4092។ តើលោកអាចចាំបានទេ អក្សរនេះជាអក្សរសរសេរដៃដោយអ្នកណា?

**ថ៖** ខ្ញុំមិនចាំទេ ហើយមិនស្គាល់ទៀត។

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំសូមបង្ហាញឯកសារមួយគឺ E3/2421, ERN ជាភាសាខ្មែរ 00271176 ដល់ 77, ERN ជាភាសាអង់គ្លេស 00322201 ដល់ 02 និង ERN ជាភាសាបារាំង 00623832 ដល់ 33។ នេះគឺជារបាយការណ៍វាយអង្គុលីលេខពីគុកក្រាំងតាចាន់។ ខ្ញុំសូមការអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះជូនសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកមើលឯកសារដែលបានបង្ហាញជូនលោកគឺ ថ្ងៃទី០៥ ខែកក្កដា ៧៨ របាយការណ៍លាយលក្ខណ៍អក្សរពី អាន់។ នៅក្នុងចម្លើយនៅជាមួយៗនឹងសហចៅក្រមស៊ើបអង្កេតគឺ ឯកសារ D232/93។ ចម្លើយរបស់លោកនៅត្រង់ចម្លើយលេខ៧០ហ្នឹងលោក ឬ៧១ លោកឆ្លើយដូចតទៅ៖ "ថាតើនេះគឺជាឯកសារដែលលោកវាយអង្គុយលីលេខនៅក្រាំងតាចាន់ដោយយកសៀវភៅកត់ត្រាដែលសរសេរដោយដៃដែលគេផ្តល់មកឱ្យលោកវាយជាអង្គុយលីលេខហ្នឹងមែនទេ? តើឯកសារវាយជាអង្គុយលីលេខនេះ លោកវាយមែនទេ?

[០៩:៤៦:៤៤]

**លោក ស្រី ថន៖**

**ឆ៖** បាទ មក ខ្ញុំចាំមិនបានទេព្រោះវាយអង្គុយលីលេខនេះមិនមែន -- ព្រោះអក្សរដូចគ្នា មិនដឹងជាខ្ញុំវាយឬក៏គេវាយ ខ្ញុំអត់ -- ចាំអត់បានលោក។

**ស៖** ខ្ញុំមិនសួរថាតើលោកអាចបញ្ជាក់អះអាង ដោយសាររយៈពេលហ្នឹងវា៣០-៤០ឆ្នាំមកហើយ តើនេះគឺជាឯកសារដែលលោកវាយដោយផ្ទាល់ដៃឬក៏អត់នោះទេ។ ខ្ញុំសួរថានេះ គឺជារបៀបឯកសារដែលគេត្រូវវាយនៅក្រាំងតាចាន់ឬក៏អត់ នៅពេលដែលលោករៀនធ្វើជាអ្នកវាយអង្គុយលីលេខនៅទីនេះ? តើទម្រង់នេះ របៀបនេះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ទម្រង់ៗនិងវិធី របៀបវាយនេះគឺពិតប្រាកដមែន។

**ស៖** អ្វីដែលខ្ញុំចង់ឱ្យលោកឆ្លើយនោះគឺថា សូមឱ្យយកសៀវភៅកត់ត្រាដែលខ្ញុំបានផ្តល់ឯកសារទៅឱ្យលោក គឺE3/4092 ហើយសុំ -- ហើយនៅក្នុងសៀវភៅនោះសូមលោកចូលទៅមើលទំព័រ ERN ជាភាសាខ្មែរ 00271156 ដល់ 57 ហើយនៅក្នុងទំព័រហ្នឹងគឺខ្ញុំបានគូសបង្ហាញងាយស្រួលដល់លោក គឺ

ERN 00834818 ដល់ 19, ERNជាភាសាបារាំង 00721298 ទៅ 99។ ហើយប្រសិនបើអាចសូមលោកប្រៀបធៀបឯកសារសរសេរដោយដៃ និងឯកសារវាយអង្គុយលីលេខដែលទើបតែផ្ដល់ឲ្យលោក។ តើលោកអាចបញ្ជាក់បានទេថា ឯកសារវាយអង្គុយលីលេខហ្នឹងគឺសំអាងឬក៏ចម្លងពីសៀវភៅសរសេរដោយដៃចំពោះអ្នកទោសចំនួន ប្រាំពីរនាក់ដែលមានឈ្មោះរៀបរាប់នេះទេ?

[០៩:៤៩:៣៤]

**ធៈ** បាទ មិនមានទេ។ សៀវភៅនេះ មានសៀវភៅក្របអ៊ីចឹងដែរ ប៉ុន្តែទម្រង់សរសេរនេះមិនដឹងជាសៀវភៅនេះតាំងពីឆ្នាំ -- មុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ៧៥បាទ។ ខ្ញុំអត់ចាំបាទទេ។ ប៉ុន្តែ ពេលដែលខ្ញុំចូលទៅដល់ ខ្ញុំឃើញតែសៀវភៅហ្នឹងទេ ប៉ុន្តែនៅក្នុងសៀវភៅហ្នឹងមិនដឹងជាមានទម្រង់យ៉ាងម៉េច គឺខ្ញុំអត់ៗចាំទេ អត់បានឃើញទេ។

**សៈ** ខ្ញុំដឹងថាលោកមិនចាំទេជាង៣០ឆ្នាំកន្លងមកហើយ ថាតើឯកសារជាក់លាក់ណាមួយលោកជាអ្នកវាយអង្គុលីលេខទេ តែជាទូទៅ តើលោកអាចជួយបញ្ជាក់បានថាដំណើរការដែលលោកបានអនុវត្តនៅពេលលោកវាយឯកសារ គឺត្រូវយកសៀវភៅសរសេរដោយដៃដែលគេឲ្យមកលោក ហើយវាយអង្គុលីលេខទៅជារបាយការណ៍ដែលជាកិច្ចការ គេប្រធានឈ្មោះ អាន់ នេះចាត់តាំងឲ្យលោកធ្វើអ៊ីចឹងឬក៏យ៉ាងណា?

**ធៈ** បាទ មិនមែនទេ។ ខ្ញុំបញ្ជាក់ប្រាប់ទៅលោកថា ពេលដែលគេសរសេរហើយ សរសេរក្រដាសគឺចេញជាក្រដាសរ៉ាមអ៊ីចឹង ចេញជាក្រដាសរ៉ាមហើយ គេសរសេរជាដៃ ក្រដាសរ៉ាមហើយគេយកក្រដាសហ្នឹងយកមកឲ្យខ្ញុំបានចម្លងអង្គុលី អត់មានសរសេរសៀវភៅទេៗ។

**សៈ** ខ្ញុំយល់ ប៉ុន្តែខ្ញុំសួរលោក តើលោកយកក្រដាសសរសេរដោយដៃនៃចម្លើយសារភាពដែលគេឲ្យមកលោក ហើយយកក្រដាសសរសេរដោយដៃវាយជារបាយការណ៍ ហើយដែលក្រោយចុងបញ្ចប់ គឺប្រធានគុកឈ្មោះ អាន់ ជាអ្នកចុះហត្ថលេខា?

**ធៈ** បាទ ពិតប្រាកដមែន។

**សៈ** ប្រសិនជាលោកចូលទៅរបាយការណ៍វាយអង្គុលីលេខដែលខ្ញុំផ្ដល់លោកគឺ E3/2421 ចុះថ្ងៃទី៥ កក្កដា ១៩៧៨ នៅខាងដើមបំផុតនៃរបាយការណ៍គឺ មន្ទីរអប់រំស្រុក១០៥ តើគុកក្រាំងតាចាន់គឺៗជាគុកមួយនៅជាគុកមួយឈ្មោះថាជាមន្ទីរអបរំស្រុក១០៥ ឬក៏យ៉ាងម៉េច នៅពេលលោកវាយអង្គុលីលេខហ្នឹង?

[០៩:៥២:៣៦]

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ គ្រាន់គេដាក់ក្នុងដើមទីបនៃដំបូងនៃអក្សរដែលយើងវាយហ្នឹង គឺគេដាក់ "មន្ទីរអប់រំស្រុក១០៥" អីចឹងហ្នង។ ខ្ញុំមិនបានដឹងថា មន្ទីរហ្នឹងជាមន្ទីរស្រុក ឬមន្ទីរខេត្តយ៉ាងម៉េចខ្ញុំអត់បានយល់ទេ។

**ស៖** តើស្រុកត្រាំកក់ ហៅថា "ស្រុក១០៥" ដែរ ឬក៏អត់?

**ឆ៖** ពិតប្រាកដមែន។

**ស៖** ហើយនៅខាងលើបំផុតនៃឯកសារនេះ គឺរបាយការណ៍នេះសរសេរ សូមដកស្រង់៖ "សូមគោរពនិងផ្ញើសេចក្ដីរាយការណ៍ជូនបក្សអំពីចម្លើយអ្នកទោសដូចតទៅ" បញ្ចប់ការដកស្រង់។ តើប្រធានគុកឈ្មោះ អាន់ ឬក៏អនុប្រធាន ឌុច ជាអ្នកណែនាំថាតើត្រូវបញ្ជូនរបាយការណ៍នេះទៅឯណា ក្នុងករណីនេះគឺរបាយការណ៍នេះគឺបញ្ជូនទៅបក្ស។ តើអីចឹងទេ?

**ឆ៖** បាទ ពិតប្រាកដមែន។ របាយការណ៍នេះបញ្ជូនទៅបក្ស ប៉ុន្តែមិនដឹងជាបក្សនៅត្រង់ណាទេ។

**ស៖** របាយការណ៍ជាក់លាក់មួយពាក់ព័ន្ធទៅនឹងអ្នកទោសចំនួនប្រាំពីរនាក់ ដែលគេចោទថាជាជនក្បត់ដែលគេរាយការណ៍ថាជាទាហានរបបលន់នល់ ដោយសារតែបញ្ជាក់យោបល់ដូចតទៅ។ សូមដកស្រង់៖ "ក្នុងរបបចាស់ យើងសប្បាយចិត្តណាស់ដែលយើងមានលុយ យើងចង់ស៊ីអីក៏បាន យើងទៅណាក៏បាន យើងអាចរួមភេទជាមួយស្ត្រី យើងអាចយើងលេងល្បែងនៅពេលណាក៏បានតាមតែចិត្តយើងចង់ យើងមិនអាចរស់នៅក្នុងរបបនេះបានទេ ដោយសាររបបនេះពិបាកណាស់"។ បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ លោកសាក្សីគឺ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា តើមនុស្សម្នាក់ក្នុងអ្នកទោសម្នាក់ ក្នុងចំណោមក្រុមមនុស្សដែលលោកបានឃើញនៅក្នុងគុកក្រាំងតាចាន់ គឺជាអ្នកដែលប្រភេទនេះដែលត្រូវគេចោទប្រកាន់ ដោយសារថារិះគន់ ឬជំទាស់ជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ?

[០៩:៥៥:៤៣]

**ឆ៖** បាទ ពិតប្រាកដមែន។ សម័យនោះ បើគ្រាន់តែនិយាយថាហូបមិនឆ្អែត ក៏ត្រូវជាប់គុកដែរ មិនបាច់ចាំដល់តែនិយាយបរិហារស្អីទេ។ គ្រាន់តែមានយោបល់ថា ហូបមិនឆ្អែតមិនឆ្ងាញ់ ក៏ត្រូវវាបញ្ជូនទៅដែរ។ ហ្នឹងភាគច្រើនដែលខ្ញុំឃើញ។

**ស៖** សូមលោកមើលទំព័រទី២ ចុងៗក្រោយបំផុតនៃទំព័រទី២ ហើយសូមលោកជម្រាបជូន

អង្គជំនុំជម្រះផង ប្រសិនណាជាលោកចាំហត្ថលេខា ឬក៏អក្សរសរសេរដោយដៃនៅចុងបញ្ចប់នៃរបាយ-ការណ៍នេះ គឺត្រង់ចុងបញ្ចប់នៃទំព័រទី២។

**ឆ៖** អត់ស្គាល់សំណួរអត់យល់សោះ។ ម្តងទៀត។

**ស៖** សូមលោកមើលចុងក្រោយបំផុតនៃទំព័រទី២ តើអ្នកណាជាអ្នកចុះហត្ថលេខាលើរបាយ-កាណ៍នេះ?

**ឆ៖** បាទរបាយការណ៍នេះ គឺ អាន់ ជាអ្នកចុះហត្ថលេខា។

**ស៖** តើរបាយការណ៍ទាំងអស់ដែលលោកវាយអង្គុលីលេខនៅក្រាំងតាចាន់ដែលប្រធានឈ្មោះ អាន់ ឱ្យលោក ឬក៏មានកម្មាភិបាលណាមួយសញ្ញេលើរបាយការណ៍ហ្នឹងដែរ ឬក៏មានតែ អាន់ ទេ?

**ឆ៖** បាទ ពេលដែលខ្ញុំវាយចប់ហើយនោះ មិនមានអ្នកណាមួយអ្នកស៊ីញ៉េទេ។ ពេលដែលខ្ញុំចេញមកស៊ីញ៉េ ព្រោះមានប្រធាន អនុប្រធានរបស់គេហ្នឹង វាក្រុមគ្នាហ្នឹង វាបីបួននាក់ តែខ្ញុំមិនស្គាល់ឈ្មោះគេអស់ទេ ជាអ្នកស៊ីញ៉េ។

**ស៖** D3232/93 ទី៣៣ ដល់៣៨ សួរថា "តើលោកស្គាល់ឯកសារដែលគេផ្ញើមកឱ្យលោកនេះទេ? ខ្ញុំបានឮថា ឯកសារហ្នឹងគឺ -- "លោកដឹងគេផ្ញើនៅទីណាទេ? ខ្ញុំឮសួរថាគេផ្ញើទៅថ្នាក់លើ តែមិនដឹងថាថ្នាក់លើហ្នឹងនៅឯណាទេ"។ បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ តើគុកក្រាំងតាចាន់ មាននីរសារដែលត្រូវបញ្ជូន ឬក៏នាំយករបាយការណ៍ឯកសារពីគុកក្រាំងតាចាន់ ទៅមន្ទីរ១០៥ ទៅមន្ទីរស្រុកដែរឬទេ?

[០៩:៥៩:០២]

**ឆ៖** បាទមាន ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះវាទេ ព្រោះឯកសារទាំងឡាយ គេបញ្ជូនតាមនីរសារ ប៉ុន្តែនីរសារហ្នឹង ខ្ញុំអត់ស្គាល់ឈ្មោះទេ។

**ស៖** តើចាំទេ តើមាននីរសារប៉ុន្មាននាក់ធ្វើការនៅគុកក្រាំងតាចាន់?

**ឆ៖** បាទ ខ្ញុំមិនដឹងមានប៉ុន្មាននាក់ទេ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញរបាយការណ៍វាយអង្គុលីលេខមួយទៀត ដើម្បីឱ្យសាក្សីពិនិត្យមើល។ គឺឯកសារ E3/2425 ។ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីពីខាងដើមលោកបានបញ្ជាក់ថា លោកចងចាំនៅត្រង់ចម្លើយលេខ៥៦ លោកថា លោកចងចាំឯកសារ D232/93 ហ្នឹង ខ្ញុំសូមសួរលោកអំពីរបាយការណ៍នេះ។ នៅក្នុងរបាយ-ការណ៍ស្តីអំពីចម្លើយអ្នកទោសអតីតទាហានលន់ នល់ ពីរនាក់ មួយឈ្មោះ អោម ចាន់ថា, មួយទៀតឈ្មោះ ប៉ុក ប៊ុនលី គឺជាអតីតទាហានលន់ នល់ពីរនាក់ដែលត្រូវបានចោទប្រកាន់ថា បានលួចដូង ហើយនិងលួចដំឡូងមី ដើរហើរសេរី ហើយធ្វើពុតជាឈឺមិនអាចទៅធ្វើការបាន”។ សំណួរខ្ញុំសួរថាតើអ្នកទោសដែលគេបញ្ជូនទៅគុកក្រាំងតាចាន់ រួមទាំងមនុស្សដូចខ្ញុំរៀបរាប់នេះត្រូវបានចោទប្រកាន់ដោយសារតែលួចចំណីអាហារ ឬក៏ធ្វើពុតជាឈឺៗអស់កម្លាំងមិនអាចទៅធ្វើការកើត។ តើមានអ៊ីចឹងមែនទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:០២:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំក៏អានឯកសារនេះដែរ។ គឺខ្ញុំ -- គឺថាពាក់ -- គឺខ្ញុំសូមឱ្យមានការដកស្រង់ឱ្យបានច្បាស់លាស់ ដែលគឺពាក់ព័ន្ធទៅនឹងគេចោទប្រកាន់ថា ជាចោរលួចរបស់របរចំណីអាហារញ៉ើកញ៉ាប់។ សូមឱ្យដកស្រង់ឱ្យបានពេញលេញតែម្តង។

**សួរដោយលោក ឌេល លីសាក់៖**

ត្រឹមត្រូវហើយអ្វីដែលគេបានលួចនោះ គឺគេលួចចំណីអាហារ លួចដូង លួចដំឡូងមី លួចស្ករ។

**ស៖** សំណួររបស់ខ្ញុំម្តងទៀត លោកសាក្សី តើអ្នកទោសដែលគេបញ្ជូនទៅក្រាំងតាចាន់រួមទាំងអ្នកដែលគេចោទប្រកាន់ថាលួចចំណីហូប ឬធ្វើពុតជាឈឺមិនអាចទៅធ្វើការកើត។ ពិតជាមានអ៊ីចឹងទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ អ្នកទោសដែលគេបញ្ជូនទៅហ្នឹងគឺភាគច្រើនសុទ្ធតែគេចោទថា លួច និងពុត ហើយ និងខ្ជិលតែម្តង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអធ្យាស្រ័យដែលខ្ញុំរំខានដល់លោក។ យើងកំពុងតែអានរបាយការណ៍តែមួយ ហើយសហព្រះរាជអាជ្ញាមិនបាននិយាយថា អ្នកទោសពីរនាក់ដែលបានលើកឡើងហ្នឹងគឺជាទាហានដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់ ឬក៏ម៉េចទេ។ គឺនេះគឺជាទាហានពីរនាក់មកពី -- ចាប់បានពីកងណាមួយ គឺអ្នកដែលលួចដូង គឺវាមិនបានឆ្លើយបញ្ជាក់ ផ្ទុះបញ្ចាំងអំពីឯកសារនេះ ប្រសិនយើងដកស្រង់ឯកសារពីក្រាំងតាចាន់គឺយើងដកស្រង់វា សូមឲ្យដកស្រង់ពេញលេញតែម្តង។

[១០:០៤:២៥]

**លោក ឌេល លីសាក់៖**

ខ្ញុំបានកត់សម្គាល់ថា ទាហានលន់ នល់ នេះគឺខ្ញុំមិនមានកាតព្វកិច្ចអីត្រូវរៀបរាប់អំពីថាមនុស្សម្នាក់មានចាក់សាក់នៅលើខ្លួន គឺមេធាវីការពារក្តីខ្លួនឯងគឺថាមានសិទ្ធិសួរអីចឹង បើចង់សួររឿងចាក់សាក់រឿងអីនោះ។ គឺឯកសារ E3/4083 គឺដែលខ្ញុំបានផ្តល់ពីមុន គឺឯកសារ E3/4083។ សុំការអនុញ្ញាតដើម្បីបង្ហាញជូនសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សុំឲ្យលោកពិនិត្យមើលក្របសៀវភៅសរសេរដោយដៃនេះ ដូចដែលសៀវ-ភៅមួយខ្ញុំបង្ហាញពីខាងដើមគឺ មានរូបក្មេងៗ កុមារៗសរសេរ។ ទី១ សុំលោកជួបបញ្ជាក់ផងមើលថាតើនេះគឺជាសៀវភៅកត់ត្រាមួយក្នុងចំណោមសៀវភៅកត់ត្រាជាច្រើន ដែលលោកបានឃើញនៅក្រាំងតាចាន់ ឬក៏អត់។ នេះសៀវភៅកត់ត្រាប្រភេទនេះ?

**លោក ស្រី ថន៖**

**ឆ៖** បាទ ពិតមែនហើយ សៀវភៅនេះគឺក្នុងចំណោមសៀវភៅទាំងអស់។ សុទ្ធតែប្រហាក់ប្រហែលគ្នាទាំងអស់។

**សៈ** សៀវភៅនេះ គឺដូចជាស៊ីចង្វាក់គ្នាជាមួយនឹងបញ្ជីអ្នកទោសជាជាងក្រដាសកត់ត្រា ឬក៏ក្រដាសកត់ត្រាចម្លើយសារភាព។ បើសិនណាលោកចូលទៅមើល ERN ជាភាសាខ្មែរ 00068026 ដែលខ្ញុំបានគូសបង្ហាញលោកផង ហើយ ERN អង់គ្លេស 00233948, បារាំង 00778855 ដល់ 56, ហើយនៅត្រង់កណ្ដាលនៃទំព័រភាសាខ្មែរគឺ 68026។ តើឈ្មោះទាំងអស់នេះ ជាឈ្មោះអ្នកទោសក្នុងចំណោមមានឈ្មោះ អោម ចាន់ថា មានឈ្មោះ ប៉ុក ប៊ុនលី អតីតទាហានលន់ នល់ពីនាក់នេះត្រូវបានគេចោទថា លួចដូង លួចដំឡូងមី។ សំណួររបស់ខ្ញុំពេលដែលលោកមកដំបូងថា តើលោកចាំអក្សរដៃនៅត្រង់ទំព័រនេះទេ? ឬក៏ថាតើលោកចាំបានទេ អ្នកណាជាអ្នកសរសេរបញ្ជីអ្នកទោសនេះ?

**ឆៈ** បាទ អក្សរនេះ ខ្ញុំអត់ចាំទេ។ មិនដឹងជាអ្នកណាអ្នកសរសេរទេ។

[១០:០៨:០៨]

**សៈ** ហើយនៅត្រង់ទំព័រនេះ មានអ្នកទោសភាគច្រើននៅទំព័រហ្នឹង និងនៅទំព័របន្ទាប់នោះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេគឺថា មានសរសេរអក្សរ "អ៊ិច" ច្រើនណាស់នៅពីខាងមុខអ្នកទោសហ្នឹងសរសេរអក្សរជាអក្សរ "អ៊ិច" នៅពីខាងមុខឈ្មោះអ្នកទោស។ តើលោកអាចជួយជម្រាបជូនអង្គជំនុំជម្រះបានទេ? សរសេរ "អ៊ិច" ហ្នឹងតំណាងឲ្យស្អីហ្នឹង?

**ឆៈ** បាទ អត់ ខ្ញុំអត់ដឹងទេ។

**សៈ** ប្រសិនលោកបើកទៅពីរបីទំព័រទៅខាងមុខទៀតគឺត្រង់ ERN 0068028 មានអ្នកទោសមួយចំនួនដែលថា ត្រូវបានយកទៅកន្លែងមួយឈ្មោះ ម៉េង នៅឆ្នាំ៧៨។ លោកបាននិយាយថាគឺជាក្រុមអ្នកទោសមួយក្រុមដែលគេបញ្ជូនពីក្រាំងតាចាន់បញ្ជូនទៅគុកមួយទៀតគឺនៅចុង ៧៨ ឬក៏ដើមឆ្នាំ៧៩។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា តើអ្នកទោសនៅក្នុងបញ្ជីនេះ គឺជាអ្នកទោសមួយចំណែកដែលគេបានបញ្ជូនចេញពីក្រាំងតាចាន់នៅចុងឆ្នាំ៧៨ នោះឬ?

**ឆៈ** បាទ ខ្ញុំអត់ចាំទេ ប៉ុន្តែកាលពីចុងឆ្នាំ៧៨នេះ បញ្ជូនចេញទៅនេះ គឺមិនដឹងជាយកទៅដាក់គុកនៅត្រង់ណាទេ គឺខ្ញុំអត់ដឹង ប៉ុន្តែមានបញ្ជូនចេញមែន។

**សៈ** លោកស្គាល់ ម៉េង ហ្នឹង ជាអ្នកណាឬទេ? ពីព្រោះសរសេរថា "បញ្ជូនទៅកន្លែង ម៉េង"។ មេង ហ្នឹងជាអ្នកណា?

**ឆៈ** បាទ អត់ស្គាល់ទេ។

**សៈ** នៅត្រង់ទំព័រដដែល មានកំណត់ត្រាថា អ្នកទោសមួយចំនួនបានស្លាប់ដោយសារតែជំងឺ។

តើលោកដឹងទេ អ្នកណាជាអ្នកសរសេរ ឬក៏តាមដានអ្នកទោសស្លាប់ដោយសារជំងឺ?

**ឆ៖** បាទ អត់ដឹងទេ ដូចជាគ្មាន។

[១០:១១:៣៥]

**ស៖** ហើយចំណុចចុងក្រោយនៃឯកសារនេះ ខ្ញុំសូមបង្ហាញជូនលោក ប្រសិនជាលោកចូលទៅចុងក្រោយបំផុត ERN 00068036 ជាភាសាខ្មែរ។ តើលោកចាំអក្សរសរសេរដោយដៃ នៅត្រង់ទំព័រ 68036 ERN ជាភាសាខ្មែរ?

**ឆ៖** បាទ អត់ចាំទេ ហើយអត់ស្គាល់ទៀត អក្សរនេះ។

**ស៖** នៅក្នុងបញ្ជីនេះ គឺមានចំនួនអ្នកទោស២១ ដែលត្រូវថាជាបណ្ដាញរបស់ "អាក្បត់ទាំង ២០នាក់ ដែលជាខ្សែ សេ.អ៊ី.អា ចង់រត់ទៅវៀតណាម ឬរត់ទៅប្រទេសថៃ"។ តើមានអ្នកទោសប្រភេទនុ៎ង គឺអ្នកទោសដែលត្រូវគេថាមានផែនការរត់គេចពីរបបកម្ពុជាប្រជាធិបតេយ្យរត់ចូលទៅវៀតណាម ឬក៏ទៅថៃនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនអាចចាំបានទេ។

**ស៖** --

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនជំទាស់នឹងការតាំងសំណួរនេះទេ ក៏ប៉ុន្តែខ្ញុំបានកត់សម្គាល់ឃើញថា ទំព័រជាក់លាក់មួយចំនួនដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺខុសគ្នាពីទំព័រដែលយើងផ្ទៀងផ្ទាត់នេះ។ ដូច្នេះ គឺវាមិនដឹងថា ទំព័រនេះ ជាទំព័រមួយនៃឯកសារនេះ ឬក៏អត់។ ដូច្នេះនេះគឺជាការគួរឲ្យកត់សម្គាល់ ដូចដែលយើងបានឃើញអំពីតាំងពីប្រវត្តិសារតារ តាំងពីទំព័រ តាំងកូឡោន តាំងពីពណ៌ជាដើម ។ល។ ដូច្នេះ វាឯកសារទាំងអស់នេះចោទជាបញ្ហា យើងអត់មានឯកសារដើមណាមួយនោះទេ។ អ៊ីចឹង វាមានបញ្ហា។ ដូច្នេះការកត់សម្គាល់របស់យើងខ្ញុំ គឺចាត់ទុកជាបញ្ហាទូទៅពាក់ព័ន្ធទៅនឹងការយោងទៅនឹងឯកសារទាំងអស់នេះ។ ខ្ញុំមិនដឹងថាតើទំព័រដែលកំពុងតែបង្ហាញនេះ វាជាទំព័រមួយនៃទំព័រឯកសារដែលលើកយកមកនិយាយឬក៏នោះទេ។

**លោក ឌេល លីសាក់៖**

មេធាវីការពារក្ដី គឺថាគាត់អាចលើកចំណុចទាំងអស់នេះឡើង នៅពេល ពេលវេលារបស់គាត់ត្រូវតាំងជាសំណួរ។ អ៊ីចឹង លោកប្រធាន ខ្ញុំអាចតាំងសំណួរទៅមុខទៀតបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ ជាត្រឹមត្រូវ។ នេះជាវិធីសាស្ត្រមួយ ប៉ុន្តែក៏សុំឱ្យវាច្បាស់លាស់ទាំងអស់គ្នាដែរ ជៀសវាងមានការភាពមិនច្បាស់លាស់កើតឡើងនៅក្នុងអំឡុងពេលសវនាការ នាំឱ្យមានបញ្ហាយឺតយ៉ាវ ហើយធ្វើឱ្យដំណើរការហ្នឹងមិនមានប្រសិទ្ធភាព។

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។ បុគ្គលិករដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ រួមទាំងមេធាវីប្រឹក្សារបស់គាត់ នៅក្នុងអំឡុងពេលសម្រាក និងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទី គឺឱ្យបានមុនអង្គជំនុំជម្រះចូលកាន់អសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់**

**ស៖** យើងកំពុងតែនិយាយអំពីឯកសារ E3/4083 គឺជាបញ្ជីមួយ ហើយនៅចុងឯកសារនោះខ្ញុំមានសំណួរពីរពាក់ព័ន្ធទៅនឹងឯកសារនេះ។ អ្នកទោសលេខរៀងទី២៨ គឺជាមនុស្សដែលរអ៊ូរទាំដែលថាហូបបបរ គឺទំព័រ 00068036 អ្នកទោសលេខរៀងទី២៨ ដែលរអ៊ូរទាំថាបានហូបតែបបរ។ អ៊ីចឹងខ្ញុំចង់សួរថា តើអ្នកដែលនៅក្រាំងតាចាន់ អ្នកទោសនៅក្រាំងតាចាន់ គឺតើមានទេ មានអ្នកណាដែលរអ៊ូរទាំថា ហូបចុកមិនគ្រប់គ្រាន់ ហូបតែបបរអ៊ីចឹងទេ?

**ឆ៖** បាទ អ្នកដែលជាប់ទោស ដែលគេយកទៅដាក់នៅគុកក្រាំងតាចាន់ហ្នឹង ភាគច្រើនគឺអ្នករអ៊ូរទាំ អ្នកហូបមិនឆ្អែត អ្នកធ្វើការយ៉ាប់ពេក អ្នកដែលគ្នាមិនសូវចេះការងារហ្នឹងត្លញត្លែរ គឺឲ្យតែពីរឿងនឿយហត់គឺត្រូវតែយកទៅហ្នឹងតែម្តង។ ភាគច្រើនគឺអ៊ីចឹង។

**សៈ** លេខ២៩ ជាអ្នកទោសចុងក្រោយនៅក្នុងឯកសារហ្នឹង គឺគាត់អាយុ៦៣ ឈ្មោះ សួង រដ្ឋ។ គាត់ជាអតីតអ្នកភូមិ ហើយគេចោទថាលួចម្ហូប។ តើនៅក្នុងចំណោមអ្នកទោសនៅក្រាំងតាចាន់ហ្នឹងមានមនុស្សចាស់ទេ?

[១០:៣៦:២៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ ទៅនឹងសំណួរនេះ។ យើងមិនដឹងថា តើទំព័រនេះ ជាទំព័រនៃឯកសារក្រាំងតាចាន់ដែរ ឬក៏អត់ទេ? ដូចខ្ញុំបញ្ជាក់រួចហើយថា ទំព័រនេះ ខុសពីទំព័រផ្សេងទៀត។ ដូច្នេះ យើងអត់មានមធ្យោបាយណាមួយក្នុងការទទួលបានច្បាប់ដើមទេ។ អ៊ីចឹង យើងមិនដឹងថាតើទំព័រមួយនេះ នៃឯកសារនេះត្រូវបានសូកបញ្ចូលទៅក្នុងឯកសារនេះ ឬក៏អត់? អ៊ីចឹងយើងមើលទៅលក្ខណៈខាងក្រៅទម្រង់នេះ ដូចខុសពីឯកសារផ្សេងទៀត ខុសពីទំព័រផ្សេងទៀត។ អ៊ីចឹងយើងមិនដឹងថាតើ វាជាឯកសារតែមួយ ឬក៏យ៉ាងម៉េច? សហព្រះរាជអាជ្ញា គឺថាគាត់ថាសាក្សីហ្នឹងមើលឃើញរួចហើយ ហើយវាជាឯកសារមកពីក្រាំងតាចាន់។ ក៏ប៉ុន្តែតាមពិតយើងអត់ដឹងទេ។

**លោក ឌេល លីសាក់៖**

ជាថ្មីម្តងទៀត គឺខ្ញុំឆ្លើយតបដដែល គឺជាឯកសារដែលដាក់ចូលទៅក្នុងសំណុំរឿងរួចទៅហើយ។ ដូច្នេះពេលដែលគាត់សួរនោះ មេធាវី គាត់អាចចោទសួរពីឯកសារនេះបាន។ ខ្ញុំសួរអំពីមនុស្សចាស់ នៅក្រាំងតាចាន់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំចង់ឲ្យលោកប្រធានផ្តល់ការសម្រេចចំពោះបញ្ហានេះ។

[១០:៣៧:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៦:១៥]

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញាអន្តរជាតិ អាចឆ្លើយបញ្ជាក់បានទេថាឯកសារចុងក្រោយអម្បាញ់មិញនេះ E3/4083 ហ្នឹងជាឯកសារនៅមាននៅក្នុងសំណុំរឿងក្ដីបច្ចុប្បន្ននេះដែរឬទេ? ហើយមានភ្ជាប់ជាមួយនឹងជើងទំព័រនៃឯកសារនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះដែរឬទេ?

**លោក ឌេល លីសាក់៖**

ពិតណាស់លោកប្រធាន។ ឯកសារហ្នឹងមានក្នុងសំណុំរឿងយើងរួចហើយ។ ខ្ញុំមិនបានពិនិត្យផ្ទៀងផ្ទាត់ថាតើមាននៅក្នុងដីកាដំណោះស្រាយឬក៏អត់យ៉ាងនោះៗទេ ក៏ប៉ុន្តែឯកសារហ្នឹងគឺជាឯកសារដែលមាននៅក្នុងសំណុំរឿងដែលបានបង្ហាញនៅក្នុងវគ្គ០០២/០១ រួចមកហើយលោកប្រធាន គឺពាក់ព័ន្ធទៅនឹងត្រាំកក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវអង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីចំពោះសំណួរពាក់ព័ន្ធជាមួយនឹងឯកសារ E3/4083 នេះ។ ហើយតំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីបាន ហើយសាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះ សូមជម្រាបរំឭកដល់សហមេធាវីការពារក្ដីថា កិច្ចការពាក់ព័ន្ធនឹងបញ្ហានេះ គួរលោកទុកលទ្ធភាពនៅក្នុងការសួរដេញដោលពាក់ព័ន្ធនឹងបញ្ហាដែលលោកមានចម្ងល់ ឬក៏មានបញ្ហាចង់បញ្ជាក់ឲ្យច្បាស់នេះ ដល់វេនលោកដែលត្រូវនឹងត្រូវសួរ មានឱកាសក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:៤៨:០៨]

**លោក ឌេល លីសាក់៖**

សូមអរគុណ លោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសួរម្ដងទៀត។ តើមានអ្នកទោសជាមនុស្សចាស់ជរាដែរឬទេនៅក្នុងគុកក្រាំងតាចាន់លោកសាក្សី?

**លោក ស្រី ថន៖**

**ឆ៖** បាទ ខ្ញុំកម្រឃើញមនុស្សចាស់ជរាណាស់។

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីការឆ្លើយបញ្ជាក់របស់លោកនៅក្នុងឯកសារ D125/129, ឯកសារនេះគឺនៅលេខ 00224790 ជាភាសាខ្មែរ, ជាភាសាអង់គ្លេស 00231675, ជាភាសាបារាំង 00234576។ លោកឆ្លើយនៅពេលនោះថា លោកបានទទួលឯកសារសរសេរដៃដែលមានការរាយការណ៍ពីការចោទ -- រាយការណ៍ពីចម្លើយសារភាពរបស់អ្នកទោសដែលគាត់ឆ្លើយថាមានទំនាក់ទំនងជាមួយ សេ.អ៊ី.អា មានការលួចស៊ី រអ៊ូរទាំ ធ្វើការហត់ រអ៊ូថាហូបមិនឆ្អែត ពាក់ព័ន្ធនឹងទាហាន លន់ នល់ ជានាយទុន។ល។ អ៊ីចឹងយើងបានឃើញព័ត៌មានទាំងអស់នេះរួចមកហើយ អ៊ីចឹងខ្ញុំចង់សួរថាតើមានអ្នកទោសច្រើនទេនៅក្រាំងតាចាន់ដែលជាអតីតទាហាន លន់ នល់ ឬក៏ជាអ្នកដែលគេចោទថាមានការពាក់ព័ន្ធទៅនឹងរបប លន់ នល់?

[១០:៥០:០០]

**ឆ៖** បាទ ខ្ញុំមិនដែល បានដឹងថាគេបែងចែកអ្នកទោសជាពីរ បី ប្រភេទអ៊ីចឹង ប៉ុន្មានអ្នកទេ ខ្ញុំអត់បានដឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីបងប្អូនជីដូនមួយរបស់លោក នៅឯកសារ លេខ D232/93 ទំព័រ៦៨ លោកថា លោកមានបងប្អូនជីដូនមួយ ឈ្មោះ មាស អឿន ដែលគេចាប់យកទៅដាក់គុកនៅក្រាំងតាចាន់។ អ៊ីចឹងតើលោកដឹងយ៉ាងម៉េចបានថាបងប្អូនរបស់លោក បងប្អូនជីដូនមួយហ្នឹងត្រូវបានគេចាប់ហើយបញ្ជូនទៅក្រាំងតាចាន់ តើលោកដឹងដោយរបៀបណា?

**ឆ៖** បាទបងជីដូនមួយខ្ញុំគេចាប់យកទៅដាក់គុកក្រាំងតាចាន់នេះ គឺមុនពេលដែលខ្ញុំទៅដល់ហ្នឹងទៅទៀត។ ពេលដែលខ្ញុំទៅដល់គឺអត់មានឃើញទេ ហើយក៏ខ្ញុំសន្មតថា អ្នកដែលចាប់មកពីតាមភូមិឃុំគឺ ទៅដល់គុកក្រាំងតាចាន់ហ្នឹងតែម្តង។ ប៉ុន្តែដោយឡែកតែឈ្មោះបងជីដូនមួយខ្ញុំ ឈ្មោះ មាស អឿន ហ្នឹង គឺអត់ឃើញទេ។

**ស៖** តើបងជីដូនមួយរបស់លោកធ្វើអ្វី? ហើយនៅក្នុងអំឡុងរបបខ្មែរក្រហមគាត់រស់នៅឯណាដែរ?

**ឆ៖** បាទកាលពីមុនរបបខ្មែរក្រហមគាត់នៅភ្នំពេញ ក្រោយមកចេញពីភ្នំពេញមកគាត់នៅភូមិអង្គតានូ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**លោក ឌេល លីសាក់៖**

សូមលោកប្រធាន ខ្ញុំចង់ស្នើសុំការអនុញ្ញាតដើម្បីបង្ហាញឯកសារពីរ ដែលនិយាយអំពីមនុស្សតែមួយ គឺមនុស្សដែលមានឈ្មោះតែមួយទេ គឺមាស ភឿន ដែលត្រូវបានចាប់ខ្លួននៅស្រុកត្រាំកក់ ឯកសារនេះគឺ ឯកសារលេខ D137.39 និងឯកសារ D157.7។ លោកប្រធានខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះជូនសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:៥៣:១៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីឯកសារទី១ ដែលយើង -- គឺ D157. -- 137.38 គឺឯកសារចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ៧៧ គឺផ្ញើជូនមន្ទីរស្រុក១០៥។ ថ្ងៃ១៧ មេសា ឆ្នាំ៧៧ គឺចាប់ខ្លួនជនក្បត់ឈ្មោះ មាស ភឿន អាយុ២៦ឆ្នាំ ជាអតីតសិស្សថ្នាក់ទី២ ជាទាហានដែលមានឋានៈអនុសេនីយ៍ត្រី នៅពោធិ៍ចិនតុង។ គាត់ត្រូវបានចាប់ខ្លួន នៅភូមិថ្មុលខ្ពស់ ឃុំលាយបូរ ហើយបញ្ជូនទៅឲ្យខាងប៉ូលិស។ ចំណែកឯកនៅក្នុងឯកសារ D157.7, ជាភាសាខ្មែរ 00270871, ជាភាសាអង់គ្លេស 00866430, ជាភាសាបារាំង 00872808 យើងមើលហើយ ឃើញហើយថាមានកំណត់ត្រាពាក់ព័ន្ធទៅនឹងការសួរចម្លើយឈ្មោះ មាស ភឿន អាយុ២៥ឆ្នាំ រៀបការនឹង ម៉ៅ ចាន់ កើតនៅឃុំលាយបូរ ស្រុកត្រាំកក់ ចូលធ្វើទាហានឆ្នាំ៧០ ហើយមានឋានៈជាអនុសេនីយ៍ត្រី។ តើបុគ្គលហ្នឹងជាបងជីដូនមួយរបស់លោកហ្នឹងមែនទេ។

**លោក ស្រី ថន៖**

**ឆ៖** បាទពិតប្រាកដមែនហើយ។ មាស ភឿន ជាបងជីដូនមួយរបស់ខ្ញុំ។

**ស៖** តើបងរបស់ -- បងជីដូនមួយរបស់លោកហ្នឹងមានឋានៈជាអនុសេនីយ៍ទោមែនទេ នៅមុនឆ្នាំ១៩៧៧ គឺក្នុងរបប លន់ នល់ នោះ? -- សុំទោស ៧៥?

**ឆ៖** បាទ ខ្ញុំអត់ដឹងគាត់នៅក្នុងភ្នំពេញ គាត់ធ្វើជាទហាន ព្រោះខ្ញុំដឹងថាគាត់នៅរៀនជានិស្សិតនៅសម័យនោះ។

**ស៖** នៅក្នុងឯកសារលេខ D157.7 មានការសរសេរពាក់ព័ន្ធនឹងបងជីដូនមួយរបស់លោក ដែលនិយាយថា បុគ្គលនេះមានពាក់ព័ន្ធនឹង អាម៉ង់ និង អាជ័យហ៊ុន ដែលចង់ក្បត់យើង។ អ្នកទាំងអស់

នេះ និយាយថា យើងត្រូវអត់ធ្មត់បន្តិចទៀត ប្រទេសយើងនឹងដូចពីមុនវិញហើយ គឺមានសាសនា សាលារៀន មានវិស័យឯកជន មានកម្មសិទ្ធិឯកជន មានលុយកាក់ អីឡើងវិញហើយ។ ហើយបន្ទាប់មកទៀត នៅក្នុងកថាខណ្ឌបន្ទាប់មកទៀត មានការសរសេរថា ម្នាក់ហ្នឹងមិនមានផែនការច្បាស់លាស់ទេ ពួកគេកំពុងតែរង់ចាំវាយពីខាងក្រោមកវិញ។ ឥឡូវនេះ ពួកគេអ៊ូរទាំអំពីការលំបាកនិងភាពមិនគ្រប់គ្រាន់ ពីព្រោះថា នៅក្នុងរបប លន់ នល់ គឺថាមិនមានអ្វីខ្វះខាតទេ ប៉ុន្តែរបបនេះ គឺខ្វះខាត។ លោកសាក្សី នៅក្នុងឯកសារកំណត់ហេតុរបស់លោក គឺលេខ D232/93, ចម្លើយ៥៣ លោកនិយាយថា មានអ្នកទោសតិចតួចត្រូវបានដោះលែង ហើយអ្នកទោស៩៩ភាគរយត្រូវបានគេកម្ទេច គេមានដោះលែងតិចតួចណាស់។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើបងជីដូនមួយរបស់លោក ស្ថិតនៅក្នុងចំណោមអ្នកដែលគេដោះលែងនៅក្រាំងតាចាន់ ឬក៏ស្ថិតនៅក្នុងចំណោមអ្នកទោសទាំង៩៩ ភាគរយដែលត្រូវបានគេកម្ទេច?

[១០:៥៧:២៥]

**ឆ៖** បាទ ពេលដែលគេចាប់បងជីដូនមួយរបស់ខ្ញុំមកនោះ គឺខ្ញុំអត់ទាន់បានចូលទៅនៅក្នុងកន្លែងមន្ទីរគុកក្រាំងតាចាន់ទេ។ ខ្ញុំនៅក្នុងជួរកងទ័ពនៅឡើយ គេមិនទាន់បានបញ្ជូនខ្ញុំទៅទេ។

**ស៖** តើពេលដែលគេចាប់ខ្លួនគាត់ ហើយបញ្ជូនទៅក្រាំងតាចាន់នោះ មានធ្លាប់ឃើញគាត់ទេទៀតទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី ខ្ញុំមានប្រធានបទចុងក្រោយ ចង់ពិភាក្សាជាមួយលោក គឺការសម្លាប់អ្នកទោសនៅក្រាំងតាចាន់ នៅក្នុងឯកសារស្តាប់ចម្លើយរបស់លោក គឺឯកសារ D232/93 ចម្លើយ២៩ លោនិយាយថា ឯកសារដែលគេប្រគល់ឲ្យលោកវាយអង្គុលីលេខនោះ គេដាក់ឈ្មោះអ្នកទោសដែលត្រូវកម្ទេច។

[១០:៥៨:៤៩]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតប្រគល់ជូនសាក្សីនូវឯកសារ E3/4145, ជាភាសាខ្មែរ គឺ 68737, អង់គ្លេស 00762845 ទៅដល់ 46, ជាភាសាបារាំង 00761101-02 ឯកសារនេះ ជាបញ្ជីអ្នកទោស។ អ៊ីចឹង ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះជូនសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ជាថ្មីម្តងទៀតហើយ យើងស្ថិតនៅក្នុងស្ថានភាពស្មុគស្មាញលំបាកណាស់ ពាក់ព័ន្ធនឹងឯកសារនេះ។ ខ្ញុំមិនដឹងថាតើលោកប្រធាន យល់អំពីការជំទាស់របស់ខ្ញុំកាលពីមុនឬក៏អត់នោះទេ? ខ្ញុំសូមអន្តរាគមន៍ពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារនេះ។ យើងបានធ្វើការស្រាវជ្រាវ ពាក់ព័ន្ធនឹងឯកសារនេះ។ នេះជាឯកសារកម្រមួយក្នុងចំណោមឯកសារកម្រនានា ដែលសហព្រះរាជអាជ្ញាបានផ្អែកលើ។ ហើយឯកសារនេះ គឺមាននៅទួលស្លែង។ ដូច្នេះ ខ្ញុំគិតថាឯកសារនេះមិនមែនជាឯកសារមកពីក្រាំងតាចាន់ទេ ប្រហែលជាឯកសារនេះគឺមិនពីមន្ទីរស-២១ទេ លោកប្រធាន។

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារនេះជាឯកសារទទួលរួចមកហើយៗ មានឯកសារជាច្រើនមកពីត្រាំកក់ ដែលមានដាក់នៅក្នុងទួលស្លែង។ អ៊ីចឹងមិនមែនមានន័យថា ឯកសារនេះមកពីទួលស្លែងទេ មិនមែនបានន័យថា មកពីស-២១ ទេ។ អ៊ីចឹងយើងចង់សួរគ្រាន់តែចង់ដឹងពាក់ព័ន្ធនឹងចំណុចនេះ។

[១១:០០:៤៥]

**លោក វ៉ិចទ័រ កូប៉េះ**

ឯកសារនេះគឺ E3/4145 គឺនិយាយអំពីទាហាន។ អ៊ីចឹងបើយើងនិយាយអំពីឯកសារស-២១ សាក្សីនេះគាត់មិនដឹងអ្វីពាក់ព័ន្ធទៅនឹងចំណុចនេះទេ។

**លោក ឌេល លីសាក់៖**

អ៊ីចឹង យើងមើលទំព័រហ្នឹងអត់ត្រូវទេ លោកមេធាវី។ អ្វីដែលខ្ញុំចង់បង្ហាញមិនមែនទំព័រហ្នឹងទេ។ មិនមែនទំព័រដែលមានអ្នកទោសមកពីភូមិភាគបូព៌ាទេលោកមេធាវី លោកមើលច្រឡំហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

ប៉ុន្តែឯកសារទំព័រហ្នឹងគឺស្ថិតនៅឯកសារ E1/4145 ហើយ។

**លោក ឌេល លីសាក់៖**

គឺដដែលទេ គឺដូចបញ្ជីមនុស្សដែលជាជាប់សាច់ឈាមរបស់លោកសាក្សី ហើយឯកសារហ្នឹងមកពីក្រាំងតាចាន់ទេ។ អ៊ីចឹង ខ្ញុំបានធ្វើការស្រាវជ្រាវហើយៗខ្ញុំអាចបញ្ជាក់បានថា សាក្សីជាច្រើន -- អ្នកទោសជាច្រើនហ្នឹងគឺស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់។ ឧទាហរណ៍ដូចជារបាយ-ការណ៍សួរចម្លើយដែលធ្វើឡើងដោយឈ្មោះ អាន់ នៅត្រាំកក់។ ឯកសារហ្នឹងគឺជាឯកសារត្រាំកក់ហើយ

អ៊ីចឹងសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យខ្ញុំបន្តសួរសំណួរទៅទៀត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោកនួន ជា ដែលជំទាស់លើការប្រើប្រាស់ឯកសារនេះរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះអនុញ្ញាត។

[១១:០២:៥១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារដែលគេផ្ដល់ជូនលោកនេះ លោកសាក្សី នេះគឺជាបញ្ជីអ្នកទោស៣៧នាក់។ បញ្ជីនេះមិនពេញលេញទេ ហើយយើងមានចំណារសរសេរដៃពីរ។ នៅខាងស្ដាំ ខាងក្រោមចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំសូមអាន៖ "គឺមានចំនួនសរុប ៣៧នាក់ មានក្មេងមានចាស់ ហើយគេបានបោសសម្អាត"។ អ៊ីចឹង តើលោកស្គាល់អក្សរសរសេរដៃហ្នឹងទេ លោកសាក្សី?

**លោក ស្រី ថន៖**

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ ប៉ុន្តែអ្នកដែលសរសេរលើក្រដាសនេះមានតែប្រធានពីរនាក់ទេ គឺ ឌុច និង អាន់។ មានតែពីរនាក់ហ្នឹងទេ សរសេរ។ ប៉ុន្តែអក្សរនេះ ខ្ញុំមិនសន្និដ្ឋានថា អក្សរនេះជាអក្សរ អាន់ ឬអក្សរ ឌុច ទេ ខ្ញុំមិនស្គាល់អក្សរគេច្បាស់។

**ស៖** លោកបានឆ្លើយថា បានវាយអង្គុលីលេខនូវបញ្ជីអ្នកទោសដែលមានឈ្មោះអ្នកដែលគេកម្ទេច។ ឯកសារនេះគឺ -- អ៊ីចឹងដូចទៅនឹងឯកសារដែលលោកបានវាយអង្គុលីលេខនៅពេលនោះទេ លោកមើលទម្រង់ទ្រង់ទ្រាយអីហ្នឹង?

**ឆ៖** បាទ ទម្រង់ទ្រង់ទ្រាយនេះពិតជាដូចជាឯកសារខ្ញុំវាយមែន ប៉ុន្តែឯកសារដែលកម្ទេចមនុស្សសម្លាប់៣០-៤០នាក់នេះគឺខ្ញុំអត់ដែលបានឃើញ ប៉ុន្តែទម្រង់ដូចគ្នានឹងខ្ញុំបានឃើញ ខ្ញុំធ្លាប់វាយ។

**ស៖** នៅក្នុងឯកសារលេខ D232/93 ចម្លើយទី២៦ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "អ្នកទោសគេយកទៅសម្លាប់នៅក្នុងគុក នៅក្រៅគុកក៏មាន។ ពេលគេវាយអ្នកទោសចោលនៅគុក ខ្ញុំបានឮសម្រែកអ្នកទោសស្រែក"។ ក៏ប៉ុន្តែនៅក្នុងឯកសារ E319.1.25 នៅចម្លើយទី៤៣ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឃើញសាកសពគរលើគ្នានៅខាងម្ខាងទៀតនៃរបងទ្វារ"។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកឃើញគំនរសាកសពហ្នឹងនៅខាងណា? នៅខាងជើង ខាងត្បូង ខាងលិច ឬក៏ខាងកើត?

[១១:០៦:០០]

**ឆ៖** ទេ ខ្ញុំមិនដែលឃើញសាកសពគរទេ។ ចម្លើយនេះគឺអត់ត្រឹមត្រូវទេ។ សំណួរ មិនត្រឹមត្រូវទេ។

**ស៖** អ្នកយាមក្នុងចំណោមក្រុមទាំងប្រាំមួយនាក់របស់លោកនៅក្រាំងតាចាន់ ដែលលោកហៅឈ្មោះថា ស៊ីម បានឆ្លើយពាក់ព័ន្ធទៅនឹងការសម្លាប់អ្នកទោសនៅក្នុងគុកនោះ។ ដូច្នេះ ខ្ញុំចង់សួរលោក ឯកសារ D40/20, ជាខ្មែរ 00165330, ជាភាសាអង់គ្លេស 00433569 ដល់ 70, ជាភាសាបារាំង 00524318។ នេះជាចម្លើយរបស់ ស៊ីម៖ "កងរបស់ខ្ញុំយាមនៅខាងក្រៅនៅពេលដែលគេសម្លាប់អ្នកទោស"។ គាត់ឆ្លើយបន្តទៅទៀត៖ "នៅពេលអ្នកទោសត្រូវបានគេសម្លាប់ ខ្ញុំត្រូវបានគេចាត់ឱ្យយាមនៅខាងក្រៅរបងក្រាំងតាចាន់ ហើយមិនមានអ្នកណាអាចទៅជិតហ្នឹងបានទេ។ យាមកុំឱ្យមានមនុស្សទៅជិត"។ សុំបញ្ឈប់ការដកស្រង់។ ជននោះគាត់បាននិយាយថា នៅក្នុងពេលប្រជុំដែលដឹកនាំដោយ អាន់, ឌុច, សេង កងរបស់លោកគឺត្រូវតែនាំអ្នកទោសទៅខាងក្រៅដើម្បីយកទៅសម្លាប់ចោល ហើយនិយាយថា យាមនៅខាងក្រៅ។ អ៊ីចឹងលោកចាំទេថាកងរបស់លោកទទួលបញ្ជាបែបនេះនោះ? គឺថានៅក្នុង ហើយនៅក្នុងបរិវេណក្រាំងតាចាន់ហ្នឹង គេធ្វើ គេប្រជុំនៅកន្លែងណាដែរ ដែលគេប្រគល់ភារកិច្ចឱ្យលោកធ្វើបែបនេះនោះ?

**ឆ៖** បាទ គ្មានទេ។ ពេលដែលគេប្រជុំឱ្យយើងទៅសម្លាប់គឺអត់ទេ។ ក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង ក្រុមខ្ញុំប្រាំមួយនាក់នេះ គឺគ្មានតួនាទី។ អាន់ អ្នកបញ្ជាទេ គឺកងទ័ព គឺមេបញ្ជាការកងទ័ព។ ខ្ញុំគឺកងពល ២១០ វរសេនាធំ១៣ មានឈ្មោះបងមាន និង បងថា ជាអ្នកបញ្ជា។ អ៊ីចឹង ខ្ញុំប្រធានគុកក្រាំងតាចាន់គឺគ្មានតួនាទីកោះហៅខ្ញុំប្រជុំទេ។ ខ្ញុំនៅខាងក្រៅ គឺគ្មានតួនាទីកោះខ្ញុំមកប្រជុំទេ។ គេមិនដែលហៅខ្ញុំប្រជុំទេ។

[១១:០៨:៥៥]

**ស៖** លោកសាក្សី កងការពារ កងយាមរបស់លោកនោះ តើត្រូវទទួលបញ្ជាពីថ្នាក់លើ ត្រូវគោរពតាមបញ្ជាពីថ្នាក់លើទេ?

**ឆ៖** បាទ ក្រុមខ្ញុំប្រាំមួយនាក់នេះគឺទទួលបញ្ជាពីមេបញ្ជាការកងវរៈសេនាធំ១៣ ឱ្យទៅការពារនៅមន្ទីគុកក្រាំងតាចាន់ មិនមែនជាបុគ្គលិកនៅក្នុងមន្ទីរគុកក្រាំងតាចាន់ទេ។

**ស៖** ខ្ញុំនឹងអានឃ្លាផ្សេងទៀតនៃចម្លើយរបស់អ្នកយាមផ្សេងទៀត ជាភាសាខ្មែរគឺ 00165334

ទៅដល់ 35, ជាភាសាអង់គ្លេស 00433573, ជាភាសាបារាំង 00524323។ នេះជាចម្លើយរបស់ ស៊ឹម គាត់និយាយថា ខ្ញុំសូមដកស្រង់៖ “ខ្ញុំឮគេចាក់ធុងបាស។ សេង តែងតែជាអ្នកចាក់បាស ចាក់ធុងបាស ហើយនិងជាអ្នកជីករណ្តៅ ហើយកប់សពមនុស្សដែលគេសម្លាប់”។ តើគេមានប្រើធុងបាសទេ នៅពេលគេសម្លាប់អ្នកទោសនោះ? ហើយប្រសិនបើប្រើនោះ តើគេដាក់នៅធុងបាសនោះនៅកន្លែងណាដែរ លោកសាក្សី?

**ឆ៖** បាទ សម័យនោះគ្មានធុងបាសទេ សូមជម្រាបលោកគ្មានទេ។

**ស៖** បើតាមលោកដឹង តើអ្នកទោសដូចជា សយ សែន ជាដើម ត្រូវបានគេឲ្យជីករណ្តៅ ហើយនិងកប់សាកសពអ្នកទោសដែលគេសម្លាប់ចោលនោះទេ?

**ឆ៖** បាទ សយ សែន ពេលដែលខ្ញុំចូលទៅដល់ ឃើញគាត់រស់នៅក្នុងហ្នឹងទៅហើយ ប៉ុន្តែមិនដឹងជាជាប់ គាត់ជាប់ពន្ធនាគារហ្នឹងប៉ុន្មានឆ្នាំមកទេ គឺខ្ញុំអត់ដឹងទេ។ ហើយតួនាទីរបស់ សយ សែន ហ្នឹង ក៏ខ្ញុំអត់ដឹងដែរ។ ព្រោះ សយ សែន ហ្នឹង គាត់នៅកន្លែងហ្នឹងយូរហើយ មិនដឹងជាប៉ុន្មានជំនាន់មកហើយទេ ជំនាន់អ្នកដឹកនាំក្នុងហ្នឹង។ ប៉ុន្មានជំនាន់ ខ្ញុំអត់ដឹងទេ។

[១១:១១:៥៣]

**ស៖** ខ្ញុំនឹងអានសម្រង់ផ្សេងទៀត។ នៅកងការពារហ្នឹងដែរ នៅទំព័រដដែល គាត់និយាយអំពីឧបករណ៍សម្រាប់សម្លាប់អ្នកទោស។ ខ្ញុំសូមដកស្រង់៖ “នៅពេលដែលគេសម្លាប់នោះ គេប្រើដំបងឫស្សី ប្រើចប ហើយមានកាំបិតអារកជាដើម”។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងគេ តើគេទុកដាក់របស់របរ ឬក៏ឧបករណ៍សម្រាប់ធ្វើបាបអ្នកទោសហ្នឹងនៅកន្លែងណាដែរលោកសាក្សី នៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។ មិនដឹងគេទុកដាក់ ឬលាក់នៅកន្លែងណា អត់បានដែលឃើញទេ។

**ស៖** តើក្រុមរបស់លោកមានអាវុធទេ?

**ឆ៖** បាទ ក្រុមរបស់ខ្ញុំមានអាវុធ កាំភ្លើងអាកា កាំភ្លើងអឹមសី និងកាំភ្លើងសេកាសេ។

**ស៖** នៅមន្ទីរក្រាំងតាចាន់ តើមានកន្លែងណាមួយដែលគេទុកដាក់អាវុធទាំងអស់ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ ដឹងតែក្រុមខ្ញុំ កងខ្ញុំប្រាំមួយនាក់ គឺមានកាំភ្លើងប្រាំមួយដើម ប៉ុន្តែខាងក្នុងរបស់គុកហ្នឹង គឺខ្ញុំអត់ដឹងគេដាក់ទុកត្រង់ណាទេ។ បើកងខ្ញុំប្រាំមួយនាក់ហ្នឹង គឺម្នាក់មួយដើម គឺកាន់ជាប់រៀងរាល់ថ្ងៃតែម្តង ទាំងយប់ទាំងថ្ងៃ។

[១១:១៤:០៣]

**ស៖** មុននឹងបញ្ចប់ការសួរសំណួរ លោកសាក្សី លោក សយ សែន បាននិយាយអំពីតួនាទីរបស់លោកនៅក្នុងគុក។ ដូច្នេះ ខ្ញុំចង់អានឃ្លាមួយ ហើយនិងឲ្យលោកឆ្លើយតប គឺកំណត់ហេតុ E319.1.25 គឺចម្លើយ១០៥ និង១០៦។ សយ សែន គេសួរសំណួរគាត់ "តើឌុចតូចធ្វើអ្វី?" គាត់ឆ្លើយថា "ឌុចតូចជាអ្នកវាយអង្គុលីលេខ ក៏ប៉ុន្តែគាត់ក៏ជាអ្នកសម្លាប់អ្នកទោសដែរ ហើយគាត់ក៏ជាអ្នកសរសេររបាយ-ការណ៍នៅថ្ងៃបន្ទាប់" ហើយគេសួរគាត់ទៀតថា "តើលោកឃើញ ឌុច តូច សម្លាប់ដោយផ្ទាល់ភ្នែកទេ?" ហើយគាត់ឆ្លើយថា "ខ្ញុំឃើញញឹកញាប់ណាស់។ មុនពេលសម្លាប់ស្ត្រីនោះ គាត់ប្រាប់ថា ឲ្យស្រាតខោអាវទៀតផង"។ លោកសាក្សី នៅពេលដែលមានអ្នកទោសច្រើនដែលត្រូវសម្លាប់ចោល តើកងរបស់លោកនោះ ធ្លាប់ទទួលបញ្ជាឲ្យចូលរួមនៅក្នុងការសម្លាប់អ្នកទោសទាំងអស់នោះទេ?

**ឆ៖** បាទ ពេលដែលមានគេសម្លាប់មនុស្ស កងការពាររបស់ខ្ញុំគឺការពារជុំវិញបរិវេណ។ មិនអាចចូលមកនៅក្នុងបរិវេណដែលគេសម្លាប់ហ្នឹងបានទេ។ ហើយត្រង់ដែលចម្លើយឆ្លើយថា ខ្ញុំបានទៅសម្លាប់មនុស្សនោះគឺ ខ្ញុំមិនអាចឆ្លើយបានទេ។

**ស៖** លោកសាក្សី ស៊ឹម ជាសមាជិកកងការពារនៅក្នុងក្រុមលោកដែរ។ គាត់បានឆ្លើយនៅ--ជូនថា នៅក្នុងឯកសារដដែល។ "សួរ៖ គេសម្លាប់អ្នកទោសម្តងប៉ុន្មាននាក់ដែរ? ចម្លើយ៖ លើសពី ១០០ទៀត ជួនកាលក៏ដល់២០០នាក់ក៏មាន។ ជួនកាលនោះ គេនាំអ្នកទោសយកទៅសម្លាប់នោះ មានទាំងក្មេង មានទាំងមនុស្សធំ។ សែន ដែលជាអ្នកទោសនៅទីនោះ គឺដឹងច្បាស់ណាស់។ សូមបញ្ចប់ការដកស្រង់។ មានអ្នកយាមម្នាក់ផ្សេងទៀត បានឆ្លើយនៅក្នុងឯកសារ E319.1.23 នេះជាកំណត់ហេតុស្តាប់ចម្លើយ។ ចម្លើយទី៩០៖ គាត់ឆ្លើយថាមានគេសម្លាប់ទាំងកុមារក្មេងៗទៀត នៅក្រាំងតាចាន់។ អ្នកទោសដែលត្រូវបានសម្លាប់នៅក្រាំងតាចាន់ តើមានទាំងកុមារដែរឬទេ?

**ឆ៖** បាទ សំណួរនេះ ពិតប្រាកដមែន។ ប៉ុន្តែ ខ្ញុំមិនអាចចាំបានថាមានកុមារប៉ុន្មាននាក់ ឬមនុស្សស្រីប៉ុន្មាននាក់ ប្រុសប៉ុន្មាននាក់ទេ។ គឺមិនបានដឹងទេ ប៉ុន្តែពិតជាមានកុមារមែន។

**ស៖** សំណួរចុងក្រោយ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ខ្ញុំសូមយោងទៅលើឯកសារ E1/257.1 នៅម៉ោង១០:៤០នាទី គាត់ថាលោកជាអ្នកយាមដែលនៅ -- ដែលមានវត្តមាននៅពេលដែលគេ ដែលពេលនោះគឺ សែន និង ស៊ឹម សម្លាប់ក្មេងពីរនាក់។ ក្មេងតូចមួយមានអាយុប្រហាក់ប្រហែល ៣ ទៅ៤ឆ្នាំ ហើយក្មេងម្នាក់ទៀត ៥ទៅ៦ឆ្នាំ។ ហើយនៅថ្ងៃទី០៤ ខែកុម្ភៈ នៅម៉ោង១៣:៣៧នាទី សយ

សែន គាត់បានរៀបរាប់អំពីការសម្លាប់។ គាត់ថា មានរណ្តៅតូចមួយនៅខាងជើងដើមត្នោត -- នៅខាងត្បូងដើមត្នោត ហើយគេសម្លាប់កូនក្មេងតូចនោះបោកទៅនឹងដើមត្នោត។ ហើយបន្ទាប់មកនាំកុមាររាងធំបន្តិចនោះ យកចបវាយកញ្ចឹងកឲ្យស្លាប់។

[១១:១៨:៤៩]

លោកសាក្សី អ៊ីចឹងតើលោកមានអ្វីចង់និយាយទេ ពាក់ព័ន្ធទៅនឹងការសម្លាប់ក្មេងទាំងពីរនាក់នេះនៅក្រាំតាចាន់?

**ឆ៖** បាទ អំពីបញ្ហាសម្លាប់នៅក្រាំងតាចាន់នេះ ខ្ញុំមិនបានឃើញផ្ទាល់ភ្នែក ហើយក៏មិនអាចសន្និដ្ឋានបានថា តើគេសម្លាប់ដោយវិធីណាទេ។ ប៉ុន្តែបើសិនជាគេបាញ់ គឺអត់មានឮទេ ព្រោះកងខ្ញុំ កាន់កាំភ្លើងទាំងអស់។ ហើយបើសិនជាគេសម្លាប់ដោយវាយ ឬត្បូងចបអីនោះ ឬអីនោះ នេះទើបវាមានការស្លាប់ហ្នឹងស្ងាត់ស្ងៀមបំផុត អត់មានសូរក្នុងក្លាំងអីទេ។ ហើយខ្ញុំជឿថា គេសម្លាប់កុមារសម្លាប់អីនេះតាមវិធីផ្សេងៗ ប៉ុន្តែខ្ញុំមិនដែលបានឃើញផ្ទាល់ឃើញ នឹងភ្នែកខ្ញុំទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ខ្ញុំបានហួស ចំណាយពេលលើសបន្តិចហើយ មុននឹងពេលលោកផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ! អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញចោលចំពោះសាក្សីរូបនេះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ ជាដំបូង ខ្ញុំបាទសូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមជម្រាបសួរដល់អ្នកដែលចូលរួមទស្សនានៅទីនេះ ហើយអ្នកដែលបានចូលរួមទស្សនាតាមបណ្តាញផ្សព្វផ្សាយនានា។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ហើយនិងជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះផងដែរ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះ ខ្ញុំបាទសូមជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងធ្វើការសួរបន្តិចទៀតនេះ ដែល

ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនដែលលោកបានជួបប្រទេសនៅក្នុងរយៈកាលឆ្នាំ១៩៧៥ ដល់៧៩។សំណួរដំបូង គឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកថា លោកជាអ្នកយាមនៅខាងក្រោមន្ទីរអប់រំក្រាំងតាចាន់នេះមានគ្នាប្រាំមួយនាក់។ សួរថា តើនៅពេលដែលលោកកំពុងតែយាម និងពេលដែលគេបញ្ជូនអ្នកទោសមក តើលោកនៅទទួលកន្លែងណា?

**លោក ស្រី ថន៖**

**ធ៖** បាទ សំណួរសួរអំពីចាប់ពីឆ្នាំ១៩៧៥ មក គឺខ្ញុំអត់បានទៅនៅក្រាំងតាចាន់ទេ។ ឆ្នាំ១៩៧៦ ចុងឆ្នាំ៧៦ គេបញ្ជូនខ្ញុំពីកងទ័ព ពីកងឯកភាពស្រុក ចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៦ គេឲ្យខ្ញុំទៅយាមនៅខាងលិចគុកក្រាំងតាចាន់ ចម្ងាយដីប្រហែល១គីឡូម៉ែត្រ។ គេអត់ទាន់ឲ្យខ្ញុំចូលទៅនៅមន្ទីរអប់រំស្រុកត្រាំកក់នោះទេ -- មន្ទីរក្រាំងតាចាន់ហ្នឹងទេ។

[១១:២៣:២៣]

**ស៖** អ៊ីចឹងមានន័យថា លោកសាក្សីអត់បានដឹងពីព័ត៌មានការបញ្ជូនអ្នកទោសមកតាមរយៈដែលលោកបានយាមហ្នឹង គឺថាពេលយាម យើងយាមជុំវិញ។ ចុះពេលនៅពេលដែលគេបញ្ជូនអ្នកទោសមក តើលោកបានឃើញទេ បានដឹងទេ នៅពេលនោះ?

**ធ៖** បាទ ពេលនោះយាម មិនមែននៅយាម គឺចាំទទួលអ្នកទោស ប៉ុន្តែគ្រាន់តែយើងមិនមែនយើងយាមជុំវិញគុកទេ គឺយាម យើងធ្វើរោងមួយ មានរោងមួយនៅចម្ងាយប្រហែល១គីឡូ ពីកន្លែងមន្ទីរក្រាំងតាចាន់ហ្នឹង។ ហើយក្រុមខ្ញុំប្រាំមួយនាក់ហ្នឹង គឺនៅកន្លែងហ្នឹង នៅជិតមួយឆ្នាំសម្រាប់ទទួលអ្នកទោសហ្នឹង គេបញ្ជូនពីតាមភូមិ តាមឃុំមក គេយកមកឲ្យកន្លែងស្នាក់ការខ្ញុំហ្នឹង និងបញ្ជូនមកដល់កន្លែងគុកគេតែម្តង បាទ។

**ស៖** អរគុណ។ តើអ្នកណាដែលយកអ្នកទោសហ្នឹងយកមកជូនខាងក្រុមលោកពូហ្នឹង តើជាកងទ័ព ឬមួយជាមួយឈ្លប ឬមួយជាមនុស្សយ៉ាងម៉េចដែលបញ្ជូនទ័ពមកហ្នឹង បញ្ជូនអ្នកទោសមកហ្នឹង?

**ធ៖** បាទ ឈ្លប និងកងទ័ពដែលគេចាប់បញ្ជូនមក។

**ស៖** សូមទោស។ អ៊ីចេះ! ខ្ញុំចង់សួរថាអ្នកដែលចាប់ អ្នកដែលនាំគេមកហ្នឹង តើជានរណា?

**ធ៖** បាទ ខ្ញុំមិនស្គាល់ទេ។ នាំមកមានតែគ្រាន់តែមានគេមានតួនាទីជាកងទ័ព ឬៗឈ្លប មានតែពីរ១មុខហ្នឹងទេ។ ប៉ុន្តែដល់ទៅឈ្មោះមិនស្គាល់ទេ មិនដឹងជានរណាទេ មិនអាចស្គាល់គេបានទេ។

[១១:២៥:៤៨]

**ស៖** អរគុណ។ តើអ្នកដែលបញ្ជូនមកហ្នឹង ក្នុងមួយថ្ងៃបញ្ជូនមកប៉ុន្មាននដង? ហើយលោកសាក្សីបានឃើញអ្នកដែលបញ្ជូនមកហ្នឹង អ្នកដែលនាំអ្នកទោសមកហ្នឹង មនុស្សដដែលៗហ្នឹង ឬមួយដូរៗមុខ?

**ឆ៖** បាទ ពេលគេនាំមកនេះមិនមែនមនុស្សដដែលទេ មានផ្លាស់ប្តូរគ្រប់មនុស្ស មិនមែនមនុស្សដដែលទេ ប៉ុន្តែក៏មិនមែនជាប់រៀងរាល់ថ្ងៃដែរ។ ជួនកាលនៅពេលខ្លះ មួយខែក៏គ្មានម្នាក់បញ្ជូនមកក៏មានដែរ ជួនកាលមួយថ្ងៃ បួន ដប់នាក់ ម្ភៃនាក់ ក៏មានដែរ។ អ៊ីចឹងវាអត់ទៀងទាត់ថាមួយថ្ងៃប៉ុន្មានក៏វាអត់មានច្បាស់ពិតប្រាកដ វាមានដោយថ្ងៃ ជួនកាលមួយខែហ្នឹងអត់មានសោះ ក៏មានដែរបាទ។

**ស៖** តាមលោកសាក្សីបានជួបប្រទះ ថាតើពេលដែលបានទទួលអ្នកទោសមកហ្នឹង ភាគច្រើនជាបុរស ឬមួយភាគច្រើនជាស្ត្រី? ហើយក្នុងនោះមានកុមារក្មេងៗតូចៗដែរឬអត់?

**ឆ៖** បាទ អ្នកទោស គេបញ្ជូនមកនោះ ភាគច្រើនជាបុរស ស្ត្រីតិច ក្មេងក៏តិចដែរ ភាគច្រើនបំផុត គឺបុរស។

**ស៖** តើអ្នកទោសដែលគេបញ្ជូនមកហ្នឹងក្នុងសភាពយ៉ាងដូចម្តេច? មានន័យថា គេចងក្រៀកគាត់ ឬមួយយ៉ាងដូចម្តេច? ហើយចំពោះក្មេងៗគេធ្វើយ៉ាងម៉េចដែរ?

**ឆ៖** បាទ គេបញ្ជូនមក គេចងស្លាបសេកទៅក្រោយក្នុងសភាពមួយមិនឲ្យអ្នកដែលគេចាប់ហ្នឹងមិនឲ្យរត់រួចតែម្តង។ ក្មេងគេឲ្យដើរតាមក្រោយ។

**ស៖** ចុះនៅពេលណាដែល -- ពេលណាដែលលោកបានចាំ? គឺថាឈប់យាមខាងក្រៅហ្នឹងហើយចូលទៅខាងក្នុងដែលធ្វើការងារដែលពាក់ព័ន្ធនឹងការវាយអង្គុលីលេខ?

**ឆ៖** បាទ ពេលដែលចេញពីកន្លែងយាមពីខាងក្រៅ គេយកទៅដាក់ឲ្យនៅក្បែររបងនៅក្នុងគុកហ្នឹងមួយរយៈពេល។ ក្រោយមកគេដឹងថាខ្ញុំចេះអក្សរតិចតួច ចេះវាយអង្គុលីលេខខ្លះ គេមិនមែនប្រគល់តួនាទីហ្នឹងឲ្យខ្ញុំទេ ប៉ុន្តែគេគ្រាន់តែជា ឲ្យជំនួសគេមួយភ្លែតៗពេលណាដែលប្រធានគេមិននៅតែប៉ុណ្ណឹងទេ។

**ស៖** ពេលដែលលោកចូលទៅ លោកសាក្សីចូលទៅខាងក្នុងហ្នឹង តើចូលទាំងប្រាំមួយនាក់ហ្នឹង ឬមួយចូលតែម្នាក់ឯង ឬមួយមានប៉ុន្មាននាក់ដែលចូលទៅក្នុងហ្នឹងបាទ?

[១១:៣០:០៨]

**ឆ៖** បាទ ចូលទៅទាំងប្រាំមួយនាក់។

**ស៖** អរគុណ។ តើនៅកន្លែងដែលលោកវាយអង្គុលីលេខ តើនៅក្នុងនោះមានម៉ាស៊ីនវាយអង្គុលីលេខហ្នឹង ប៉ុន្មានដែរ?

**ឆ៖** បាទមានតែមួយទេ។

**ស៖** តើអ្នកដែលវាយអង្គុលីលេខមានប៉ុន្មាននាក់?

**ឆ៖** បើសិនជាតាមខ្ញុំធ្លាប់ឃើញគេវាយ មានតែពីរនាក់ទេ គឺ អាន់ និង ឌុច ហ្នឹងទេ។ ដោយឡែកតែពេលណាដែលគេមិននៅ ម្នាក់គេមិននៅ គេមានឯកសារអីតិចតួចស្តួចស្តើងហ្នឹង បានគេហៅខ្ញុំឱ្យទៅជួយវាយគេ។ បាទ មានតែពីរនាក់ហ្នឹងទេ មានតែ ឌុច ហើយនិង អាន់ ជាអ្នកវាយ។ ខ្ញុំជាបន្ទាប់បន្សំទេ។

**ស៖** តើលោកសាក្សីបានចាំទេ ថាតើឯកសារអ្វីខ្លះដែលលោកបានទទួលយកមកវាយជាលក្ខណៈអង្គុលីលេខនេះ?

**ឆ៖** បាទខ្ញុំមិនចាំអស់ទេ។ ប៉ុន្តែបើខ្ញុំធ្លាប់អង្គុលីលេខនេះ គ្រាន់តែមានឈ្មោះអ្នកទោសដែលគេបញ្ជូនមកមានចំនួនប៉ុន្មាននាក់នៅក្នុងមួយខែគេសរុបអ្នកទោសចូលមកប៉ុន្មានអីចឹងទៅ។ ហ្នឹង គេវាយជាអង្គុលីលេខហ្នឹង។ ប៉ុន្តែយ៉ាងម៉េចទៀតនោះគឺអត់មានទេ។

[១១:៣២:៣៤]

**ស៖** អរគុណ។ ចុះនៅពេលដែលលោកសាក្សីបានវាយអង្គុលីលេខហើយ តើមានអ្នកណាដែលត្រួតពិនិត្យទៅលើការវាយរបស់លោក ថាតើខុស ឬត្រូវដែរឬអត់?

**ឆ៖** អត់មានទេ ពេលដែលវាយអង្គុលីលេខហ្នឹងហើយ វាយអង្គុលីហើយ ក្រដាសដែលចម្លងចេញពីអក្សរដែលគេសរសេរដៃគឺខ្ញុំទុកលើតុហ្នឹង។ ប៉ុន្តែកន្លែងគេហ្នឹង គ្មានៗមនុស្សទី៣ហ្នឹង ចូលទេ មានតែពីរនាក់ទេ គឺ អាន់ និង ឌុច។ គេទៅគេពិនិត្យ ៗលើឯកសារដែលយើងវាយចម្លងពីគេហ្នឹងបាទ។

**ស៖** បន្ទាប់មកគេបញ្ជូនឱ្យលោកសាក្សីកែតម្រូវឡើងវិញ ឬមួយយ៉ាងម៉េច?

**ឆ៖** អត់ទេ។ ពេលកាលណាវាយហើយគឺទុកហ្នឹង បើសិនជាខុសគេកែខ្លួនគេ។ គេជួសជាអក្សរដៃឬក៏គេសរសេរអីទៀត គេអត់មានហៅខ្ញុំមកពីរដងទេ។

**ស៖** អរគុណ។ ខ្ញុំពិនិត្យមើលលើចម្លើយរបស់លោក គឺលេខ D232/93។ ចម្លើយលេខ៣២ ខ្ញុំសូមអាន។ ចម្លើយហ្នឹងគឺពាក់ព័ន្ធនឹងថា "ជាសៀវភៅដែលមានកម្រាស់ប្រហែល ១០ ឬ ២០សន្លឹក

គឺជាសៀវភៅសរសេរសម្រាប់ក្មេងៗរៀន"។ អម្បាញ់ខ្ញុំបានស្តាប់លោកខាងសហព្រះរាជអាជ្ញាបានសួរអំពីបញ្ហានេះ ហើយលោកបានឆ្លើយថា មិនមែនជាក្រដាសសៀវភៅនេះទេ ប៉ុន្តែតាមចម្លើយរបស់លោកកាលពីមុននោះគឺបានលើកឡើងនូវចំណុច៣២នេះថាដូច្នេះ។ មានន័យថា ជាសៀវភៅដែលមានកម្រាស់ ឬ២០ ឬ១០ ទៅ ២០ - ៣០សន្លឹកណាំ! ដែលសរសេរលើហ្នឹងហើយ យកមកឲ្យលោកវាយអង្គុលីលេខ។ តើចំណុចនេះ លោកៗថាម៉េចដែរបាទ?

**ឆ៖** បាទសៀវភៅនេះ មិនមែនសៀវភៅវាយអង្គុលីលេខទេ ហើយសៀវភៅនេះ មិនមែនសៀវភៅកំណត់ហេតុដែលគេកត់ឲ្យខ្ញុំសរសេរ និងវាយអង្គុលីលេខទេ។ ពេលដែលមុននឹងវាយអង្គុលីលេខគេសរសេរនឹងក្រដាសរ៉ាមៗអ៊ីចឹង គេសរសេរហើយអ៊ីចឹងជាអក្សរដាក់តាមដៃយើង បានគេយកមកឲ្យខ្ញុំវាយអង្គុលី។ គ្មានសរសេរក្នុងសៀវភៅទេ។ សៀវភៅនេះ មានទម្រង់គ្រាន់តែកត់ចំនួនអ្នកទោសទេដែលចេញចូលនៅក្នុងគុកហ្នឹងទេ បាទ។

**សៈ** មានៗន័យថាសៀវភៅហ្នឹងកត់ចំនួនអ្នកទោស គេអត់ឲ្យយក -- អត់ឲ្យមកលោកសាក្សីដើម្បីវាយទេ?

**ឆ៖** បាទ អត់ទេ។

[១១:៣៦:៣៤]

**សៈ** អរគុណ។ ចុះនៅពេលដែលលោកចូលទៅធ្វើការនៅទីនោះ ទៅវាយអង្គុលីលេខនៅទីនោះដែលឃើញសំបុត្រដែលចារលើប៊ិកក្រហមថា បញ្ជូនទៅថ្នាក់ណាៗទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលឃើញទេ។

**សៈ** ខ្ញុំសូមត្រឡប់ទៅខាង -- អម្បាញ់មិញ លោកបានឆ្លើយថា នៅពេលដែលលោកយាមកាមនៅខាងក្រៅហ្នឹង គឺនៅក្នុងមន្ទីរសន្តិសុខអ្នកដែលគ្រប់គ្រងក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹង មិនអាចបញ្ជាលោកបានទេ គឺមានតែខាងកងពលទើបបញ្ជា។ អ៊ីចឹង ខ្ញុំសួរថាតើនៅក្នុងចំណោមលោកប្រាំមួយនាក់ហ្នឹង តើមានអ្នកណាជាប្រធានដែរឬទេ? បើមិនមានជាប្រធាននៅក្នុងប្រាំមួយនាក់ហ្នឹងទេ តើមានអ្នកណាដែលជាតំណាងទំនាក់ទំនងមកខាងមន្ទីរសន្តិសុខក្រាំងតាចាន់ ឬមួយទំនាក់ទំនងទៅខាងកងពលរបស់លោក?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ប្រាប់លោកជ្រាបថា ក្រុមខ្ញុំប្រាំមួយនាក់នេះ មិនមែនជាបុគ្គលិកមន្ទីរគុកក្រាំងតាចាន់ទេ គឺជាងកងឯកភាពស្រុកដែលគេបញ្ជូនទៅឲ្យការពារនៅមន្ទីរគុកក្រាំងតាចាន់។

ហើយពេលដែលមានការ គេហៅប្រើ អាហ្នឹងប្រធានគេ – ប្រធានមានតែពីរនាក់ទេ គឺ អាន់ និង ឌុច ហ្នឹង។ គេបញ្ជាយើងឲ្យយាមត្រង់ណា គឺយាមនៅត្រង់ហ្នឹង ប៉ុន្តែបើផែនការដក ឬយកយើងចេញទៅវាលវិញ មានតែកងយើងទេ មានតែមេបញ្ជាការកងទ័ពរបស់យើងទេ។ អ្នកនៅក្នុងអស់ហ្នឹង គ្មានតួនាទីអីបញ្ជាយើងទេ មានតែមេបញ្ជាការកងទ័ពរបស់យើងៗ – កងពល២១០ បាទ។

**ស៖** បាទអរគុណ ថាតើនៅពេលដែលយាមនុង ដែលមានជួបបញ្ហាអ្វីដែលកើតឡើងទេ ដូចជាអ្នកទោសរត់ ដូចជាមានបញ្ហាអីផ្សេងៗទៀត? តើនៅពេលមានបញ្ហាហ្នឹង តើនរណាម្នាក់ដែលជាអ្នករាយការណ៍? តើរាយការណ៍ទៅខាងណា?

**ឆ៖** បាទ ខ្ញុំពេលដែលចូលទៅនៅក្នុងហ្នឹង មិនដែលមានអ្នកទោសរត់រួចទេ។ ហើយបើសិនជាយើង ឧទាហរណ៍ថាបើមានបញ្ហាអីមួយនៅខាងក្រៅ គឺយើងរាយការណ៍ទៅឲ្យប្រធានគុក បើមានបញ្ហា យើងរាយការណ៍ទៅឲ្យ ឡេង និង អាន់។

[១១:៤០:១៨]

**ប្រធានអង្គជំនុំ៖**

មេធាវីអស់សំណួរឬនៅ? បើនៅ សំណួរច្រើនទេ?

**លោក ឡោ ជុនធី៖**

លោកប្រធានអាច១៥នាទីទៀត អាចសុំបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ ហើយអង្គជំនុំជម្រះនឹងបន្ថែមជូនលោក៨នាទីទៀត ដោយពេលវេលាជំទាស់ហ្នឹង ១៥នាទី ឥឡូវលើស៧-៨នាទីហើយ អ៊ីចឹងនៅសល់តែ ៨នាទីទៀតប៉ុណ្ណោះ។

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងសាមសិបនាទីនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ រួមទាំងមេធាវីប្រឹក្សារបស់គាត់ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមបន្ទប់សាលសវនាការនេះ និងឲ្យបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤១នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីបន្ត។

**សួរដោយលោក ឡោ ជុនធី៖**

បាទ សូមអរគុណ ហើយសូមជម្រាបសួរសាជាថ្មី។

**ស៖** សុំលោកសាក្សីបំភ្លឺបន្ថែមនូវពាក់ព័ន្ធនៅចំណុចថា តើនៅក្នុងអ្វីដែលលោកបានវាយអង្គុលីលេខនោះថា តើអ្នកដែលយកក្រដាសដែលសរសេរជាដៃហ្នឹង យកមកឲ្យលោកផ្ទាល់ដៃតែម្តង ឬមួយគេទុកនៅកន្លែងណាដែលឲ្យលោកធ្វើការងារហ្នឹង ហើយថាតើលោកធ្វើការងារហ្នឹងមួយថ្ងៃតែម្តង ឬមួយធ្វើតែមួយម៉ោង ពីរម៉ោង ហើយចប់ពីម៉ោងហ្នឹងទៅលោកទៅធ្វើអ្វីផ្សេង? តើលោកធ្វើយ៉ាងម៉េចដែរបាទ?

**ឆ៖** បាទ ពេលគេឲ្យខ្ញុំបាទវ៉ៃអង្គុលីនេះ គឺមួយថ្ងៃប្រហែលជាមិនដល់នឹងកន្លះម៉ោងផង មិនថាដល់មួយម៉ោងទេ។ មួយភ្លែតហ្នឹងព្រោះឯកសារវាខ្លីៗ ឈ្មោះគាត់បន្តិចៗហ្នឹង។ ហើយមិនមែនជាទៀងទាត់រៀងរាល់ថ្ងៃទេ។ ជួនកាលប្អូនដប់ថ្ងៃ កន្លះខែណោះបានខ្ញុំមានវត្តមានខ្ញុំម្តងហ្នឹង។ ហើយក្រៅពីនោះ ពេលចប់ការងារខាងវ៉ៃហ្នឹងហើយ ខ្ញុំទៅចូលកន្លែងរោងយាមរបស់ខ្ញុំវិញ។

**ស៖** ខ្ញុំចង់ដឹងថា ពីរឿងពាក់ព័ន្ធនឹងការបញ្ជូនអ្នកទោសមកម្តងទៀតដោយយើងចង់បញ្ជាក់ថា

តើការបញ្ជូនអ្នកទោសមកហ្នឹង បញ្ជូនមកហើយ ពេលដែលលោកនៅខាងក្នុងហ្នឹង បានធ្វើការងារអីដែលក្រៅពីវៃអង្គុលីលេខហ្នឹង គឺបានទទួលអ្នកទោស ឬមួយនាំអ្នកទោសទៅដាក់ក្នុងកន្លែងគុកហ្នឹងដែរអត់ បាទ?

**ឆ៖** បាទ ពេលដែលខ្ញុំវាយអង្គុលីលេខហ្នឹង គឺខ្ញុំអត់បាននាំអ្នកទោសចូលមកទេ។ អ្នកទោសគេនាំចូលពីរបងខាងកើត និងខាងលិចហ្នឹង គ្រាន់ណាបើមកពីខាងកើតគឺអ្នកយាមពីខាងកើតគេនាំចូលមក គេប្រគល់ឲ្យអ្នកនៅក្នុងគុកហ្នឹងជាអ្នកបញ្ចូល ហើយបើនាំពីខាងលិចគឺអ្នកនាំទ្វារមាត់ច្រកពីខាងលិច គេនាំបញ្ចូលមក។ អ៊ីចឹង តួនាទីរបស់អ្នកយាមនៅកន្លែងហ្នឹង ដើម្បីនាំអ្នកទោសពីមាត់ទ្វារមកចូលដល់កន្លែងគុក គឺមានអ្នកប្រចាំការនៅក្នុងគុកហ្នឹង គេអ្នករៀបចំនៅក្នុងហ្នឹង។ យើងចេញទៅហើយយកប្រគល់ឲ្យគេហើយ យើងចេញទៅវិញ។

[១៣:៣៦:៥៦]

**ស៖** បាទ អរគុណ។ ចុះតើលោកបានដឹងថា តើការរៀបចំអ្នកទោសនៅក្នុងអគារទាំងពីរហ្នឹង តើគេមានបែងចែកកុមារផ្សេង ស្ត្រីផ្សេង បុរសផ្សេងទេ បាទ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** បាទ អរគុណ។ ចុះលោកបានដឹងថា តើរបបអាហាររបស់អ្នកទោសទាំងនោះ យ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ របបអាហារវិញ បើតាមខ្ញុំឃើញគឺអ្នកទោសហូបយ៉ាងច្រើនបំផុត ម្នាក់មួយត្រឡោកទេ។ គ្មានចានទេ។ មានតែត្រឡោក។

**ស៖** តើលោកសាក្សីដឹងថា តើត្រឡោកហ្នឹងប្រើប្រាស់សម្រាប់ដាក់បាយ ហើយសម្រាប់ប្រើអីទៀតដែរអត់ទេ បាទ?

**ឆ៖** បាទ ត្រឡោកនេះ សម្រាប់ដាក់បាយបបរ និងសម្លហ្នឹងលាយជាមួយគ្នាហ្នឹងក្នុងមួយត្រឡោកៗហ្នឹង។

**ស៖** ចុះខាងលោកសាក្សីវិញ តើរបបអាហារហ្នឹង យ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ ខ្ញុំ ក្រុមខ្ញុំហូបបាយនៅខាងក្រៅនេះ អត់មានពាក់ព័ន្ធនឹងឡូកឡំជាមួយហ្នឹងអ្នកដែលជាប់គុកខាងក្នុងទេ។ អាហារហូបចុកវិញ ក៏មិនគ្រប់គ្រាន់ដែរ។ ប៉ុន្តែវាប្រសើរជាអ្នកដែលជាប់គុកនៅខាងក្នុង។

**ស៖** អរគុណ។ តើលោកសាក្សីស្គាល់ឈ្មោះ ឌុច ដែរឬទេ?

**ឆ៖** បាទ ស្គាល់។

[១៣:៣៩:៥០]

**ស៖** តើលោកធ្លាប់មានការប្រាស្រ័យទាក់ទងជាមួយគាត់ដែរឬទេ? ហើយធ្លាប់ពិសាបាយជាមួយគ្នាទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តើលោកមានដឹងថាតើនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ទាំងមូល គេមានបុគ្គលិកប៉ុន្មានដែរ? ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន? មានៗដឹងទេបាទ?

**ឆ៖** បាទ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ គឺខ្ញុំអត់ដឹងចំនួនគេប៉ុន្មានពិតប្រាកដទេ។

**ស៖** តើលោកមានបាន -- លោកសាក្សីមានបានប្រទះឃើញអ្នកទោសម្នាក់ ឬមួយច្រើននាក់ដែលគាត់នៅក្នុងហ្នឹង គាត់អាចដើរចល័តក្នុងហ្នឹងបាន ដូចជាទៅចូលបោសសម្អាតទៅកន្លែងនានាដូចជាកន្លែងលោកវ៉ៃអង្គុយលីលេខនោះ មានដឹងទេបាទ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញមានឈ្មោះ តាដាំ ម្នាក់។ ហ្នឹងគេឲ្យដាំបាយនៅខាងក្រៅគឺ ហើយនិងដើរសម្អាត ដើរបោសអីហ្នឹងគឺមានឈ្មោះ តាដាំ ហ្នឹង។

**ស៖** តើលោកសាក្សីបាន ដែលបានជួបប្រទះទេថា ក្នុងមួយរយៈកាលដែលធ្វើការនៅទីនោះមានការប្តេជ្ញាចិត្ត គេហៅថា “រៀបការ” នៅទីនោះដែរទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** មុននេះបន្តិច គឺមានខាងសហព្រះរាជអាជ្ញាបានជម្រាបសួរទៅលោកថា ពាក់ព័ន្ធទៅនឹងពេលដែលគេសម្លាប់ គឺគេមានចាក់បំពងសំឡេងដាក់ទៅកន្លែងអ្នកទោស។ តើមានការចាក់បំពងសំឡេងតាមមីក្រូ ដែលហៅថា “មីក្រូផ្កាត្រកួន” ទេបាទ?

**ឆ៖** បាទ គ្មានទេ។

**ស៖** តើនៅក្នុងរយៈពេលដែលលោកសាក្សីធ្វើនៅទីនោះ បានជួបប្រទះនឹងស្ត្រីពីរនាក់ ដែលជាស្ត្រីខាងកងចល័តហ្នឹង គេបញ្ជូនមកទីនេះ។ តើលោកបានជួបប្រទះពួកគាត់ទេ? ហើយដឹងថា ពួកគាត់នឹងក្លាយទៅជាអ្វីទៅថ្ងៃក្រោយទៅទៀត?

[១៣:៤៣:៥៨]

**ឆ៖** បាទ ខ្ញុំអត់បានជួប ហើយអត់បានស្គាល់ទេ។

**ស៖** ចុះលោកបានវាយអង្គុលីលេខ តើលោកមានបានប្រទះឃើញឈ្មោះស្ត្រីពីរនាក់ហ្នឹងដែរទេ?

**ឆ៖** បាទ អត់ដឹងទេ។ ខ្ញុំអត់ចាប់អារម្មណ៍ផង ហើយអត់ចាំទៀត។ មិនដឹងស្ត្រីហ្នឹងឈ្មោះអីផង ខ្ញុំអត់ចាំ។ ហើយក៏មិនចាំទៀត វាឈ្មោះវាវែងឆ្ងាយពេកហើយ។ បាទ អត់ចាំ។

**ស៖** លោកបានឆ្លើយថា បានឃើញការធ្វើទារុណកម្មអ្នកទោស។ តើកាលដែលឃើញហ្នឹង ឃើញនៅចំណុចណាដែរបាទ?

**ឆ៖** បាទ សំណួរដែលសួរថា បានឃើញនេះគឺសំណួរនេះមិនពិតទេ។ ខ្ញុំបានឮសម្រែកដែលគេស្រែកហ្នឹង ខ្ញុំឮ បើថាខ្ញុំឃើញផ្ទាល់ភ្នែកគឺខ្ញុំអត់ឃើញទេ បាទ។

[១៣:៤៥:៥០]

**ស៖** ប្រសិនជាបានឮ តើបានឮចម្ងាយប៉ុន្មាន ដែលយើងឮហ្នឹង គឺឮពីចំណុចណា ឮពីកន្លែងលោកយាម ឬមួយឮពីកន្លែងលោកសាក្សី វាយអង្គុលីលេខ?

**ឆ៖** បាទ កន្លែងខ្ញុំយាម កឮស្នូរដល់ដែរ បើសិនជាអ្នកទោសនោះស្រែកខ្លាំង។ ប៉ុន្តែភាគច្រើនគេមិនសូវឲ្យស្រែកឮប៉ុន្មានទេ។ ដល់នៅជិតបានឮ។ ហើយភាគច្រើន ពេលគេសួរចម្លើយ គឺយើងមិនដែលបានទៅនៅជិតទេ។ បើមុននឹងគេសួរចម្លើយគឺយើងត្រូវនៅចាំទ្វារខាងក្រៅហើយ យើងមិនបានអង្គុយជិតក្នុងហ្នឹងទេ បាទ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំសូមជម្រាបសួរដែរថា ពាក់ព័ន្ធនឹងមាន -- លោកថាមាននីរសារជិះសេអិល មួយខែមកម្តង។ តើអ្នកដែលជិះសេអិលមួយខែមកម្តងហ្នឹង លោកបានជួបមុខផ្ទាល់ទេ?

**ឆ៖** បាទ អ្នកដែលមកនេះ ខ្ញុំមិនមែនឆ្លើយថាមួយខែមកម្តងទេ។ ម្នាក់នេះគឺខ្ញុំឃើញយូរៗមកម្តង។ មិនមែនកំណត់មួយខែម្តងទេ។ ប៉ុន្តែយើងអត់ស្គាល់ឈ្មោះទេ ហើយអត់ស្គាល់មុខគេទៀត គ្រាន់តែឃើញគេជិះចូល។ បើគេចូល គេពាក់មួកជិត ទទូលក្រមាយើងអត់អាចមើលគេស្គាល់ទេ។ ហើយបើស្គាល់មិនដឹងជាពីណា។ មិនស្គាល់ទេ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកសាក្សី។ ហើយសូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តើអស់លោក លោកស្រី ចៅក្រមមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរ

ឬទេ? បើមានសូមអញ្ជើញបាទ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួនសួរបន្តទៅសាក្សីនេះ។

[១៣:៤៨:១១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី លោកបាននិយាយថា លោកត្រូវបានគេដកចេញពីកងវរសេនាធំ១៣ ដើម្បីឲ្យមកការពារនៅក្រាំងតាចាន់។ អ៊ីចឹង ខ្ញុំសួរថាតើឈ្មោះមេរបស់លោក មេរបស់លោកឈ្មោះអ្វីដែរ? ពីព្រោះថា បើតាមលោកឆ្លើយអម្បាញ់មិញ គឺថា ឌុច ក៏មិនមែន តាអាន់ ក៏មិនមែន។ អ៊ីចឹង ឈ្មោះមេរបស់លោកៗ ជាអ្នកណា?

**លោក ស្រី ថន៖**

**ឆ៖** បាទ មេបញ្ជាការរបស់កងពលវរសេនាធំ២១០ កងពលវរសេនាធំ១៣ កងពល២១០។ មេបញ្ជាការរបស់ខ្ញុំស្គាល់គឺ មួយឈ្មោះ ថា និងមួយទៀតឈ្មោះ មាន។

**ស៖** តើលោកទទួលបញ្ជាពីតាថា ហើយនិងតាមាន ហ្នឹងតាមរបៀបណា? ហើយកងវរសេនាធំដែលលោក ដែលស្ថិតនៅនោះ ក្នុងចូលចំណុះហ្នឹងនៅចម្ងាយប៉ុន្មានដែរ ពីមន្ទីរក្រាំងតាចាន់ ហ្នឹងបាទ?

**ឆ៖** បាទ កងពលវរសេនាធំ១៣ គ្មានកន្លែងទីតាំងច្បាស់លាស់ទេ គ្រាន់តែដាក់នៅតាមភូមិប្រជាជន គ្នាប្រហែលជាបីបួនប្រាំនាក់ៗ នៅចម្ងាយពីហ្នឹងប្រហែលជារាប់រយគីឡូ អត់ជិតទេ ឆ្ងាយ។ បើគិតទៅប្រហែលជា៧០ ឬ៨០គីឡូនោះ។ អត់មាននៅជិតក្រាំងតាចាន់ហ្នឹងទេ។

**ស៖** តើលោកទាក់ទងជាមួយនឹងមេរបស់លោកយ៉ាងម៉េចដែរ ដែលគាត់នៅចម្ងាយប្រហែលពី៧០ ទៅ ៨០ គីឡូម៉ែត្រពីក្រាំងតាចាន់ សួរថាទាក់ទងគ្នាយ៉ាងម៉េចដែរ?

**ឆ៖** បាទ មុននឹងគេបញ្ជូនយើងមក គេចែកភារកិច្ចឲ្យយើងហើយស្រេចហើយ អត់មានពេលកំពុងយើងអនុវត្តការងារ ពេលគេប្រគល់ភារកិច្ចឲ្យយើងយាមហ្នឹង គឺយើងគ្មានសិទ្ធិដើរទៅណាទេ ឧទាហរណ៍ថា កំណត់ពីរខែម្ដងគេមកជួបយើង ឬមួយក៏ឲ្យទៅជួបមេបញ្ជាការ ពេលដែលខ្ញុំទៅនៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង ជួបជាមួយមេបានតែម្ដងទេ ព្រោះរយៈពេលតែបួនខែ ឬប្រាំខែប៉ុណ្ណោះ។ ប៉ុន្តែមិនដែលគេមកជួបយើងទេ មានតែយើងទេឡើងទៅជួបគេ។ ប៉ុន្តែដល់គេហៅយើងទៅ។

[១៣:៥១:៣០]

**ស៖** តើលោកបានជួបគាត់នៅពេលណាដែរ?

**ឆ៖** នៅពេល ពេលថ្ងៃ ចូលទៅពេលថ្ងៃ នៅកន្លែងកងពល។

**ស៖** តើហេតុអ្វីក៏លោកដឹងថាត្រូវទីបញ្ជាការកងពល?

**ឆ៖** ពេលដែលខ្ញុំត្រូវទៅ គឺមាននីរសារគេមកហៅយើងទេ។ ជំនាន់នោះគឺអត់មានស្អីទាំងអស់ គឺមាននីរសារមួយ គេមកប្រាប់យើង ឲ្យយើងឡើងទៅជួប។

**ស៖** អ៊ីចឹងបើសិនខ្ញុំសង្ខេបមកវិញ គឺថានៅក្នុងរយៈពេលដែលលោករស់នៅក្រាំងតាចាន់នោះ លោកបានទទួលបញ្ជាតែម្តងទេ គឺបញ្ជាដែលសុំឲ្យលោកទៅកងពល ក្រៅពីថ្ងៃហ្នឹងលោកមិន ពេលមួយហ្នឹងនោះ លោកមិនដែលបានទទួលបញ្ជាមកពីកងពលមកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** ហើយ តាអាន់ និង តាឌុច ហ្នឹងមិនមានសិទ្ធិអីទទួល -- បើចេញបញ្ជាឲ្យលោកទេ ឲ្យលោកធ្វើអ្វីៗនៅក្រាំងតាចាន់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** បើអ៊ីចឹង ចុះហេតុអីបានលោកប្តូរពីអ្នកយាម ហើយម្តងឋានៈ -- ចេញពីអ្នកយាមចូលមកធ្វើជាអ្នកវាយអង្គុលីលេខវិញ។ ខ្ញុំសួរថាអ្នកណាជាអ្នកសម្រេចចេញបញ្ជាឲ្យលោកធ្វើយ៉ាងដូច្នេះ? ចេញពីអ្នកយាម មកជាអ្នកវាយអង្គុលីលេខវិញនេះ។

**ឆ៖** បាទ មិនមែនខ្ញុំចូលជាបុគ្គលិកអ្នកវាយអង្គុលីលេខទេ។ ពេលណាដែលគេអត់ មេគេទាំងពីរនាក់ហ្នឹង នៅមួយអត់មួយ ហើយគេអត់វាយ គេហៅខ្ញុំមកជំនួសគេរយៈពេលខ្លីតែប៉ុណ្ណោះ។ ខ្ញុំមិនជាអ្នកវាយអង្គុលីលេខស្ទាត់ជំនាញទេ។ ប៉ុន្តែគ្រាន់តែជំនួសបាន។ ដូច្នេះបើកាលណាគេអត់នៅ គេហៅខ្ញុំមកជំនួស ជំនួសហើយខ្ញុំចេញទៅវិញទៅ មិនមែននៅក្នុងហ្នឹងទេ។

**ស៖** បើលោកមិនបានឆ្លើយនឹងសំណួរខ្ញុំទេ។ ខ្ញុំសួរថា អ្នកណាជាអ្នកចេញបញ្ជាឲ្យលោកវាយអង្គុលីលេខ ជួយវាយអង្គុលីលេខគេនេះ?

**ឆ៖** វាមានតែពីរនាក់ទេ បើជួនកាល តាអាន់ ហៅ ឬមួយទៀត តាឌុច ហៅ។

**ស៖** បើអ៊ីចឹងខ្ញុំសួរថាមួយណា?

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀត?

**ស៖** និយាយអំមិញ តាអាន់ និងតាឌុច ហ្នឹង ក្នុងចំណោមពីរនាក់ហ្នឹង អ្នកណាគេៗ អ្នកសុំឲ្យលោកជួយវាយអង្គុលីលេខគេហ្នឹងណ៎ា ក្នុងចំណោមពីរនាក់ហ្នឹង?

**ឆ៖** បាទ ក្នុងចំណោមទាំងពីរនាក់ ទាំងពីរនាក់តែម្តង។ ជួនកាលអាហ្នឹងគេហៅឲ្យខ្ញុំជួយ វ៉ៃគេខ្លះទៅ បើ ឌុច ហ្នឹងអត់នៅ គេហៅឲ្យខ្ញុំជួយវ៉ៃទៅ។ ជួនកាលបើសិនជា អាន់ អត់នៅទៅ ឌុចហ្នឹងក៏ហៅខ្ញុំជួយវ៉ៃបន្ថែមទៅ នៅពេលណាដែលអវត្តមានរបស់គេហ្នឹង ទើបខ្ញុំវ៉ៃ។

**ស៖** អ៊ីចឹងខ្ញុំសួរថាហេតុអី? បើថាអ្នកទាំងពីរនាក់ហ្នឹងមិនមែនជាមេរបស់លោកទេ ហេតុអីក៏លោកព្រមធ្វើការពេលដែលគាត់ប្រើ? ព្រោះថាតួនាទីរបស់គាត់ហ្នឹងគ្រាន់តែ -- របស់លោកហ្នឹងគ្រាន់តែជាអ្នកយាមនៅបរិវេណខាងក្រៅទេ ហេតុអីក៏ព្រមទទួលធ្វើការងារពេលពួគេប្រើ ចេញបញ្ជាប្រាប់លោកឲ្យធ្វើនេះ?

**ឆ៖** បាទ ពេលនោះលោកដឹងស្រាប់ហើយថា សម័យខ្មែរក្រហមគឺ អ្នកអត់ចេះទាំងអស់ដែលយកទៅធ្វើការ។ ពេលដែលខ្ញុំបានចេះអក្សរបន្តិចបន្តួចហ្នឹង គឺទៅហ្នឹងគេប្រើឲ្យទៅណាគឺឲ្យទៅសរសរឲ្យធ្វើហ្នឹងហើយ អ្នកក្រៅពីហ្នឹងគឺអត់ចេះទេ។ អ៊ីចឹងអ្នកចេះអក្សរបន្តិចបន្តួច គឺអាចសរសេរបានអីបានហ្នឹង គេប្រើបាន។ ហើយពេលដែលយើងទៅនៅក្នុងហ្នឹង ទាំងពីរនាក់ហ្នឹងគ្មានសិទ្ធិបញ្ជាទេ ប៉ុន្តែមានសិទ្ធិហៅឲ្យយើងឲ្យប្រើក្នុងរយៈពេលណាដែលយើងអាចធ្វើបានទេ មិនមែនមានសិទ្ធិបញ្ជាយើង ក្រុមយើងប្រាំមួយនាក់នេះថាឲ្យទៅខាងនេះខាងនោះ អត់ទេ។ បើថាគេហៅជំនួយជួយវាយអង្គុលីបន្តិចបន្តួចយើងចេះ គេហៅឲ្យយើងជួយវាយឲ្យទៅ យើងជួយតាមសំណូមពររបស់គេទៅ គ្រាន់តែប៉ុណ្ណឹង។

[១៣:៥៧:៣៣]

**ស៖** តើការវាយអង្គុលីលេខហ្នឹង គឺជាការដែលថាលោកជួយគាត់តែប៉ុណ្ណឹងទេ? ឬក៏លោកធ្លាប់ជួយការងារផ្សេងទៀតដែរ?

**ឆ៖** ខ្ញុំអត់មានជំនាញអីខុសពីហ្នឹងទេ បើខ្ញុំអង្គុលីហ្នឹងគឺខ្ញុំចេះតិចតួចបំផុត។ អក្សរក៏ខ្ញុំចេះមិនចេះជ្រៅជ្រះអីប៉ុន្មានដែរ អ៊ីចឹងអ្វីដែលលើសពីហ្នឹងគឺខ្ញុំមិនអាចធ្វើបាន។

**ស៖** ឥឡូវខ្ញុំចង់ៗឲ្យលោកពន្យល់ឲ្យលម្អិតបន្តិចថាតើលោកបានរៀនវាយអង្គុលីលេខហ្នឹងនៅឯណាដែរ?

**ឆ៖** បាទ ខ្ញុំរៀនវាយអង្គុលីលេខនៅបឋមសិក្សាវត្តអង្គឈូក ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ខេត្តតាកែវ។ ខ្ញុំរៀននៅថ្នាក់ទី៨ អង្គុលីលេខហ្នឹងវាចាស់ទៅហើយ ខ្ញុំចេះតែរៀនវាយគោះទៅ វាចេះ

បានបន្តិចបន្តួច ដល់ខ្ញុំរៀនវាយតាំងពីនៅក្មេងនៅឡើយ ហើយពេលហ្នឹងវានៅចាំដិតអារម្មណ៍នៅក្នុងចិត្តហ្នឹងចងចាំរហូតទៅ។ ពេលដែលមានសង្គ្រាមកើតឡើងហ្នឹង ក៏ការងារចេះហ្នឹង វាអត់ទាន់ភ្លេចទេ វានៅចងចាំបន្តិចបន្តួចក្នុងខ្លួន។ វាក៏អត់មានស្ទាត់ជំនាញដែរបាទ។

**ស៖** អ៊ីចឹងគឺលោកបាននិយាយថាលោកបានរៀនអង្គុលីលេខហ្នឹងនៅសាលាបឋមសិក្សា។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើមានសិស្សនៅសាលាបឋមសិក្សាច្រើនទេរៀនវាយអង្គុលីលេខហ្នឹង? ឬក៏លោកតែម្នាក់គត់ទេដែលរៀនវាយអង្គុលីលេខនៅសាលាបឋមសិក្សា?

**ឆ៖** បាទមាន ប៉ុន្តែមិនច្រើនប៉ុន្មានទេសម័យនោះ។ ក្មេងៗពេលដែលឈប់ពេលគេហៅថាពេលឈប់សម្រាក ម៉ោងសម្រាកហ្នឹងចូលវាយលេងក្នុងគេហៅ បណ្ណាល័យ ចូលទៅវាយលេងត្រង់ហ្នឹង គ្មានគ្រូបង្រៀនទេបាទ។

**ស៖** ហើយអត់មានគ្រូបង្រៀនទេអ៊ីចឹង? ហើយមានត្រឹមម៉ាស៊ីនអង្គុលីលេខ អ៊ីចឹងពេលដែលលោកឃើញម៉ាស៊ីនអង្គុលីលេខហ្នឹងទៅក៏ចង់វាយ រៀនវាយទៅក្រែងលោ មានប្រយោជន៍ទៅថ្ងៃក្រោយ។ លោកចង់និយាយប្រាប់ទៅតុលាការអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៤:០០:១៧]

**ឆ៖** បាទ កាលពីសម័យនោះ ខ្ញុំនៅក្មេង ឃើញរបស់អស់ហ្នឹង ចង់វាយ ចង់ចេះ។ ប៉ុន្តែខ្ញុំរៀននៅថ្នាក់ទី -- រៀននៅសាលាបឋមសិក្សានៅជំនាន់នោះគ្មានទេ មានតែនៅក្នុងបណ្ណាល័យហ្នឹងទេ ដែលអង្គុលីហ្នឹងនៅសល់ ឃើញនៅសល់ពីសង្គមចាស់មកហ្នឹង។ ហើយចេះតែវាយទៅ បានចេះខ្លះហ្នឹង។ គោលបំណងនៃការវាយហ្នឹងគឺដើម្បីឲ្យចេះ ចង់រៀន ចង់ចេះ បាទ។

**ស៖** ហើយកាលលោកឃើញ ដឹង ពេលដឹងថាខ្លួនឯងហ្នឹងចង់រៀនវាយអង្គុលីលេខ ដឹងថាខ្លួនឯងមានទេពកោសល្យហ្នឹង កាលនុំងមានអាយុប៉ុន្មានដែរ?

**ឆ៖** បាទ កាលនោះខ្ញុំអាយុប្រហែលជា ១៣-១៤ឆ្នាំ តែប៉ុណ្ណោះ មុនរដ្ឋប្រហារឆ្នាំ១៩៧០ អាយុ ១៣ឆ្នាំ ឬ ១៤ឆ្នាំ តែប៉ុណ្ណឹង។

**ស៖** ហើយនិយាយ ចន្លោះពេលពីសាលាបឋមសិក្សាហ្នឹងទៅមន្ទីរក្រាំងតាចាន់ហ្នឹង ក្នុងចន្លោះពេលហ្នឹងលោកមិនដែលប្រកបមុខរបរជាអ្នកវាយអង្គុលីលេខទេ។ អ៊ីចឹងខ្ញុំចង់សួរថា តើពីពេលចេញពីពេលសាលាបឋមសិក្សាហ្នឹង រហូតដល់ពេលដែលលោកទៅក្រាំងតាចាន់ហ្នឹង ក្នុងចន្លោះពេលហ្នឹងលោកមានដែលវាយអង្គុលីលេខទេ? ធ្វើការងារជាអ្នកវាយអង្គុលីលេខអីទេ?

**ឆ៖** បាទអត់ទេ អត់មានវាយនៅកន្លែងណាទេ។

**ស៖** អ៊ីចឹងខ្ញុំសួរថាម៉េចក៏តាអាន់ ហើយនិង តាឌុចហ្នឹង ដឹងថាលោកហ្នឹងចេះវាយអង្គុលីលេខ? តើពួកគាត់ទាំងពីរនាក់ហ្នឹងដឹងតាមរបៀបណា?

**ឆ៖** បាទធម្មតាទេ កាលណាយើងចូលទៅដល់គេសួរយើងហើយចេះស្អីខ្លះ។ ចេះអក្សរអត់ចេះអីហ្នឹង។ ហើយអង្គុលីហ្នឹងចេះវាយអត់ហ្នឹង គេសួរយើង។ ហើយយើងចេះអក្សរយើងថាចេះអក្សរ យើងថាអត់យើងថាអត់ទៅ។ ហើយអង្គុលីលេខគេសួរយើងចេះវាយអង្គុលីហ្នឹងអត់ ព្រោះកន្លែងហ្នឹងគឺមានអង្គុលីលេខ។ ហើយខ្ញុំចង់វាយផងហ្នឹង ឆ្លើយប្រាប់គេថាចេះទៅ ប៉ុន្តែចេះហ្នឹងស្ទើរបំផុត បាទ។

[១៤:០៣:០៧]

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាលោកបានជំនួសអ្នកណាម្នាក់កាលហ្នឹង។ អ៊ីចឹង ខ្ញុំសួរថាលោកជំនួសអ្នកណា?

**ឆ៖** បាទអត់ទេ។ អត់មានជំនួសអ្នកណាទេ។

**ស៖** អ៊ីចឹង គឺបានន័យថាលោកជាមនុស្សទី១ ហើយដែលប្រើ -- ដែលចេះវាយ ឬក៏ប្រើប្រាស់ម៉ាស៊ីនអង្គុលីលេខនេះ មែនទេ?

**ឆ៖** បាទទេ មិនមែនខ្ញុំជាលើកទី១ទេ ព្រោះកន្លែងហ្នឹងមិនដឹងគេវាយហ្នឹងប៉ុន្មាននាក់មកហើយទេ ឬអ្នកចេះនៅក្នុងហ្នឹងគេវាយប៉ុន្មាននាក់ខ្ញុំក៏អត់ដឹងដែរ ព្រោះខ្ញុំទៅក្រោយនេះ វាវគ្គក្រោយបំផុតដែលពេលដែលខ្ញុំចូលទៅវាយហ្នឹងគឺខ្ញុំទៅក្រោយគេទាំងអស់ បាទ។

**ស៖** បាទខ្ញុំសូម ចង់ឲ្យលោក ប្រាប់ថាតើកន្លែងដែលលោកយាមនោះ ធៀបទៅហ្នឹងមន្ទីរក្រាំងតាចាន់នោះថា ចម្ងាយប៉ុន្មានដែរ? ខ្ញុំឮថា ដូចជាមួយគីឡូម៉ែត្រ ឬក៏អាចឆ្ងាយជាងហ្នឹង។ អ៊ីចឹង ខ្ញុំសួរសុំឲ្យលោកបញ្ជាក់ឲ្យច្បាស់ថា ចម្ងាយប៉ុន្មានពីប៉ុស្តិ៍យាមរបស់លោកហ្នឹង ទៅមន្ទីរក្រាំងតាចាន់?

**ឆ៖** បាទសូមជម្រាបថា វាមានពីរដំណាក់កាល។ ដំណាក់កាលទី១ ពេលខ្ញុំទៅមុនដំបូង គេដាក់ចម្ងាយប្រហែលជា១គីឡូម៉ែត្រ។ ក្រោយមកបានរយៈពេលប្រហែលជាជិតមួយឆ្នាំ បានគេយកមកដាក់យាមនៅមាត់ទ្វារ មាត់របង នៅគុកក្រាំងតាចាន់ហ្នឹងតែម្តង។ ហើយពីមុខ ពីរបងនៅជុំវិញព័ទ្ធគុកក្រាំងតាចាន់ហ្នឹង មានទំហំដីប្រហែលជា១ហិកតាកន្លះទេ ប្រហែលជា១០០ម៉ែត្រជាងបួនជ្រុង ប្រហែលជា១៥០ម៉ែត្រចុះបួនជ្រុងទេ។ ហើយយើងយាមនៅរបង យាមនៅមាត់ទ្វារខាងកើតមួយ។ មានមាត់ទ្វារពីរ ខាងកើតមួយ ខាងលិចមួយ បាទ។

**ស៖** បាទ ខ្ញុំនៅតែយល់មិនច្បាស់ដដែល ខ្ញុំសូមឲ្យលោកបំភ្លឺ។ លោកនិយាយថាពីដំបូងលោកនៅចម្ងាយប្រហែលជា១គីឡូម៉ែត្រ ពីមន្ទីរក្រាំងតាចាន់ -- ពីមន្ទីរតាចាន់ហ្នឹង។ ហើយបន្ទាប់មក គេដាក់មកខ្លោងទ្វារ។ អ៊ីចឹង ខ្ញុំសួរបញ្ជាក់ថា តើមាត់ទ្វារនេះ គឺថានៅក្បែរមន្ទីរ នៅជិតមន្ទីរហ្នឹងជាង ឬក៏ឆ្ងាយជាងអា១គីឡូម៉ែត្រនុងទៀត?

[១៤:០៦:១៥]

**ឆ៖** បាទ របងគុកនៅជុំវិញក្រាំងតាចាន់ ដូចខ្ញុំឆ្លើយប្រាប់អម្បាញ់មិញអ៊ីចឹង គឺមានទំហំតែប្រហែលជា១ហិកតាបួនជ្រុង ជាង១០០ម៉ែត្របួនជ្រុងទេ។ អ៊ីចឹងមុនដំបូងវាយកខ្ញុំទៅដាក់នុង ប្រហែលចម្ងាយ១គីឡូម៉ែត្រ។ ក្រោយមកបានយកមកដាក់ឲ្យយើងមាត់ទ្វាររបងគុកហ្នឹងទាំងពីរហ្នឹង ហើយទំហំមាត់ ទំហំគុកហ្នឹងមានប្រហែលដីហ្នឹង១ហិកតាកន្លះទេ ប្រហែលជា១៥០ម៉ែត្របួនជ្រុងទេ បាទ។ អ៊ីចឹង មិនមែនមួយដំណាក់កាលទេ គឺពីរដំណាក់កាល។ ដំណាក់កាលទី១ នៅប្រហែលជា១គីឡូម៉ែត្រ។ ដំណាក់កាលទី២ បានមកនៅនឹងជាប់របងគុកហ្នឹងតែម្តង។ ហើយគុកហ្នឹង មានទំហំប្រហែលជា១គីឡូ -- ១៥០ម៉ែត្របួនជ្រុងទេ។

**ស៖** អ៊ីចឹង បានន័យថាលោកនៅនឹងរបងហ្នឹងដែលមានបរិវេណប្រហែលជា ១៥០ម៉ែត្របួនជ្រុង។ អ៊ីចឹងៗបានន័យថា កាលនោះលោកនៅនឹងនៅជិតនឹងមន្ទីរហ្នឹងមែនទេ? អ៊ីចឹងគឺថា សឹងតែនៅក្នុងមន្ទីរហ្នឹងតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ពេលដែលមកនៅក្នុងយាមមាត់ទ្វារហ្នឹង គឺនៅក្នុងមន្ទីរហ្នឹងតែម្តង។

**ស៖** កន្លែងរោងសម្រាករបស់យើង គឺនៅក្នុងៗជាប់របងជាប់នឹងមាត់ទ្វារហ្នឹង។

**ស៖** តើនៅកន្លែងហ្នឹងហើយដែលលោកបានឮអ្នកទោសដែលត្រូវបានគេធ្វើទារុណកម្មហ្នឹងស្រែក។ អង្កាល់ដែលឮហ្នឹង លោកនៅចម្ងាយ១គីឡូម៉ែត្រពីមន្ទីរហ្នឹង ឬក៏ពេលដែលលោកមកនៅនឹងរបងហ្នឹងបានឮ?

[១៤:០៨:៣៥]

**ឆ៖** បាទ ដល់ៗមកដល់ក្នុងរបងបានឮ បើនៅ១គីឡូម៉ែត្រ ស្តាប់មិនឮទេ ព្រះគុណ។

**ស៖** អ៊ីចឹង លោកបានឮអ្នកទោសស្រែក ក៏ប៉ុន្តែលោកមិនដែលបានឮគេចាក់មីក្រូទេ។ លោកបាននិយាយអម្បាញ់មិញហ្នឹង និយាយអ៊ីចឹង។ មិនដែលឮគេចាក់មីក្រូទេ មិនដែលឮគេបាញ់កាំភ្លើងអីទេ ប៉ុន្តែឮអ្នកទោសស្រែកហ្នឹងឮ។ តើលោកអាចបញ្ជាក់ចម្លើយលោកបានទេ គឺថាអម្បាញ់មិញហ្នឹងលោក

បាននិយាយអ៊ីចឹង?

**ឆ៖** បាទ ពិតប្រាកដមែន។ ខ្ញុំនិយាយដូចសម្ដីខ្ញុំរៀបរាប់មុនហ្នឹងអ៊ីចឹង បាទ។

**ស៖** ហើយលោកបាននិយាយថា លោកនិយាយ -- លោកៗនិយាយថាលោកមិនដែលបានឮគេចាក់មីក្រូ ឬក៏មិនដែលឃើញមីក្រូ?

**ឆ៖** បាទ មិនដែលទាំងឮ ហើយក៏មិនដែលទាំងឃើញទៀតផង។

**ស៖** តើលោកមានធ្លាប់ឃើញអ្នកទោសរបួសដែរឬទេ?

**ឆ៖** បាទ អត់ទេ មិនដែលឃើញទេ។

**ស៖** តើលោកមានដែលឃើញអ្នកទោសចេញពីមន្ទីរក្រាំងតាចាន់ហ្នឹងវិញទេ?

**ឆ៖** បាទ ដែលឃើញខ្លះ ចេញទៅវិញ។ ប៉ុន្តែ មិនដឹងជាចេញហ្នឹង គេឲ្យទៅផ្ទះឬក៏ចេញទៅណាទេ អត់ដឹងទេ។

**ស៖** ហើយនៅពេលដែលពួកគេចេញពីមន្ទីរឃុំ -- មន្ទីរក្រាំងតាចាន់ហ្នឹង ចេញទៅគេចងដៃឃើញហើយដើរចេញទៅតែខ្លួនឯង -- ដោយខ្លួនឯង ឬមួយក៏ចេញទៅមានគេអមដំណើរ គេដើរក្រៀកចេញទៅ?

**ឆ៖** បាទ ពេលដែលចេញពីមន្ទីរក្រាំងតាចាន់ហ្នឹង គឺអត់មានអ្នកណាអមដំណើរទេ អត់មានទេ។ តែបើនៅ -- គេបញ្ជូនចេញពីក្រាំងតាចាន់នេះ ភាគច្រើនគេចងដៃ ហ្នឹងបានសរថាមិនមែនអ្នកហ្នឹងចេញទៅផ្ទះទេបាទ។ កាលណាគេចងៗដៃទៅក្រោយហើយហ្នឹង គេបញ្ជូនចេញ។ មានអ្នកគេមកទទួលត្រឹមហ្នឹង។ ប៉ុន្តែ គេយកទៅណាទៀត ហ្នឹងខ្ញុំចាំបានត្រឹមឃើញ គេនាំពីក្នុងមកចេញដល់មាត់ទ្វាខ្ញុំ និងប្រគល់ឲ្យគេទេ។

[១៤:១២:២៧]

**ស៖** អ៊ីចឹង ក្រុមអ្នកផ្សេងដែលគេមកយកបន្តទៅហ្នឹង ពួកហ្នឹងជាអ្នកណាដែរ?

**ឆ៖** បាទ អត់ដឹងទេ អត់ស្គាល់។

**ស៖** ក្រុមហ្នឹងគេមកហ្នឹង គេមកដោយចៃដន្យតែម្ដង ឬក៏ពួកគេៗហ្នឹងទទួលបញ្ជាច្បាស់លាស់ហើយមុននឹងមកហ្នឹង បើតាមលោកយល់ដឹង?

**ឆ៖** បាទ ខ្ញុំអត់ដឹងថាគេមកហ្នឹងមកដោយចៃដន្យទេ ហើយឬក៏មកដោយបញ្ជាពីថ្នាក់ណាមកក៏ខ្ញុំអត់បានដឹងដែរ ឃើញតែគេមកដល់ អាហ្នឹងគេបញ្ជូនចេញតែម្ដង។ ខ្ញុំអត់បានដឹងទេ។

**សៈ** នៅពេលដែលពួកគេមកដល់កន្លែងហ្នឹង ទោះបីថានៅខាងក្នុងរបងក៏ដោយ ខាងក្រៅរបងៗក៏ដោយនោះ តើពួកគេនោះត្រូវបង្ហាញលិខិតស្នាមអីទេ? សួរថា ដើម្បីចូលទៅក្នុងបរិវេណមន្ទីរហ្នឹងបាន មានត្រូវបង្ហាញលិខិតស្នាមឬក៏ការ -- លិខិតអនុញ្ញាតអីទេ មុននឹងចូលបាននោះ?

**ផៈ** បាទ គ្មានទេ មានតែស្លៀកពាក់ខោអាវខ្មៅ កាន់ស្ពាយកាំភ្លើងមកហ្នឹង អាហ្នឹងចូលបានហើយ។ យើងបើកទ្វាឲ្យគេចូលហើយ។ យើងនៅអ្នកយាមហ្នឹងគឺបើកទ្វាបិទទ្វាហ្នឹង។ ពេលណាមានកាំភ្លើងស្ពាយមក ពាក់ខោអាវខ្មៅហ្នឹង ចូលមកយើងអត់មានសួររកអត្តសញ្ញាណគេទេ អត់ដែលមានអ្នកសួរទេ។

**សៈ** តាំងពីពេលលោកបានឈប់ធ្វើការនៅក្រាំងតាចាន់ហ្នឹង តើលោកមានបានជួបអតីតបុគ្គលិកនៅមន្ទីរក្រាំងតាចាន់ដែរឬទេ? ឬក៏លោកធ្លាប់បានជួបអតីតអ្នកទោសនៅក្រាំងតាចាន់ដែរឬទេ?

[១៤:១៤:៤៥]

**ផៈ** បាទ បុគ្គលិកដែលនៅជាមួយខ្ញុំ ប្រាំប្រាំមួយនាក់ហ្នឹង ខ្ញុំអត់ដែលបានជួបទេ។ គេមានប្តី-ប្រពន្ធ បែកគ្នារៀងៗខ្លួនទៅហើយ មិនដែលបានជួបគ្នាទេ។ ហើយនិងអ្នកទោសនៅក្នុងហ្នឹង ក៏ខ្ញុំអត់ដែលបានជួបដែរ ព្រោះខ្ញុំចេញពីក្រាំងតាចាន់ហ្នឹង នៅខែ៧ ឆ្នាំ១៩៧៨ ខ្ញុំទៅកងអង្គភាពខ្ញុំវិញ។ ហ្នឹងខ្ញុំចេញទៅមុនគេបំផុត។

**សៈ** អ៊ីចឹងតើលោកមិនដែលបានជួបអ្នកទោសនៅមន្ទីរក្រាំងតាចាន់ទេក្រោយមកហ្នឹងមែនទេ?

**ផៈ** បាទ ក្រោយមកហ្នឹងគឺខ្ញុំអត់ដែលជួបទេ មានតែឈ្មោះមួយគត់ដែលឧស្សាហ៍ទៅរកខ្ញុំហ្នឹងគឺឈ្មោះ សយ សែន ហ្នឹង។ បើអ្នកទោសក្រៅពីហ្នឹងគឺអត់មានទេ។

**សៈ** ហើយអ៊ីចឹង ខ្ញុំសួរលោកថា អ៊ីចឹង សយ សែន ហ្នឹង មិនមែនជាអ្នកទោសនៅក្រាំងតាចាន់ទេឬ?

**ផៈ** ទេ។ សយ សែន ជាអ្នកទោសនៅក្រាំងតាចាន់ហ្នឹង ប៉ុន្តែ សយ សែន ហ្នឹងជាប់ទោសតាំងពីមុនខ្ញុំទៅដល់ ហើយពេលដែលខ្ញុំចេញមកវិញហ្នឹងក៏ សយ សែន នៅហ្នឹងដែរ ខ្ញុំ ពេលខ្ញុំចេញពីក្រាំងតាចាន់ក៏ សយ សែន អត់ចេញដែរ នៅតែក្នុងហ្នឹងរហូត។ មិនដឹងជាគាត់ចេញនៅពេលណា។ ខ្ញុំអត់បានដឹងទេ។

**សៈ** អ៊ីចឹង គឺខ្ញុំមិនចង់សួរសំណួរដែលគគ្រោតគគ្រាតទេ។ អ៊ីចឹងខ្ញុំសួរថា លោកដែលមានអនុស្សាវរីយ៍ដែលល្អ ឬក៏អនុស្សាវរីយ៍អាក្រក់អំពីមន្ទីរក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ មកដល់ពេលនេះ ខ្ញុំសុំជម្រាបទៅអស់លោកថាមួយជីវិតខ្ញុំ មិនចង់ឃើញ មិនចង់យល់ ហើយរបបរបៀបនេះ គឺខ្ញុំមិនចង់រំឭកឱ្យឮដល់កូនចៅដល់ខាងក្រោយទៀត។ នេះជាអនុស្សាវរីយ៍ដ៏ជូរចត់បំផុត តែខ្ញុំមិនអាចដឹងព័ត៌មានច្រើនមកពីខ្ញុំនៅក្មេង ហើយម្យ៉ាងទៀតខ្ញុំក៏មិនមែនជាកម្មាភិបាល។ អ៊ីចឹងព័ត៌មានដែលដឹង គឺតិចតួចបំផុត ដែលខ្ញុំមិនអាចដឹងបាន ឃើញបាន គ្រាន់តែឮ។ ហ្នឹងជាវិប្បដិសារីរបស់ខ្ញុំ ដែលមិនបានដឹង មិនបានចាំច្បាស់ ប៉ុន្តែ ខ្ញុំគ្រាន់តែ -- ហ្នឹងហើយជាអនុស្សាវរីយ៍ដ៏ជូរចត់បំផុតនៅក្នុងឆាកជីវិតរបស់ខ្ញុំ។ បាទ សូមអរគុណ។

**សៈ** បើសិនជាខ្ញុំអាចសង្ខេបឡើងវិញបាននោះគឺថា លោកបានឃើញរឿងរ៉ាវតិចណាស់។ ឮសំឡេងពីរបីម៉ាត់ប៉ុណ្ណឹង ហើយលោកមានវិប្បដិសារី។ អ៊ីចឹង ខ្ញុំសួរថា ម៉េចក៏មានវិប្បដិសារី បើឃើញក៏តិច ឮក៏តិច។ អ៊ីចឹង តើមានមូលហេតុអីដែលធ្វើឱ្យលោកមានវិប្បដិសារី?

[១៤:១៨:៤៩]

**ឆ៖** បាទ មិនមែនជារឿងគួរឱ្យយើងចាប់អារម្មណ៍ ប៉ុន្តែនៅពេលនោះដែលខ្ញុំក្មេង នៅវ័យក្មេងពេកមិនអាចចងចាំបាន។ អ៊ីចឹង ការងារទាំងឡាយដែលបានធ្វើមកលើគ្រួសារបងប្អូនម៉ែឪ ក៏ខ្ញុំអត់បានដឹង អត់ចាប់អារម្មណ៍ អត់ចងចាំ។ បាទ ត្រង់ហ្នឹងហើយបានធ្វើឱ្យខ្ញុំដូចជាមានអារម្មណ៍ថាអស់សង្ឃឹមក្នុងចិត្ត។

**សៈ** បាទ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកនិយាយថា លោកមានវិប្បដិសារី។ អ៊ីចឹងខ្ញុំសួរថាលោកមានវិប្បដិសារីចំពោះខ្លួនឯងផ្ទាល់ ឬក៏មានវិប្បដិសារីចំពោះអ្នកទោសនៅក្រាំងតាចាន់?

**ឆ៖** បាទ ខ្ញុំ បើនិយាយទៅ មិនមែនតែអ្នកដល់តែជាប់ទោសហ្នឹងបានហៅអ្នកទោស។ សូម្បីតែបុគ្គលិកនៅក្នុងហ្នឹង បើខ្ញុំសន្មតមិនខុសទេ ប្រហែលជាចង់លើអ្នកទោសទៅទៀត ព្រោះនៅក្នុងគុកនៅពេលនោះ គុកគ្មានជញ្ជាំង ដូចយើងបររទេះសេះ ស្រុកខ្មែរយើងបររទេះសេះ ពេលគេចាប់បររទេះសេះ គេចាប់យកបង្ហៀរពាក់ហើយ គេដាក់ដែកបាំងភ្នែកមិនឱ្យឃើញចុះ ស្អីក៏ដោយ។ ហ្នឹងដែលថា ខ្ញុំជម្រាបទៅអង្គសវនាការ។ បាទ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលចាប់ពីដំបូងនេះ គឺសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។ បាទ សូមអញ្ជើញ!

[១៤:២១:២៦]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ ដំបូង ខ្ញុំសូមសួរលោកអំពីរយៈពេលមុនឆ្នាំ១៩៧៥ មុននឹងរំដោះបានទីក្រុងតាកែវ។ ខ្ញុំសូមអានចម្លើយរបស់កម្មាភិបាលមកពីភូមិភាគនិរតីដែរ។ លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារនេះ ជូនសាក្សី គឺE127/7.1.8, ERN ភាសាអង់គ្លេស 00901569, បារាំង 00978646, ERN ភាសាខ្មែរ 00893277។ លោកសាក្សី នេះគឺជាចម្លើយមួយរបស់កម្មាភិបាលមកពីភូមិភាគនិរតី។ ខ្ញុំសូមដកស្រង់ចេញពីចម្លើយរបស់គាត់ ហើយសូមសួរទៅលោក តើលោកយល់ឃើញថាដូចម្តេចដែរ។ កម្មាភិបាលម្នាក់នេះនិយាយដូចតទៅ គឺចម្លើយលេខ៥ "ទាក់ទងនឹងបញ្ហានេះ តាម៉ុក បានចេញបញ្ជាថាលេខាឃុំស្រុក ហើយនិងតំបន់ មិនមានសិទ្ធិចាប់ខ្លួន និងសម្លាប់ប្រជាជនទេ"។ ហើយក្រោយមក អ្នកស៊ើបអង្កេតបានសួរសំណួរបន្តទៅទៀត។ "តាម៉ុក បាននិយាយថាថ្នាក់ស្រុក និងថ្នាក់តំបន់ មិនមានសិទ្ធិសម្លាប់ប្រជាជនទេ។ ហេតុអ្វីបាន -- សំណួរសួរហេតុអ្វីបានជាមានមនុស្សជាច្រើនត្រូវសម្លាប់នៅថ្នាក់ស្រុកនិងថ្នាក់តំបន់?" កម្មាភិបាលនិយាយថា "ខ្ញុំមិនដឹងដែរ ចំពោះការអនុវត្តនៅតាមតំបន់ និងស្រុកនេះ តែខ្ញុំចាំច្បាស់នូវពាក្យសម្តីរបស់តាម៉ុក។ សំណួរ៖ តើតាម៉ុក ជាគណៈភូមិភាគនិរតីឬ?" ចម្លើយលេខ៨ ថា "បាទ"។ ហើយសំណួរបន្ទាប់សួរថា -- ហើយសំណួរលេខ៩៖ "តើតាម៉ុកធ្វើការប្រកាសនៅពេលណា? ឆ្លើយ៖ តាម៉ុកធ្វើការប្រកាសនៅមុនឆ្នាំ១៩៧៥។ នៅពេលមានកិច្ចប្រជុំបូកសរុប ដែលត្រូវបានធ្វើឡើងនៅក្នុងព្រៃមួយឆ្នាំម្តងដោយមានការចូលរួមពីគណៈឃុំ ស្រុក ខេត្ត និងកងវរៈ។ ក្រោយឆ្នាំ១៩៧៥ មានការប្រជុំម្តងទៀតនៅទីរួមខេត្តតាកែវ ដោយមានតាម៉ុក ចូលរួម ហើយឈ្មោះ សោម ដែលជាគណៈតំបន់១៣ បានប្រកាសថា ហាមប៉ះពាល់ទាហានរបបលន់នល់ ពីស័ក្តិ១ ដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់ទេ"។ ហើយសំណួរខ្ញុំបន្ទាប់មកទៀត គឺថាមានការប្រកាសនៅក្នុងឆ្នាំ១៩៧៥ថា ទាហានពីស័ក្តិ១ ដល់ស័ក្តិ៥មិនត្រូវ

ប៉ះពាល់ទេ។ នេះគឺកិច្ចប្រជុំធ្វើឡើងនៅភូមិភាគនីរតី។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ អំពីការប្រជុំនេះ?

[១៤:២៥:១៨]

**ឆ៖** បាទ ខ្ញុំតាំងពីចូលធ្វើនៅកងទ័ពខ្មែរក្រហមមក ខ្ញុំមិនដែលបានទៅប្រជុំ ហើយក៏មិនដែលស្គាល់ តាម៉ុក ឮសួរតែឈ្មោះទេ ខ្ញុំមិនដែលស្គាល់ផង។ ហើយសូម្បីតែប្រជុំតូច ប្រជុំធំ ក៏ខ្ញុំអត់ដែលដែរ។ អត់ដែលបានប្រជុំទេ។ អ៊ីចឹងការងារទាំងអស់ គឺខ្ញុំបាទអត់ដឹង។

**ស៖** ប្រហែលជាលោកមិនបានចូលរួមដោយផ្ទាល់ទេ ប៉ុន្តែសួរថាតើនៅក្នុងឆ្នាំ៧៥ ឬមុន៧៥ មេបញ្ជាការផ្ទាល់របស់លោក ឬក៏មេនៃមេរបស់លោក បានចូលរួមប្រជុំដែលនិយាយថា ទាហានពីស័ក្តិ១ ដល់ស័ក្តិ៥មិនត្រូវប៉ះពាល់នោះគឺ តើលោកមានធ្លាប់ដែលឮសួរបញ្ហានេះទេ?

**ឆ៖** បាទ អត់ដែលឮសួរទេ មិនដែលឮសួរគេនិយាយផង។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត ពាក់ព័ន្ធនឹងក្រាំងតាចាន់ មន្ទីរអប់រំកែប្រែក្រាំងតាចាន់។ លោកចាំឈ្មោះស្ត្រីម្នាក់នៅមន្ទីរអប់រំកែប្រែដែលជាអ្នកដាំស្លឲ្យអ្នកទោសឈ្មោះ យាយញ៉ លោកស្គាល់ទេ?

**ឆ៖** បាទ យាយញ៉ នេះខ្ញុំធ្លាប់ឮឈ្មោះគាត់។ ប៉ុន្តែខ្ញុំមិនស្គាល់គាត់ច្បាស់ទេ។ ប៉ុន្តែយាយញ៉នេះ គាត់ជាប់តាំងពីមុននឹង ខ្ញុំទៅៗទៀត។ ពេលដែលខ្ញុំចេញមកវិញ មិនដឹងជាគាត់ចេញហើយឬនៅបាទ។ មិនដឹងចេញក្រោយខ្ញុំ ឬមុនខ្ញុំទេ។ ពេលដែលខ្ញុំទៅនៅក្រាំងតាចាន់នោះគឺគាត់ជាប់ទោសនៅក្នុងនោះហើយស្រេចហើយ។

**ស៖** លោកចាំកូនរបស់គាត់ពីរនាក់ ឈ្មោះ មាស សារ៉ាត់ ឬក៏ រ៉ាត់ ឬនិង មាស សុខា ឬហៅខា លោកស្គាល់ទេ?

**ឆ៖** បាទ មិនចាំទេ។

[១៤:២៧:៤៧]

**ស៖** ពីមុនគឺថា លោកត្រូវបានសួរអំពី មាស ភឿង តើ មាស ភឿង ហ្នឹងមានពាក់ព័ន្ធសាច់ញាតិអីទៅនឹង មាស សារ៉ាត់ ឬ មាស សុខា នេះទេ?

**ឆ៖** បាទ គ្មានទេ។ អត់មានជាប់ពាក់ព័ន្ធ ញាតិមិត្តបងប្អូនទេ។

**ស៖** តើចំណុចនេះ ចង់បញ្ជាក់ថា -- ចំណុចនេះគឺឆ្លើយបញ្ជាក់ថា លោកស្គាល់ មាស សារ៉ាត់ និងមាស សុខា អ៊ីចឹងមែនទេ?

**ឆ៖** បាទ ឮឈ្មោះ តែខ្ញុំមិនស្គាល់ច្បាស់ទេ។

**ស៖** តើលោកធ្លាប់ស្គាល់ ឬក៏ធ្លាប់ដឹងថា អ្នកយាមឈ្មោះ វ៉ាន់ ស៊ាន់ តើមានជាប់សាច់ញាតិអី ជាមួយនឹងប្តីរបស់ មាស សារ៉ាត់ ដែរទេ?

**ឆ៖** អត់ស្គាល់ទេ។

**ស៖** សំណួរមួយទៀត គឺខ្ញុំនឹងសួរអំពី សយ សែន ខ្ញុំសួរខ្លីទេ។ ឥឡូវនេះ លោករស់នៅជិត សយ សែន ទេ ប្រហែលឮថាប្រហែលជា ២គីឡូម៉ែត្រ ពីភូមិរបស់គាត់ត្រូវទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងថា គាត់រស់នៅទីណាផង។ អត់ស្គាល់ អត់ចាំកន្លែងគាត់រស់នៅទេ មិនដឹង នៅទីណាផង។

**ស៖** ចំណុចនេះមានន័យថា លោកមិនមានទាក់ទងគាត់ទេ តើក្រោយឆ្នាំ១៩៧៩ លោកនៅមាន ដែលបានជួបគាត់ និយាយស្តីអីជាមួយគាត់ទេ?

**ឆ៖** បាទ ក្រោយឆ្នាំ១៩៧៩ លោក សយ សែន បានមកផ្ទះខ្ញុំម្តង ហើយគាត់ឆ្លើយ គាត់ និយាយជាមួយខ្ញុំយ៉ាងម៉េចទេកាលហ្នឹង ខ្ញុំមិនចាំទេ ប៉ុន្តែគ្រាន់តែសួរថាសុខទុក្ខគ្នាទេ កាលជំនាន់ហ្នឹង ជួបគ្នាម្តងហ្នឹងគត់។ ក្រោយមក ក៏មិនដែលជួបគ្នារហូតមកដល់សព្វថ្ងៃ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា ក្រោយឆ្នាំ១៩៧៩ លោកធ្លាប់ដែលនិយាយព្រឹត្តិការណ៍នៅ ក្រាំងតាចាន់ជាមួយយាយញ៉ ជាមួយកូនរបស់ យាយញ៉ គឺសារ៉ាត់ និង សុខា ឬក៏អ្នកណាផ្សេងទៀត ដែលត្រូវបានឃុំឃាំងនៅឯក្រាំងតាចាន់នោះដែរទេ?

**ឆ៖** បាទ ក្រោយឆ្នាំ១៩៧៩មក ខ្ញុំអត់ដែលបាននិយាយ ឬក៏អត់បានជួប ហើយក៏មិនដែលបាន ឃើញអ្នកទាំងអស់នោះដែរ បាទ។

[១៤:៣១:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារពីរបីទំព័រចេញពីឯកសារមួយចំនួន។ ការតាំង សំណួរប្រហែលជានឹងស៊ីពេលច្រើនដែរ។ ខ្ញុំមិនដឹងថា តើគួរឈប់សម្រាកនៅពេលនេះសិន ឬក៏ខ្ញុំបន្ត សួរតទៅទៀត។

**ប្រធានអង្គជំនុំ៖**

បាទបើដូច្នេះយើងឈប់ឥឡូវហ្នឹងទៅ ដើម្បីឲ្យការសួរនាំសួរដេញដោលហ្នឹងវាជាប់តែម្តងទៅ។

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី -- ម៉ោងដប់ប្រាំខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកនិងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី ខ្វះដប់នាទី មុនពេលអង្គជំនុំជម្រះចូលមកកាន់អសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៣ នាទី ដល់ម៉ោង ១៤:៥៤ នាទី)*

[១៤:៥៤:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនដល់ក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ផ្អាកបន្តិចសិនលោក វ៉ិចទ័រ កូប៉េ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយខ្លីទេ យើងបានកត់សម្គាល់ឃើញថាក្រុមមេធាវីការពារក្តី នួន ជា បានដាក់ចូលទៅក្នុងអ៊ីនធីហ្វេស នូវឯកសារជាង៥០០ទំព័រ។ ក្រុមគាត់ព្យាយាមចង់ដាក់ច្រើនទៅទៀត ថារហូតដល់១៣.០០០ទំព័រឯណោះ។ ប៉ុន្តែឯកសារដែលគាត់យកមកប្រើដំបូងនេះគឺអត់មាននៅក្នុងអ៊ីនធីហ្វេសទេ ខ្ញុំៗៗគិតឃើញថាខ្ញុំមិនជំទាស់ការប្រើប្រាស់ឯកសារក្រៅអ៊ីនធីហ្វេសទេ ប៉ុន្តែត្រូវមានភាពស្មោះត្រង់ឲ្យតែភាគីទាំងអស់បំពេញកិច្ចការអ្វីមួយដោយសេចក្តីស្មោះត្រង់ ខ្ញុំមិនជំទាស់ទេ។ ខ្ញុំសូមថាតើការប្រើប្រាស់ឯកសារនេះ វាជាការប្រើប្រាស់មួយដោយស្មោះត្រង់ឬមួយក៏

យ៉ាងណា? ដោយសារគាត់បានប្រើប្រាស់ឯកសារមួយដែលមិនមាននៅលើអ៊ីនធីហ្វេសនោះទេ។ ដូច្នេះ ខ្ញុំសូមសួរ តើមានផែនការអីត្រូវប្រើប្រាស់ឯកសារជាង ៦០០ទំព័រនេះនៅលើអ៊ីនធីហ្វេសតទៅទៀតទេ?

[១៤:៥៥:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំបានសួរទៅទីប្រឹក្សារបស់ខ្ញុំ ថាតើបានដាក់នៅលើអ៊ីនធីហ្វេសឬអត់? គាត់ថាបានដាក់ហើយ។ ខ្ញុំអត់ដឹងថា ខ្លួនខ្ញុំអត់ដឹងដាក់ថាយ៉ាងម៉េចផង យើងខ្ញុំសួរទៅទីប្រឹក្សាសួរអ៊ីចឹង ខ្ញុំចាំច្បាស់ណាស់ថាអង្គជំនុំជម្រះណែនាំឱ្យដាក់នៅលើអ៊ីនធីហ្វេស តើខ្ញុំនិយាយថាម៉េចទៀត បើខ្ញុំបានផ្ញើហើយ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមធានាថាមិនមាននៅលើអ៊ីនធីហ្វេសទេ។ ប្រហែលជាអ៊ីនធីហ្វេសហ្នឹងវាខូច ឬវាយ៉ាងម៉េចក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែដូចខ្ញុំបានលើកឡើង ឯកសារចាប់ផ្ដើម -- ខ្ញុំឃើញថាមានឯកសារ១៥៣ នៅលើអ៊ីនធីហ្វេស ហើយមានបំណងដាក់រហូតទៅដល់ ១៣០៩ ឯកសារឯណោះ។ ហេតុដូច្នេះឯង គឺយើងឃើញថាឯកសារ៧០០ ដំបូងអត់ទាន់មាននៅឡើយទេ។ ដូច្នេះ ខ្ញុំសូមឱ្យបញ្ជាក់ចំនួនឯកសារនេះនៅលើអ៊ីនធីហ្វេស បញ្ហាថាតើវាជាបញ្ហាបច្ចេកទេស ឬក៏យ៉ាងណា បច្ចេកទេសក្នុងការសួរដេញដោលយ៉ាងណា ឬក៏ដោយភាពស្មោះត្រង់នោះ?

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចមួយពាក់ព័ន្ធនឹងរបៀបដែលភាគីដាក់ឯកសារជាមុននៅក្នុងអ៊ីនធីហ្វេស ដូច្នេះខាងយើងៗចង់លើកឡើងពីបញ្ហានេះណាស់ អ៊ីចឹងធ្វើយ៉ាងម៉េចឱ្យអ៊ីនធីហ្វេសហ្នឹងជាមធ្យោបាយមួយសម្រាប់ប្រើប្រាស់ ហើយនៅពេលដែលដាក់ចង់ដាក់៥០០, ៦០០ ឬក៏ប៉ុន្មាននោះ គឺថាយើងដាក់អ៊ីចឹងពិបាកណាស់ ភាគីផ្សេងទៀតពិបាកនឹងធ្វើការណាស់ បើសិនជាដាក់ឯកសារច្រើនបែបនេះនោះ។ អ៊ីចឹងនៅពេលដែលដាក់ឯកសារច្រើន តើត្រូវតែប្រាប់ភាគីថាដាក់លេខយ៉ាងម៉េចដើម្បីឱ្យយើងដឹងថាតើ ឯកសារដែលៗចង់ប្រើហ្នឹងពិតជាដាក់នៅក្នុងអ៊ីនធីហ្វេសមែន។ អ៊ីចឹងសូមឱ្យអង្គជំនុំ

ជម្រះចោទសួរពីបញ្ហាហ្នឹង នៅពេលដែលយើងនិយាយអំពីឯកសារ ៥០០, ៦០០, ៧០០ អ៊ីចឹង តើយើងមានមធ្យោបាយណាមួយដែលថាអាចឲ្យភាគីទាំងអស់អាចដឹងបានថាឯកសារទាំងអស់នេះត្រូវបានដាក់នៅមុនសវនាការនៅក្នុងអ៊ីនធីហ្វេសនោះ។

[១៤:៥៨:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ច្បាស់ចំណុចមួយចំនួនគឺថាឯកសារទី១ ដែលខ្ញុំបង្ហាញជូនឯកសារនេះគឺថា ខ្ញុំបានធ្វើការណែនាំច្បាស់ទៅដល់ទីប្រឹក្សារបស់ខ្ញុំឲ្យដាក់ទៅលើអ៊ីនធីហ្វេស ពីព្រោះខ្ញុំមានផែនការប្រើប្រាស់ឯកសារនេះពីមុនតាំងពីមុនមកនេះហ្នឹង ចំណុចទី១។ សេចក្តីណែនាំទី២ គឺត្រូវដាក់ឯកសារក្រាំងតាចាន់ទៅលើអ៊ីនធីហ្វេស គឺថាខាងសហព្រះរាជអាជ្ញាមិនបានដាក់ទេ ពីថ្ងៃសុក្រ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ខ្ញុំធ្វើការរៀបចំ។ ខ្ញុំៗក៏បានដាក់ ហើយមិនដឹងថាត្រូវសួរឯកសារមួយណាពាក់ព័ន្ធនឹងក្រាំងតាចាន់។ ចំណុចទី១ទៀត គឺថាឯកសារជាចម្លើយបន្ថែម និយាយដោយត្រង់គឺថាខ្ញុំមិនដឹងថាមានពេលណាខ្ញុំអាចអានវាបាននោះទេ ហើយដើម្បីធានាឲ្យបានច្បាស់ថា ដែលការជំទាស់ថាមិនបានដាក់នៅលើអ៊ីនធីហ្វេស គឺយើងខ្ញុំបានដាក់ហើយ។

[១៤:៥៩:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងស្ថិតនៅក្នុងដំណើរការកំពុងរៀបចំធ្វើគោលការណ៍ណែនាំ -- ដាក់ចេញនូវគោលការណ៍ណែនាំ។ ប៉ុន្តែគោលការណ៍នេះពេលខ្លះយើងត្រូវទាមទារឲ្យមានភាពស្មោះត្រង់ នេះគឺជាយោបល់របស់ខ្ញុំទេដែលថា បញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំងនេះ គឺថាខ្ញុំស្នើសុំឲ្យមានភាពស្មោះត្រង់ដូចគ្នាដំបូង បើមិនដូច្នេះទេវាអាចពាក់ព័ន្ធទៅនឹងការរៀបចំចាត់ចែង ដោយសារយើងពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើចាំបាច់ ហើយនិងរយៈពេលដែលត្រូវប្រើប្រាស់ជាមួយនឹងចំនួនឯកសារដ៏ច្រើន។ ហើយយើងចង់ដឹងថា តើអ៊ីនធីហ្វេសនេះអាចដាក់ឯកសារបានប៉ុន្មាន។ ដូច្នេះព័ត៌មានពីរ ទី១ គឺយើងកំពុងតែរៀបចំ

ក្នុងពេលចេញត្រូវការរយៈពេលមួយថ្ងៃ ឬពីរថ្ងៃ ចេញសេចក្ដីណែនាំ ទី១ ទៀតគឺថា ភាគីម្នាក់ៗមិនត្រូវកេងប្រយោជន៍ពីគ្នាទៅវិញទៅមកនោះទេ គឺដើម្បីផលប្រយោជន៍ទាំងអស់គ្នា។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០១:៣៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី កូប៉េ គឺឯកសារដែលលោកកំពុងប្រើប្រាស់ឥឡូវនេះ កំពុងនឹង រៀបនឹងសួរបន្តិចទៀតនេះ លោកមាននៅលើអ៊ីនធីហ្វេសទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអត់ដឹងទេ លោកស្រីចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមជម្រាបជូនមើលថា តើមាននៅលើអ៊ីនធីហ្វេសឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំទើបតែសួរបញ្ជាក់ជាមួយនឹងទីប្រឹក្សាជាន់ខ្ពស់របស់ខ្ញុំ ដែលថាឯកសារហ្នឹងបានដាក់ទៅលើអ៊ីនធីហ្វេសហើយ។ ប្រហែលជាដោយសារតែការមិនដំណើរការប្រព័ន្ធអ៊ីនធីហ្វេសដោយប្រការណាមួយ។ ហើយអ៊ីចឹងឯងបានជាលោកសហព្រះរាជអាជ្ញាអន្តរជាតិគឺថាក៏ពិបាកនឹងរកវាហ្នឹងប្រហែលជាបញ្ហាបច្ចេកទេសនៃអ៊ីនធីហ្វេសនេះហើយ។

[១៥:០២:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះខ្ញុំមិនចោទប្រកាន់លោកយ៉ាងណានោះទេ លោកអាចបន្តក៏ប៉ុន្តែគ្រាន់តែសួរថា ឯកសារដែលលោកកំពុងតែរៀបនឹងប្រើហ្នឹង តើឯកសារមួយណា? ដើម្បីឲ្យយើងគិតមើលថា តើភាគីដទៃទៀតដឹងថាមានឯកសារហ្នឹងឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបង្ហាញឯកសារ E3/2421 និង E3/2107 បាទ គឺ E3/2421 និង E3/2107។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើភាគីដទៃទៀតមានដឹងថា មានឯកសារនេះនៅលើអ៊ីនធីហ្វេសទេ?

**លោក ឌេល លីសាក់៖**

លោកស្រីចៅក្រម យើងទើបតែព្រីនចេញនូវឯកសារក្នុងចំណោម ១០០ជាងរហូតទៅដល់ជាងមួយពាន់ ១៣០០ជាង គឺចន្លោះប៉ុននុ៎ង មាន២៣ទំព័រ។ អ្វីដែលយើងស្នើសុំនៅពេលនេះគឺថា សុំឱ្យផ្ដល់ការជូនដំណឹងឱ្យយើងបានទាន់ពេលវេលា ដើម្បីយើងអាចបើកមើលនៅលើអេក្រង់កុំព្យូទ័រតាមរយៈអ៊ីនធឺហ្វេសនេះ។ ប៉ុន្តែខ្ញុំទទួលស្គាល់ថាឯកសារពីរបញ្ជាក់អម្បាញ់មិញនេះគឺថាខ្ញុំអាចបានប្រើហើយៗ។

[១៥:០៤:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៤:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់ពីបញ្ហានេះចំពោះភាគី។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចង់សួរទៅលោកមេធាវី កូប៉េ។ ខ្ញុំចង់ដឹងថាតើឯកសារទាំងអស់មានប៉ុន្មានដែលបានដាក់ទៅក្នុង អ៊ីនធឺហ្វេស? ខ្ញុំយល់ថានៅរសៀលនេះ លោកចង់ប្រើតែបីទេ ក៏ប៉ុន្តែលើកលែងតែខ្ញុំភ័ន្តច្រឡំ ខ្ញុំយល់ថាមានឯកសារដល់ទៅរាប់រយឯណោះ ដែលដាក់នៅក្នុងអ៊ីនធឺហ្វេស។ អ៊ីចឹងខ្ញុំចង់ដឹងឱ្យបានច្បាស់ថា លោកពិតជាធ្វើដោយសុទ្ធចិត្ត ឬក៏យ៉ាងម៉េចក្នុងការដាក់ឯកសារច្រើនរយបែបនេះនោះ?

[១៥:០៥:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ជាថ្មីម្ដងទៀតលោកចៅក្រម គឺខ្ញុំមិនបានធ្វើអ្វីដោយមិនសុទ្ធចិត្តនោះទេ លោកចៅក្រម។ យើងខ្ញុំបានដាក់ឯកសារទៅលើអ៊ីនធឺហ្វេសយ៉ាងត្រឹមត្រូវ។ ខ្ញុំសួរទីប្រឹក្សាច្បាប់របស់ខ្ញុំ តើមិនសុទ្ធចិត្តហ្នឹងចង់ថាម៉េច?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើលោកចង់ប្រើឯកសារប៉ុន្មានសម្រាប់សួរសាក្សីរូបនេះ ហើយលោកដាក់ឯកសារប៉ុន្មាននៅក្នុងអ៊ីនធឺហ្វេស?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់សួរសាក្សី ពីរ បី សំណួរទាក់ទងទៅនឹងឯកសារទើបតែលើកឡើង យើងមានឯកសារមួយចំនួនទៀតមកពីក្រាំងតាចាន់ ដែលដាក់ទៅលើអ៊ីនធីហ្វេស គឺប្រាំឯកសារទៀត។ សរុបមកខ្ញុំយល់ថាមានទាំងអស់ប្រហែលជា ១៥ឯកសារ លោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងឯកសារទាំង១៥ហ្នឹង ត្រូវផ្ញើជូនទៅឲ្យភាគីទាំងអស់ ដើម្បីឲ្យភាគីអាចរកឃើញ ហើយប្រហែលជាភាគីត្រូវការពេលវេលាមួយចំនួនដើម្បីពិនិត្យមើលថាតើឯកសារទាំង ១៥ហ្នឹង មាននៅក្នុងអ៊ីនធីហ្វេសឬក៏អត់។ ដូច្នេះខ្ញុំមិនដឹងថាតើធ្វើយ៉ាងម៉េចទេ ប្រហែលជាអាចផ្អាកសវនាការលោកប្រធានឬក៏យ៉ាងម៉េចដើម្បីដោះស្រាយបញ្ហានេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ ឯកសារនេះគឺជាឯកសារមកពីក្រាំងតាចាន់ ខាងអយ្យការកាលពីព្រឹកមិញបានលើកឡើងឯកសារនេះមកសួរហើយ។ ចុះការឲ្យពេលវេលាដើម្បីឲ្យអយ្យការគាត់អាននេះ តើយ៉ាងម៉េចដែរ? ខាងហ្នឹង ខាងៗអយ្យការក៏គាត់មិនមានសុទ្ធចិត្តដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៨:១៨]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅខាងសហព្រះរាជអាជ្ញា ចំពោះឯកសារដែលមេធាវីប៉ុនប៉ងក្នុងការដាក់សួរដេញដោលសាក្សីរូបនេះនៅពេលបន្តិចទៀតនេះ ហើយវាមានបញ្ហាអ្វីទៀតទេ? ព្រោះគាត់បានបញ្ជាក់ហើយថាឯកសារមួយចំនួនហ្នឹង គឺបានដាក់ៗបង្ហាញដោយសហព្រះរាជអាជ្ញារួចទៅហើយ ឧទាហរណ៍ E3/2421។ ឬក៏លោកត្រូវការពេលវេលាដើម្បីពិនិត្យឯកសារនេះ ដើម្បីអង្គជំនុំជម្រះពិចារណាលើលទ្ធភាពក្នុងការផ្អាកសវនាការ ដើម្បីផ្ដល់ពេលវេលាសម្រាប់អានឯកសារ?

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំយល់ថាយើងអាចដំណើរការតាំងសំណួរបានតទៅទៀតហើយ។ ខ្ញុំយល់ឃើញថាមិនចាំបាច់ត្រូវការពេលវេលាដើម្បីអាននោះទេ អ៊ីចឹងអាចតាំងសំណួរបានហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក មេធាវី វ៉ិចទ័រ កូប៉េ បន្តនីតិវិធីក្នុងការសួរដេញដោលសាក្សី។

[១៥:០៩:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីមុននឹងចូលដល់ឯកសារនេះ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងសំណួរខ្ញុំមុនពេលឈប់សម្រាក។ ហ្នឹងគឺយោងទៅលើចម្លើយដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពីការរំបអូសបានទីក្រុងតាកែវនៅថ្ងៃទី១៧ មេសា ៧៥។ តើលោកពាក់ព័ន្ធទៅនឹងការប្រយុទ្ធដើម្បីរំបអូសយកក្រុងតាកែវដែរទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ កាលពេលនោះ ខ្ញុំនៅកងអង្គភាពស្រុក កាលពីខេត្តតាកែវហ្នឹង ប៉ុន្តែអត់មានបានវាយទេខេត្តតាកែវ គឺទាហានចេញមកដោយខ្លួនឯង លើកទង់សចុះចូលតែម្ដង។ អត់បានវាយទេ។

**ស៖** ដូច្នេះ យើង -- តើមានចម្ងាយប៉ុន្មានតាមដែលលោកប៉ាន់ប្រមាណទៅពីក្រាំងតាចាន់ទៅក្រុងតាកែវហ្នឹង មានចម្ងាយប៉ុន្មាន?

**ឆ៖** បាទ ពិបាកស្មានណាស់ ប្រហែលជាដី៣០-៤០គីឡូម៉ែត្រងណោះ បើគិតមើលទៅបាទ។

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសូមចូលទៅបង្ហាញឯកសារ លោកប្រធានសូមការ -- ខ្ញុំមានឯកសារជាក្រដាស ដូច្នេះ ខ្ញុំស្នើសុំការអនុញ្ញាតជូនទៅសាក្សី ហើយបើអាចក៏ស្នើសុំបង្ហាញនៅលើអេក្រង់ផង។ នេះគឺទាក់ទងទៅនឹងទំព័រណាមួយនៅលើឯកសារដែលបានប្រាប់នេះ ដោយសារទំព័រនេះវាមានហត្ថលេខា។ ដូច្នេះ ខ្ញុំសូមចាប់ផ្ដើមជាមួយឯកសារ E3/2421។ មិនចាំបាច់ប្រាប់បង្ហាញ ERN ទេ។ ខ្ញុំសួរតែពាក់ព័ន្ធតែទំព័រដែលមានហត្ថលេខា ERNជាភាសាខ្មែរ 00271177 ហើយនៅក្នុងឯកសារដដែលគឺ 002711810។ ដូច្នេះ យើងខ្ញុំសុំការអនុញ្ញាតបង្ហាញទំព័រពីនេះនៅលើ -- នៅក្នុងឯកសារនេះទៅសាក្សី និងសុំបង្ហាញនៅលើអេក្រង់កុំព្យូទ័រផង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៥:១៣:១៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកពិនិត្យមើល ERNជាខ្មែរ នៅជ្រុងខាងលើខាងឆ្វេងគឺ 0027 1177។ ឥឡូវនេះ គឺខ្ញុំសូមឲ្យលោកមើលត្រង់កណ្ដាល -- ចំណុចកណ្ដាលនៃទំព័រនេះ មិនមែនជាឯក-សារដើមទេ។ ឯកសារនេះ គឺយើងមិនមានឯកសារដើមទេលោកសាក្សី ក៏ប៉ុន្តែនៅត្រង់ពាក់កណ្ដាលទំព័រគឺមានហត្ថលេខាមួយ។ សូមលោកពិនិត្យមើលហត្ថលេខា ហើយជម្រាបអង្គជំនុំជម្រះផងមើលថា តើហត្ថលេខារបស់អ្នកណាហ្នឹង?

**លោក ស្រី ថន៖**

**ឆ៖** បាទ ហត្ថលេខានេះគឺហត្ថលេខារបស់ អាន់។

**ស៖** សូមអរគុណលោកសាក្សី។ ហើយនៅក្នុងឯកសារដដែលនេះ ខ្ញុំចង់ឲ្យលោកមើលទៅទំព័រ ERN ជាភាសាខ្មែរហ្នឹងនៅខាងក្រោមបំផុត -- នៅជ្រុងខាងក្រោម គឺមើលឯកសារប្អូនលេខខាងចុង 1180 គឺឯកសារE3/2421នេះឯង។ ហើយនៅត្រង់ទំព័រនេះ លោកសាក្សីគឺថាមានហត្ថលេខាមួយទៀត។ តើលោកអាចជម្រាបអង្គជំនុំជម្រះមើល ហត្ថលេខានេះជាហត្ថលេខាអ្នកណាដែរ?

**ឆ៖** បាទ ហត្ថលេខាតែមួយទេ គឺ អាន់ ដូចគ្នា។

**ស៖** សូមអរគុណ។ ចូលឯកសារទី៣ គឺឯកសារ E3/2425, ERN ជាភាសាខ្មែរ 00270926 ហើយសំណួរដដែលនៅត្រង់ពាក់កណ្ដាលទំព័រ ERN នេះ គឺលោកឃើញមានហត្ថលេខា។ តើលោកស្គាល់ហត្ថលេខានេះទេ?

**ឆ៖** បាទ ហត្ថលេខាហ្នឹងតែមួយទេ។

**ស៖** សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំសុំបង្ហាញសាក្សីនូវឯកសារមួយទៀតគឺ E3/2107។ បាទ សុំការអនុញ្ញាតផ្តល់ទំព័រជាក្រដាសនេះ សុំឲ្យមន្ត្រីតុលាការយកឯកសារជាក្រដាសជូនសាក្សីមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

ហើយលោកប្រធាន យើងខ្ញុំក៏សុំបង្ហាញនៅលើអេក្រង់ *ម្ញទីទ័ភ័*ដរ។

**ស៖** លោកសាក្សីលោកឃើញអត្ថបទមួយនៅត្រង់ ERN 0068049 លោកឃើញគេសរសេរអត្ថបទមួយសរសេរជាភាសាខ្មែរ។ សុំឲ្យលោកអានត្រង់កន្លែងនេះ។

[១៥:១៧:២៥]

**លោក ស្រី ថន៖**

**ឆ៖** "មន្ទីរអប់រំ១០៥ ចាប់ពីថ្ងៃ -- ចាប់ពីថ្ងៃ..." អានអត់ដាច់ទេលោកគ្រូ។ "ពួកអាខ្មាំងមកទល់សព្វថ្ងៃនេះ អស់ចំនួន១៥០០នាក់ សូមបក្សជ្រាប, ម.អប់រំស្រុក១០៥ អាន់"។

**ស៖** សំណួររបស់ខ្ញុំគឺ តើហត្ថលេខានេះជាហត្ថលេខារបស់ អាន់ ឬ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** សូមពន្យល់បន្តិចមើល ហេតុអ្វីបានជាលោកហ៊ានសន្និដ្ឋានថាជាហត្ថលេខារបស់ អាន់?

**ឆ៖** បាទ ព្រោះ ខ្ញុំឃើញ --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកសាក្សី!

សូមអញ្ជើញលោកសហមេធាវីរងអន្តរជាតិ -- លោកសហមេធាវី -- សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ឥឡូវនេះ គាត់សួរសាក្សីឲ្យផ្តល់នូវសេចក្តីសន្និដ្ឋាន ឬក៏ផ្តល់ជាមតិយោបល់លោក -- ខ្ញុំមិនដឹងថាឲ្យ គាត់ឲ្យសាក្សីនេះ ក្លាយទៅជាសាក្សីជំនាញ ឬក៏យ៉ាងម៉េចទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួររបស់ខ្ញុំគឺសួរថា តើសាក្សីអាច -- ហេតុអីគាត់អាចប្រាប់បានថាហត្ថលេខានេះ ជាហត្ថលេខារបស់ អាន់? ខ្ញុំមិនបានស្នើសុំឲ្យធ្វើសេចក្តីសន្និដ្ឋានទេ។ គ្រាន់តែសួរថាហេតុអីបានជាគាត់ដឹងថាជាហត្ថលេខារបស់ តាអាន់?

[១៥:២០:០៧]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប! សំណួរក្រោយនេះអាចឆ្លើយតបបាន។ សំណួរមុនមិនអាចឆ្លើយតបបានទេ ទាល់តែកែសម្រួលនូវសំណួររបស់គាត់ហើយ។

**ឆ៖** បាទ ព្រោះបានថាជាហត្ថលេខារបស់ អាន់ គឺសរសេរ អក្សរ អាន់ ដាក់ពីមុខហ្នឹងទាំងអស់ហើយ។ អ៊ីចឹងមិនពិបាកអីហ្នឹងមើលទេ។ វាងាយបំផុតគ្រាន់តែឃើញ អាន់ នៅពីមុខដឹងថា ជាហត្ថលេខារបស់គេហ្នឹងហើយ។ បាទ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ**

**ស៖** ខ្ញុំប្រហែលជារៀបសំណួរខ្ញុំឡើងវិញ។ ខ្ញុំដឹងមានឈ្មោះមនុស្សឈ្មោះ អាន់ ហើយនៅលើឯកសារហ្នឹងនោះ ប៉ុន្តែខ្ញុំសួរថាហេតុអីក៏លោកដឹងថាហត្ថលេខាមួយនេះជាហត្ថលេខារបស់ អាន់?

**លោក ស្រី ថន៖**

**ឆ៖** បាទ ព្រោះគេសរសេរអក្សរ ដាក់ អាន់ នៅពីមុខ។ ខ្ញុំឃើញអក្សរ អាន់ នៅពីមុខនេះ គឺជាហត្ថលេខារបស់គេហើយ។

**ស៖** ហ្នឹងគឺជាចំណុចដែលខ្ញុំចង់សួរ។ ខ្ញុំសួរសំណួរផ្សេងទៅវិញ។ ប្រសិនជាលោកមើលឯកសារដែលលោកទើបអាននេះ តើនេះជាអក្សរដៃរបស់ តាអាន់ ឬ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។

**ស៖** ខ្ញុំសូមឱ្យលោកមើលឯកសារនេះម្តងទៀត។ អត្ថបទនេះ គឺនិយាយពីទូរលេខ ១៥.000 នាក់។ តើលោកមានចាំថា អក្សរសរសេរដៃនេះជាអក្សររបស់ តាអាន់ ឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប! សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:២២:១៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ សំណួរនេះជាសំណួរច្រំដែល គាត់សួរសាក្សីនូវសំណួរដដែលៗទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

វាជាឯកសារដែលសំខាន់លោកប្រធាន។ ឯកសារនេះដាក់ទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យជំនុំជម្រះពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយ។ ដូច្នេះ ខ្ញុំគួរតែសួរសំណួរទៅលើឯកសារជាក់លាក់។ វាច្បាស់ណាស់ថា អក្សរសរសេរដោយដៃនេះ វាខុសពីអក្សរសរសេរដោយដៃដែលបង្ហាញពីខាងមុន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើសំណួរអម្បាញ់មិញនេះ គឺមានមូលដ្ឋានត្រឹមត្រូវច្បាប់គឺជាប្រភេទសំណួរច្រំដែល។ សាក្សីបានឆ្លើយរួចហើយ ថាខ្លួនមិនស្គាល់អក្សរឈ្មោះ អាន់ នោះឡើយ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរប្រភេទសំណួរច្រំដែលបែបនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំស្ដាប់ចម្លើយមិនបានច្បាស់ទេ។ អ៊ីចឹងគាត់ថា គាត់មិនស្គាល់អក្សរហ្នឹងទេ។ ប៉ុន្តែលោកប្រធាន ខ្ញុំបន្តទៅឯកសារមួយផ្សេងទៀត គឺឯកសារ ឯកសារនេះបាន -- សហព្រះរាជអាជ្ញាបានយកមកហើយគឺ ឯកសារ E3/4145។ បាទ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញដូចជា ឯកសារក្រដាសទៅសាក្សីជាថ្មីម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ**

**ស៖** លោកសាក្សី តើលោកធ្លាប់ដែលបានឃើញឯកសារនេះពីមុនទេ? លោកស្គាល់ឯកសារនេះទេ?

[១៥:២៥:00]

**ឆ៖** បាទ អត់ដែលឃើញទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីទម្រង់បែបបទនេះ ដូចជាហៅថា វាមានបន្ទាត់មានជួររបស់វា និយាយសរុបជារួម។ តើលោកពិនិត្យទៅឃើញថាធ្លាប់ឃើញឯកសារនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់គឺ ទំព័រមួយណាដែលគាត់យោង។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារនេះ ខ្ញុំសូមអធ្យាស្រ័យ ERN អង់គ្លេស 00762837, បារាំង 00761093--

[១៥:២៦:២៣]

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យ លោកមេធាវីញាប់ពេក ERN ជាភាសាខ្មែរបាត់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ បញ្ជាក់ ERN ជាភាសាខ្មែរម្តងទៀត។ ហើយបើជាការល្អ សូមលោកអាននូវលេខឯកសារ និងលេខERN ហ្នឹងឲ្យបានពីរដង បញ្ជាក់ឲ្យដូចគ្នាទៅសហព្រះរាជអាជ្ញារងអន្តរជាតិដែលគាត់តែងតែលើកឡើងបញ្ជាក់ពីរដង ដើម្បីឲ្យច្បាស់លាស់នៅក្នុងដំណើរនៃការដាក់បង្ហាញឯកសារ។ យើងដូចបានជម្រាបលោកម្តងហើយលើបញ្ហានេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** យើងនិយាយអំពីឯកសារ E3/4145 ទំព័រដែលត្រូវសួរនោះ គឺ ERN ជាភាសាអង់គ្លេស 00762837, បារាំង 00761093, ខ្មែរ 00068730 គឺមានចំនួនតែពីរទំព័រទេ។ ដូច្នេះសំណួរសំណួររបស់ខ្ញុំលោកសាក្សី តើទម្រង់នៃឯកសារនេះប្រភេទជាកូឡោនជាអ៊ីចឹង តើមើលទៅលោកធ្លាប់ចាំទេ លោកអាចនឹងស្គាល់ឯកសារនេះទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ ខ្ញុំដូចជាមិនដែលឃើញទេ។ បាទ អត់ដែលឃើញ។

**ស៖** លោកសាក្សី ខ្ញុំមិនសួរថាតើលោកបានឃើញឯកសារនេះផ្ទាល់ពីមុនទេ ខ្ញុំគ្រាន់តែសួរតើទម្រង់បែបបទ របៀបរបប ទ្រង់ទ្រាយហ្នឹង ប្រភេទចែកជាកូឡោនជាអី ជាដើមហ្នឹង ថាតើលោកអាចនឹងធ្លាប់ឃើញឯកសារតាមរបៀបណាមួយដែរទេ ឬក៏ធ្លាប់ឃើញគេព្រាងឯកសារដែលលំនាំបែបនេះទេ នៅឯគុកក្រាំងតាចាន់ នោះ?

**ឆ៖** អត់ទេ។

[១៥:២៨:៣៣]

**ស៖** ហើយសូមលោកជម្រាបជូនតុលាការផងថា អត់ទេហ្នឹង ចង់ថាម៉េច?

**ឆ៖** ឃើញទម្រង់ ព្រោះខ្ញុំមិនដែលបានឃើញទម្រង់ហ្នឹង សរសេររបៀបទម្រង់។ កាលហ្នឹង

គឺខ្ញុំមិនដែលបានឃើញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ ឯកសារ E3/4145 ដដែលនេះ ខ្ញុំសូមបង្ហាញជូនសាក្សីនូវ ERN ជាភាសាខ្មែរ 0068736។ សូមការអនុញ្ញាតជាថ្មីម្តងទៀត សុំបង្ហាញឯកសារជាក្រដាសដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីសូមលោកពិនិត្យមើលហ្នឹងគឺត្រង់ទំព័រពីលេខខាងចុង ពីរខ្ទង់ខាងចុង គឺលេខ ៣៦។

[១៥:៣០:២៣]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីរកឃើញឬនៅ? ឃើញឯកសារទំព័រដែលគេចង់សួរឬនៅ? ដែលមេធាវីចង់សួរហើយឬនៅ?

**លោក ស្រី ថន៖**

បាទ ឃើញហើយលោក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺដើម្បីឲ្យច្បាស់ គឺត្រង់ទំព័រ 00068736។ តើលោកស្គាល់ឯកសារនេះទេ? អាចរៀបរាប់ជូនអង្គជំនុំជម្រះបានទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ ឯកសារនេះ ខ្ញុំអត់ដែលស្គាល់ទេ។

**ស៖** ខ្ញុំយល់ថាលោកមិនស្គាល់ឯកសារ ក៏ប៉ុន្តែគ្រាន់តែប្រាប់ថាតើឯកសារនេះ ទម្រង់វាប្រភេទដែលគេបែងចែកជាកូឡោនជាអីជាដើមហ្នឹង តើលោកចាំថាឯកសារជាក់លាក់ណាមួយមានលក្ខណៈដូច ឬក៏ស្រដៀងនឹងឯកសារនេះទេ?

**ឆ៖** អត់ទេ អត់ដូចស្រដៀងគ្នាទេ។

[១៥:៣២:១២]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមចូលទៅឯកសារមួយផ្សេងទៀត គឺឯកសារនេះ លោកប្រធាន យើងខ្ញុំបានដាក់នៅលើអ៊ីនធឺហ្វេសហើយ គឺខ្ញុំសូមអានផ្នែកតូចមួយនៃឯកសារនេះទាក់ទងថា គឺឯកសារ E32454 -- E3/2454 និងឯកសារ E3/2424 និងឯកសារ E3/4093 និងឯកសារ E3/2453 និងឯកសារ E3/2048។ ឯកសារទាំងនេះ ជាឯកសារមកពីគុកក្រាំងតាចាន់។ ខ្ញុំគិតថាខាងសហព្រះរាជអាជ្ញាគឺបានឃើញឯកសារនេះហើយ។ ឯកសារទាំងប្រាំនេះ ខ្ញុំសូមអានតែ -- ឯកសារមួយៗសូមអានតែមួយទំព័រទេ ហើយខ្ញុំនឹងឲ្យ ERN នៃឯកសារចំនួនទាំងបីនេះដែរ។ យើងខ្ញុំសូមអានមួយទំព័រម្តងៗ មួយៗឯកសារអានតែមួយទំព័រទេ អ៊ីចឹងប្រាំទំព័រ។ ឯកសារទី១ ដូចដែលបានបញ្ជាក់ហើយ គឺ E3/2454 គឺ ERNជាភាសាអង់គ្លេស 00364288, ខ្មែរ 00271054, បារាំង 00612215។ លោកសាក្សីជានេះជារបាយការណ៍ជូនទៅ -- បាទ សេចក្តីរាយការណ៍គោរពជូនបក្សមូលដ្ឋានស្រុកត្រាំកក់។ឯកសារនេះនិយាយអំពីការលួចផ្សេងៗដែលថាមេកងបានអប់រំបុគ្គលនេះប្អូនដងហើយ បុគ្គលនេះអត់ស្តាប់ទេ អាហ្នឹងឯកសារទី១។ បានអប់រំកែប្រែបុគ្គលនេះ កសាងប្អូនដងហើយ។ មួយទៀតគឺ E3/2424, ERNជាភាសាអង់គ្លេស 00362217 ខ្មែរ 00 -- ហើយខ្មែរ 00612215 នេះក៏ជារបាយ-ការណ៍ដែលចោទប្រកាន់ថា មាន -- ចោទប្រកាន់ទៅលើបុគ្គលមួយចំនួននៅក្នុងពាក់កណ្តាលទំព័រនេះដែលនិយាយថា បុគ្គលនេះបានលួចរបស់នេះរបស់នោះ។ ទោះបីជាយើងព្យាយាមកសាងដោយរបៀបណាក៏ដោយ -- ឃ្លានិយាយថា យ៉ាងដូច្នេះ -- បាទ សូមឲ្យលោកចាំចំណុចនេះផង។ ហើយឯកសារមួយទៀត E3/4093, ERN អង់គ្លេស 00831489, ខ្មែរ 00270790, បារាំង 00729676។ នេះក៏របាយការណ៍ដែលរាយការណ៍ថាមាននរណាម្នាក់ប្រព្រឹត្តអ្វីខុស ហើយឯកសារនិយាយថាយ៉ាងដូច្នេះត្រង់កណ្តាលទំព័រ។

[១៥:៣៦:២៣]

"ទោះបីជាយើងអប់រំកសាងយ៉ាងណាក៏ដោយ ក៏បុគ្គលរូបនេះមិនកសាងខ្លួនដែរ"។ ហើយឯកសារទី៤ គឺឯកសារ E3/2453, ERN គឺ 00388573, ខ្មែរ 00270775 ហើយខ្មែរ 00616770។ គឺជារបាយការណ៍ដែលរាយការណ៍នៅត្រង់កណ្តាលទំព័រថា "លើសពីនេះទៅទៀតបុគ្គលនេះបានធ្វើការបំផ្លិចបំផ្លាញសហករណ៍ បានលួចដំឡូង បានបោះចានចោល។ ទោះបីជាយើងអប់រំយ៉ាងណាក៏ដោយក៏បុគ្គលនេះមិនកែប្រែ"។ នេះនៅត្រង់ពាក់កណ្តាល។ "ទោះបីជាយើងកសាងបុគ្គលនេះប៉ុន្មានដងក្តី"។ ហើយចុងបញ្ចប់គឺឯកសារ E3/2048, ERN អង់គ្លេស 00276566, ខ្មែរ 00079094 ដល់ 95

បារាំង 00611663។ នេះក៏ជារបាយការណ៍មកពី -- ជូនមន្ទីរអប់រំនៅអង្គតាសោម គឺពាក់ព័ន្ធទៅនឹងបុគ្គលពីរនាក់គឺត្រូវបានអប់រំ ត្រូវបានកសាងច្រើនដងបំផុត។ នេះគឺជាសំណួរវែងណាស់លោកសាក្សី ខ្ញុំសួរដល់ទៅប្រាំសំណួរឯណោះ។ គឺខ្ញុំសួរសំណួរទាំងប្រាំទំព័រនេះ គឺសួរថាមុនពេលអ្នកណាម្នាក់ត្រូវបញ្ជូនទៅក្រាំងតាចាន់ គឺតើៗដោយសារថាអ្នកកម្មាភិបាលមូលដ្ឋានថ្នាក់ឃុំ ថ្នាក់ស្រុកនោះបានប្រាប់តាអាន់ ថាបានអប់រំកែប្រែច្រើនដងមកហើយ។ តើលោកដឹងពីបញ្ហានេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:៣៨:៥២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំ គឺគាត់ថាឯកសារទាំងអស់នេះគឺឯកសារមកពីក្រាំងតាចាន់។ គឺជារបាយការណ៍មកពីថ្នាក់ឃុំ ថ្នាក់មូលដ្ឋាន។ គឺខ្ញុំសូមស្នើថាគាត់សួរសាក្សីនេះសូមឲ្យផ្តល់នូវការស្មានៗ។ ថាតើថ្នាក់ឃុំគេបញ្ជូនមនុស្សមកក្រាំងតាចាន់ដោយរបៀបណា? នេះគឺថាវាស្ថិតនៅក្រៅសមត្ថកិច្ចរបស់គាត់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំប្រើពាក្យពេចន៍ទូទៅមកពីគុកក្រាំងតាចាន់ ឬក៏ស្រុកត្រាំកក់។ ខ្ញុំគិត -- ខ្ញុំមិនមែនសួរតែឯកសារពីពន្ធនាគារសុទ្ធនោះទេ គឺខ្ញុំសួរសំណួរទូទៅថា តើសាក្សីធ្លាប់ -- ដោយសារគាត់ជាអ្នកធ្លាប់វាយអង្គុលីលេខ។ តើធ្លាប់ដឹងទេ? តើប្រជាជនដែលគេបញ្ជូនទៅក្រាំងតាចាន់នេះត្រូវបានអប់រំ ត្រូវបានកសាង ឬក៏មានបំណងកសាងពីរបីប្អូនដងហើយ ប៉ុន្តែនៅតែមិនកែ អ៊ីចឹងក៏ត្រូវបញ្ជូនទៅក្រាំងតាចាន់។ ខ្ញុំយល់ស្របទាំងស្រុង ការគាត់មិនបានឃើញឯកសារនេះដោយខ្លួនឯងទេ ខ្ញុំយល់។ ហើយចំណុចនេះក៏វាមិនបានបញ្ឈប់ឯកសារ បញ្ឈប់សហព្រះរាជអាជ្ញាក្នុងការបង្ហាញឯកសារបែបនេះនោះដែរ។ សំណួររបស់ខ្ញុំគឺ តើ -- ដោយសារគាត់ធ្លាប់មានបទពិសោធន៍ ថាតើបានដឹង ឬក៏ធ្លាប់មានប្រជុំជាមួយ តាអាន់យ៉ាងដូចជាដើម តើអ្នកដែលគេបញ្ជូនទៅក្រាំងតាចាន់នោះ តើវាៗស្ថិតនៅក្នុងក្រសែភ្នែករបស់កម្មាភិបាលនោះដែរឬក៏អត់? ពីព្រោះអ្នកទាំងនេះត្រូវបានអប់រំជាច្រើនលើកច្រើនសា។

**ប្រធានអង្គជំនុំ៖**

បាទ ហើយសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹង គឺមិនត្រឹមត្រូវទេ គឺអង្គជំនុំ

ជម្រះត្រូវការស្តាប់សក្ខីកម្មសាក្សីរូបនេះឆ្លើយតបនឹងសំណួរនេះ ពីព្រោះសាក្សីអាចឆ្លើយនូវសំណួរណាដែលសាក្សីអាចសង្កេតមើល និងអាចសង្កេតបានដឹងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

សាក្សីឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តីអម្បាញ់មិញនេះ ប្រសិនបើសាក្សីនៅចងចាំនូវសំណួរដែលគាត់សួរ។

**លោក ស្រី ថន៖**

**ឆ៖** បាទសំណួរដែលសួរអម្បាញ់មិញគឺ ខ្ញុំមិនបានដឹងទេ ហើយអត់ដែលឮទៀត អត់បានដឹង។ ហើយចំពោះសំណួរមួយទៀតដែលសួរថា ខ្ញុំបានប្រជុំជាមួយតាអាន់ គឺអត់ទេ។ បាទ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានវាយអង្គុលីលេខឯកសារសារភាព តើលោកអាចនិយាយជាលក្ខណៈទូទៅអំពីមូលហេតុនៃការចាប់ខ្លួន ហើយនិងការបញ្ជូនមនុស្សទៅក្រាំងតាចាន់ដែរឬទេ? តើដោយសារតែពួកគេទាំងអស់នោះកែលែងឡើង ឬក៏លោកមិនដឹងតែប៉ុណ្ណឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ រឿងនេះ។ ខ្ញុំអត់ដែលបានដឹង។

**ស៖** លោកបាននិយាយថានៅក្នុងចម្លើយរបស់លោកនោះថា ៩០ភាគរយនៃមនុស្សបញ្ចូលមកមន្ទីរក្រាំងតាចាន់ហ្នឹង ក្រាំងតាចាន់ត្រូវបានគេសម្លាប់ កម្ទេច។ បើសិនជាពិតមែន តើហេតុអ្វីបានជាបុគ្គលទាំងអស់នោះត្រូវបានគេសួរចម្លើយ?

**ឆ៖** បាទពេលដែលសួរចម្លើយគឺធ្វើទារុណកម្ម ខ្ញុំក៏មិនបានដឹងថាគេសួរពីរឿងអ្វីដែរ ខ្ញុំអត់ដឹងទេ បាទ។

[១៥:៤៣:២៩]

**ស៖** លោកជាអ្នកវាយអង្គុលីលេខ។ អ៊ីចឹងលោកគួរតែដឹងអំពីអ្វីដែលកើតឡើងនោះ។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ បើសិនជាពួកគេទាំងអស់នោះគង់តែត្រូវបានកម្ទេចដដែលនោះ តើធ្វើទារុណកម្មពួកគេធ្វើអ្វី? ខ្ញុំអត់យល់។

**ឆ៖** បាទសំណួរនេះក៏ខ្ញុំមិនអាចឆ្លើយបានដែរ ព្រោះខ្ញុំអត់យល់ ត្រង់ថាគេធ្វើយ៉ាងម៉េចនោះខ្ញុំអត់ដឹងពីផែនការនិងនយោបាយរបស់គេទេ បាទ។ អត់យល់គេដែរ។

**ស៖** ខ្ញុំមានសំណួរមួយទៀតដើម្បីត្រឡប់ -- បន្តពីសំណួរនេះ លោកនិយាយថា ចុងឆ្នាំ១៩៧៨ អ្នកទោសត្រូវបានបញ្ជូនចេញពីមន្ទីរក្រាំងតាចាន់ ប៉ុន្តែមុនហ្នឹងលោកនិយាយថា ៩៩ភាគរយនោះ ត្រូវ

បានកម្ទេចអស់ទៅហើយ។ អ៊ីចឹងតើលោកអាចពន្យល់ភាពផ្ទុយគ្នានេះបានទេ បើសម្លាប់ដល់ ៩៩ ភាគរយហើយ ហើយមានមនុស្សដែលបញ្ជូនចេញទៅនេះ? លោកពន្យល់បានទេ?

**ឆ៖** បាទ អ្នកបញ្ជូនចេញទៅនេះគឺអ្នកថ្មីទេ អ្នកចាស់នោះគ្មាននៅទេ គេកម្ទេចទាំងអស់ហ្នឹង។ អ្នកដែលថ្មីមកពេលមុនឆ្នាំ៧៨ហ្នឹង គឺខ្ញុំចេញបាត់ទៅហើយ គេបញ្ជូនចេញគឺវា១កើតចលាចលហើយបានវាបញ្ជូនចេញបាទ។

**ស៖** ខ្ញុំនៅតែមិនទាន់យល់ច្បាស់ដដែល ក៏ប៉ុន្តែមិន១ថ្វីទេ។ ខ្ញុំមានសំណួរពាក់ព័ន្ធនឹងប្រធានបទមួយទៀត គឺទាក់ទងនឹងចម្លើយរបស់លោក សយ សែន។ ព្រះរាជអាជ្ញាបានបង្ហាញលោកនូវផ្នែកមួយចំនួននៃចម្លើយរបស់លោក សយ សែន។ ដូច្នេះ ខ្ញុំក៏ចង់បង្ហាញចម្លើយ -- ផ្នែកមួយចំនួននៃចម្លើយរបស់លោក សយ សែន នេះជូនទៅលោកផងដែរ។

[១៥:៤៥:៥០]

លោកប្រធាន ខ្ញុំនិយាយអំពីប្រតិចារឹកឯកសារ E1/257.1 ប្រហែលជាម៉ោងដប់សែសិបនាទី។ ERN ជាភាសាអង់គ្លេស 00164599 ហើយនៅកន្លែងនេះ លោក សយ សែន គាត់និយាយអំពីលោក។ បាទ សំណួរនេះសួរដូចតទៅនេះ "បាទ ខ្ញុំចង់ដឹងលើសពីហ្នឹងអំពីលោក។ ម្សិលមិញលោកបាននិយាយថាទាហាន ហើយនិងអ្នកយាមបានរំលោភស្ត្រីពីរនាក់នៅកងចល័ត ហើយបាន១ញាត់កាំភ្លើងចូលទៅ១ក្នុងប្រដាប់ភេទផង។ អ៊ីចឹងតើលោកអាចនិយាយថា ឈ្មោះយោធាហ្នឹងអ្នក១ណាដែរឬទេ?" សយ សែន ឆ្លើយ៖ "គាត់ថាអ្នកហ្នឹងឈ្មោះគឺ ឌុច១តូច ហើយនិង សាំង។ មានពីរនាក់ អ្នកដែលធ្វើហ្នឹង"។ សំណួរបន្ត៖ "តើពួកអ្នកទាំងពីរនាក់ហ្នឹង តាអាន់ គាត់មានដាក់ទណ្ឌកម្ម ឬក៏គណៈកម្មការអីទេ?" "ចម្លើយ៖ ថាអត់មានអ្នកដាក់ទណ្ឌកម្មអីទេ"។ សំណួរបន្តទៀត៖ "ម្សិលមិញ លោកបាននិយាយអំពីការសម្លាប់ស្ត្រីពីរនាក់ លោកបាននិយាយថា អ្នកដែលស្ត្រីចាស់ជាងគេនោះ គេបោកក្បាលទៅនឹងគល់ឈើ។ ហើយម្នាក់ទៀតនោះវាយបាក់កញ្ចឹងក។ តើលោកអាចប្រាប់ឈ្មោះអ្នកយាមដែលនិយាយអ៊ីចឹងទេ?" សយ សែន និយាយគាត់ថា "បាទ គឺ ស៊ីម មុន ហើយនិង ឌុចតូច"។ បាទ លោកសាក្សីតាមពិតទៅ សយ សែន គាត់ចោទថាលោកបានចូលរួម ចំណែកក្នុងការធ្វើ -- ប្រព្រឹត្តអំពើឃោរឃៅនៅមន្ទីរក្រាំងតាចាន់។ តើលោកអាចមានពាក្យសម្តីអីឆ្លើយប្រាប់តុលាការទេ?

**ឆ៖** បាទ សំណួរនេះគឺខ្ញុំមិនអាចឆ្លើយបានទេ។

**ស៖** ចុះហេតុអីក៏លោកមិនអាចឆ្លើយនឹងសំណួរនេះបាន?

**ឆ៖** បាទ ព្រោះខ្ញុំមិនបានធ្វើ ហើយខ្ញុំអត់ដឹង មិនដឹងជាឆ្លើយថាយ៉ាងម៉េចហ្នឹងក៏ថាបាន។

**ស៖** តើ សយ សែន ហ្នឹងគាត់ប្រឌិតរឿងហ្នឹងឡើង ឬក៏យ៉ាងម៉េចចំពោះការយល់ដឹងរបស់លោក? គាត់ប្រឌិតរឿងឬក៏ម៉េច?

**ឆ៖** ខ្ញុំមិនដឹង។

[១៥:៤៨:៥៧]

**ស៖** លោកសាក្សី សយ សែន ក៏បាននិយាយរឿងផ្សេងទៀតដែរ។ គឺឯកសារ E1/257.1 ថ្ងៃ -- នៅទំព័រទី៤៣ ឯកសារERN00 -- បាទ សយ សែន និយាយដូចតទៅនេះពាក់ព័ន្ធនឹងលោក៖ "សំណួរ៖ បាទ ឥឡូវយើងចូលនិយាយអំពី សយ សែន ជាអ្នកដែលលោកនិយាយថានៅរស់នៅ ក៏ប៉ុន្តែប្រហែលជាលោកបាននិយាយអំពីគាត់ជាច្រើនដងហើយ បើសិនជាខ្ញុំយល់មិនច្បាស់ទេអំពីអ្វីដែលលោកបាននិយាយហ្នឹង លោកបាននិយាយថា ឌុចតូចនោះជាអ្នកឃោរឃៅជាងគេ។ តើលោកនិយាយអំពីឌុច ហ្នឹងមែន -- ឌុចតូចហ្នឹងមែនទេ?" សយ សែន ឆ្លើយថា៖ "ហ្នឹងហើយ ឌុចតូចហ្នឹង ហើយនិងម្នាក់ទៀតហ្នឹងឃោរឃៅជាងគេ។ ហើយ ស៊ីម ហ្នឹងមិនឃោរឃៅដល់ ឌុច ទេ"។ អ៊ីចឹង លោកសាក្សី សយ សែន ហ្នឹងទំនងជាចង់និយាយថាលោកហ្នឹង កាលនៅនោះឃោរឃៅ ហើយតូងតាង ហើយតើការដែលគាត់និយាយយ៉ាងដូច្នេះនេះ ត្រឹមត្រូវដែរឬទេ? កាលដែលគាត់មកផ្តល់សក្ខីកម្មនៅទីនេះ គាត់និយាយថាលោកហ្នឹងឃោរឃៅខ្លាំងណាស់។

**ឆ៖** បាទ មិនត្រឹមត្រូវទេ។

**ស៖** អ៊ីចឹងលោកកំពុងតែនិយាយថាលោកមិនឃោរឃៅ ហើយមិនក្រញេងក្រញាងទេ។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** លោកសាក្សី សយ សែន ក៏បាននិយាយផងដែរថា ទៅកាន់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ខ្ញុំនិយាយពីឯកសារ E319.1.24 គឺឯកសារ E319.1.24 សំណួរ ១០៧, ERN 0096632។ សំណួរ៖ "តើលោកមានបានឃើញ ឌុច ហ្នឹងរំលោភស្ត្រីអ្នកទោសដែរឬទេ?" សយ សែន ឆ្លើយ៖ "បាទ ខ្ញុំឃើញគាត់រំលោភអ្នកទោសម្នាក់ដែលជាចុងភៅ ហើយ ឌុច មិនបានសម្លាប់គាត់ទេ ក៏ប៉ុន្តែគាត់នោះត្រូវបានសម្លាប់នៅឆ្នាំ១៩៧៩ ហើយប្តីគាត់ស្លាប់នៅក្រាំងតាចាន់"។ លោកសាក្សី អ៊ីចឹង សយ សែន បាននិយាយថា លោកហ្នឹងបានរំលោភអ្នកទោសស្ត្រីម្នាក់នៅក្រាំងតាចាន់

នោះ។ តើលោកមានប្រតិកម្មអីឆ្លើយតបទេ?

**ឆ៖** បាទចម្លើយនេះគឺចម្លើយមិនពិតប្រាកដទេ គឺចម្លើយបំភាន់និងបំភ្លៃការពិតទាំងឡាយបាទ។

**ស៖** តើលោកអាចពន្យល់បានទេថា ហេតុអីក៏ សយ សែន ហ្នឹងគាត់ប្រឌិតរឿងហ្នឹងទាំងអស់ហ្នឹងពាក់ព័ន្ធនឹងលោក?

[១៥:៥២:៣៧]

**ឆ៖** បាទ ដូចលោកជ្រាបហើយថា សម័យខ្មែរក្រហម បើយើងគិតទៅរឿងការរំលោភសេពសន្ថវៈនៅកន្លែងណាក៏មិនដែលរួចខ្លួនដែរ។ បើមានការរំលោភគឺត្រូវតែដើរស្រែកអាក្រោសពេញភូមិហើយ។ អ៊ីចឹងគេមិនអនុញ្ញាតឲ្យទេ។ អ៊ីចឹងសំណួរនេះ មានតែសំណួរប្រឌិតឡើងដើម្បីសួរទេ បាទ។

**ស៖** បានលោកនិយាយថាចម្លើយរបស់គាត់ហ្នឹងគឺជាចម្លើយប្រឌិតទាំងស្រុងតែម្តង។ តើលោកអាចពន្យល់បានដែរឬទេថា ហេតុអ្វីបានជាគាត់ប្រឌិតរឿងឡើង ប្រឌិតរឿងហ្នឹងទាំងអស់ពាក់ព័ន្ធនឹងលោកនោះ? អាចពន្យល់បានទេ?

**ឆ៖** បាទ ខ្ញុំមិនអាចពន្យល់បានទេ ព្រោះខ្ញុំមិនដឹងពីចិត្តនិងគំនិតរបស់គេ មិនដឹងគេចង់និយាយហ្នឹង ចង់និយាយសំដៅទៅលើអ្វី។ អត់យល់។

**ស៖** បាទ ផ្នែកចុងក្រោយនៃចម្លើយរបស់លោក សយ សែន ហ្នឹង គឺមិនមែនជាចម្លើយនៅមុខតុលាការនេះទេ គឺជាការអះអាងរបស់គាត់មួយនៅជូនចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/4648, 050527774, ជាភាសាខ្មែរ 00527724, ជាភាសាបារាំង 00943272។ សំណួរៗដែលគេសួរទៅលោក សយ សែន៖ “តើគាត់រំលោភអ្នកទោសស្រីហ្នឹងមុននឹងសម្លាប់គាត់ដែរឬទេ?” សយ សែនឆ្លើយថា៖ “ខ្ញុំបានឃើញតែម្តងទេ តែអ្នកផ្សេងអ្នកធ្វើទេ ប៉ុន្តែ ឌុច នោះ ខ្ញុំមិនឃើញគាត់អ្នករំលោភគេទេ។ ឌុច សម្លាប់ក្មេងៗស្រីៗនៅក្នុងគុកហ្នឹង ហើយយកគ្រាប់កាំភ្លើងញាត់ កាំភ្លើងសេវេនធីណៃញាត់ចូលប្រដាប់ភេទ។ ខ្ញុំប្រាប់ថា ឃើញ -- ខ្ញុំសួរគាត់ទៅ ថាម៉េចក៏ធ្វើអ៊ីចឹង? បន្ទាប់ពីបានកប់ខ្មោចនោះ ហើយ ឌុច ហើយនិងមិត្តភក្តិរបស់គេបាននិយាយរឿងហ្នឹង”។ គេសួរទៅ សយ សែន “ថាតើឌុច ហ្នឹងនៅរស់នៅឡើយទេ? ឆ្លើយថា៖ បាទ រស់នៅ នៅឡើយទេ រស់នៅឃុំឧត្តមសូរិយា។ ចម្លើយ៖ សួរថាដឹងថារស់នៅឯណាទេ? ខ្ញុំដឹងតែឈ្មោះឃុំទេ ប៉ុន្តែមិនស្គាល់ឈ្មោះភូមិទេ។ គាត់បានរំលោភស្ត្រីម្នាក់ដែលរស់នៅក្នុងភូមិហ្នឹងដដែល ហើយ--

[១៥:៥៥:៤៧]

E1/267.1

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៦:០០]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ លោកមកបង្កើតអង្គហេតុ ឬក៏លោកមកតាំងសំណួរសាក្សី។ យើងដូចជាផ្ដល់ជា ផ្ដល់វេទិកាទៅលោកមានឱកាសតាំងសំណួរសាក្សីទេ មិនបានផ្ដល់ឱកាសឲ្យលោកបង្ហាញ អំពីអង្គហេតុ រៀបរាប់អង្គហេតុមកជូនអង្គជំនុំជម្រះទេ។ លោកកែសម្រួលឡើងវិញលើនីតិវិធីដែល លោកធ្វើនេះ។ សូមបង្ហាញឲ្យត្រូវទៅនឹងនីតិវិធីដែលយើងចង់បាន។

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

វិធានការការពារសាក្សី យើងបានចាត់ហើយ អ៊ីចឹងយើងមិនអាចចោទសំណួរទាក់ទងទៅនឹងអាសយដ្ឋានសាក្សីនេះទេ។ ខ្ញុំសូមរំឭកប៉ុណ្ណឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ**

**ស៖** លោកសាក្សី ខ្ញុំអានផ្នែកមួយនៃចម្លើយរបស់ សយ សែន ដែលគាត់ឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលគាត់និយាយអំពីការរំលោភពីរដង។ ហើយថា នៅក្នុងការរំលោភទាំងពីរដងនេះលោកពាក់ព័ន្ធដែរ។ អ៊ីចឹងខ្ញុំសួរលោកថាតើ លោកមានការឆ្លើយតបទៅនឹងការចោទប្រកាន់នេះយ៉ាងម៉េចដែរ?

**ឆ៖** បាទ ដូចជាខ្ញុំនិយាយដដែលអ៊ីចឹង។ ពាក្យចោទប្រកាន់នេះ គឺពាក្យមិនពិតទាំងអស់ ពាក្យបំភ្លៃការពិត។

[១៥:៥៧:៤០]

**ស៖** អ៊ីចឹងខ្ញុំសូមសង្ខេបនោះ តើ សយ សែន និយាយហ្នឹងគឺចង់និយាយថាលោកបានចូលរួមការកាប់សម្លាប់ រំលោភ។ អ៊ីចឹងបូកសរុបមកវិញ បើតាមលោកចង់និយាយគឺថា ការនិយាយទាំងអស់ហ្នឹងគឺជាការប្រឌិតទាំងស្រុងតែម្ដង អ៊ីចឹងមែនទេ ខ្ញុំយល់អ៊ីចឹងត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវមែនហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ឥឡូវខ្ញុំសូមផ្ដល់វេទិកាទៅសហភាតាជាតិរបស់ខ្ញុំលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[១៥:៥៨:៣១]

**សួរដោយលោក សួន វិសាល**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំបាទ មានសំណួរពីរបីសំណួរតែប៉ុណ្ណោះ។

**ស៖** លោកសាក្សី ជាដំបូងនេះ ខ្ញុំចង់សួរលោកថាទៅនៅពេលដែលឆ្នាំ១៩៧៦ នៅពេលដែលលោកត្រូវបានតែងតាំងមកយាមនៅមន្ទីរឃុំខ្លួនក្រាំងតាចាន់នោះ តើមេរបស់លោកមានណែនាំលោកយ៉ាងម៉េចខ្លះដែរ?

**ឆ៖** បាទ ពេលដែលគេឲ្យពួកក្រុមខ្ញុំទៅយាមនោះ គឺគេឲ្យទៅយាមជួយការពារមន្ទីរអប់រំស្រុក១០៥។ គេមានបទបញ្ជាតែប៉ុណ្ណឹងទេ។

**ស៖** តើគេមានកំណត់គោលនយោបាយអីត្រូវកម្ទេចខ្មាំង ឬក៏ទៅធ្វើវិធានការអីចាំបាច់សម្រាប់បង្ក្រាបអ្នកទោស ទាំងនោះទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** សូមអរគុណ ចូលសំណួរបន្ទាប់។ ចំណុចមួយទៀតដែលខ្ញុំមិនទាន់ច្បាស់លាស់ ថានៅពេលដែលលោកទៅយាមនៅទីនោះ គឺយាមមានពីរដំណាក់កាល។ ទី១ នៅខាងក្រៅ, ទី២ នៅខាងក្នុង។ តើនៅខាងក្រៅ ហើយនិងខាងក្នុងធ្វើកិច្ចការខុសគ្នារបៀបណាដែរ?

**ឆ៖** បាទ ពីរដំណាក់កាលនេះ ការងារមិនខុសគ្នាទេ។ គ្រាន់តែមុនដំបូង នៅឆ្ងាយ គេគ្រាន់តែឲ្យនាំអ្នកទោសដូចតែគ្នាអ៊ីចឹង។ ប៉ុន្តែមួយឆ្ងាយ មួយយកទៅដាក់ជិត ដើម្បីការពារនៅជុំវិញរបង។ បាទ មានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ សំណួរមួយទៀតទាក់ទងទៅនឹង លោកបាន ចម្លើយរបស់លោកបានបញ្ជាក់ចំពោះមុខសវនាការកាលពីព្រឹកមិញ ថាលោក នៅពេលដែលគេសម្លាប់នោះ គឺលោកមានការយាមពិសេស។ តើលោកទៅយាមនៅកន្លែងណាដែលគេជាទីតាំងសម្លាប់មនុស្សនោះ?

**ឆ៖** បាទ ខ្ញុំដូចជាឆ្លើយបញ្ជាក់ច្រើនសាហើយសំណួររឿងសម្រាប់រឿងយាម។ ក្រុមខ្ញុំប្រាំនាក់មានតួនាទីយាមមាត់ទ្វារពីខាងលិចនិងពីខាងកើត។ ប៉ុន្តែពេលដែលគេយកសម្លាប់មនុស្សនោះ គឺគេមិនឲ្យយើងទៅយាមទេ។

[១៦:០១:១២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត នៅក្នុងមន្ទីរ -- នៅក្នុងរយៈពេលដែលលោកនៅធ្វើការជាអ្នកយាមនៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង តើគេមានអនុញ្ញាតឲ្យអ្នកទោសដែលធ្វើការនៅទីនោះ បានន័យថាកែប្រែខ្លួន ហើយគេឲ្យធ្វើការក្នុងពន្ធនាគារហ្នឹងទេ?

**ឆ៖** បាទ មាន។ អ្នកទោសដែលនៅក្នុងនោះ អ្នកខ្លះ គេឲ្យចេញវាល ធ្វើការធម្មតា។

**ស៖** តើអ្នកទាំងអស់នោះធ្វើការអីខ្លះ?

**ឆ៖** បាទ មានរែកដី ដកស្ទូងអី ដល់ខែដកស្ទូង ដកស្ទូង។ តែប៉ុណ្ណឹង។

**ស៖** នៅទីនោះ តើមានគេ មានគោ មានសេះ ឬក៏ក្របីអី ដែលគេត្រូវឃ្វាលទេ?

**ឆ៖** បាទ គោមាន ប៉ុន្តែតែក្រុមគ្នាគេខាងក្នុងទេ គេអ្នកមើល គេអ្នកឃ្វាល គេមិនឲ្យអ្នកទោសឃ្វាលទេ។

**ស៖** លោកចង់បញ្ជាក់ថា អ្នកទោសដែលគេអនុញ្ញាតឲ្យធ្វើការស្រាលៗ គឺមិនអនុញ្ញាតឲ្យឃ្វាលគោទេ ឃ្វាលក្របីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

[១៦:០៣:០០]

**លោក សួន វិសាល៖**

ខ្ញុំសួរសំណួរមួយទៀត។ នៅពេល -- ព្រោះពេលវេលារាងខ្លីបន្តិច។ ខ្ញុំមានសំណួរដូចថាដល់ម៉ោង ប៉ុន្តែខ្ញុំមានសំណួរបីសំណួរទៀត។ លោកចៅក្រមអនុញ្ញាតដែរទេបាទ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**សួរដោយលោក សួន វិសាល៖**

**ស៖** ខ្ញុំចង់សួរលោកទាក់ទងទៅនឹងការសួរចម្លើយ។ តើនៅពេលសួរចម្លើយ តើលោកមានបានដឹងថាតើគេអនុញ្ញាតឲ្យអ្នកទោសស្រាលហ្នឹងទៅជិតកន្លែងគេសួរចម្លើយទេ?

**លោក ស្រី ថន៖**

**ឆ៖** បាទ ពេលគេសួរចម្លើយ គ្មានមនុស្សដើរជិត ឬអ្នកទោសស្រាលណាដែលចេញធ្វើការទេ អត់ទេ គឺនៅជាប់ទាំងអស់។

**ស៖** សូមអរគុណ។ ចំពោះអ្នកទោសដែលទៅធ្វើការខាងក្រៅ តើមានដែលគេ មានដែលរត់រួចឬទេ?

**ឆ៖** តាំងពីខ្ញុំចូលទៅនៅកន្លែងហ្នឹងទៅ គឺមិនដែលឃើញមានអ្នកទោសណារត់រួចម្នាក់ទេ មិនដែលរត់ អ្នកទោសមិនដែលរត់។

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំមានសំណើមួយខ្លីទេទាក់ទងទៅនឹងក្រុមឯកសាររបស់ក្រុម នួន ជា សួរសាក្សីបន្ទាប់។ គឺថាមានឯកសារ៧៥២ ហើយថ្ងៃនេះគឺថាមានជាង៤០០ ជម្រាបថាមាន -- សួរទើបតែ ប្រើប្រាស់តែ១៥។ ដូច្នេះយើងខ្ញុំស្នើសុំឱ្យក្រុមមេធាវី នួន ជា ផ្ញើអ៊ីម៉ែលបញ្ជាក់មកគ្រប់ភាគីទាំងអស់អំពីចំនួនឯកសារ។ ដោយសារតែឯកសារមួយចំនួននោះ គឺថាមិនមាននៅលើអ៊ីនធីហ្វេស ពិបាករក។ ដូច្នេះសូមឱ្យបញ្ជាក់អំពីចំនួនឯកសារនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់ដ៏ល្អរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយសូមភាគីមេធាវីការពារក្ដីជាពិសេសមេធាវី នួន ជា សូមផ្ដល់នូវបញ្ជីឯកសារដែលក្រុមមេធាវីទំនងជាប្រើប្រាស់ក្នុងការសួរតាំងសួរដេញដោលសាក្សីបន្ទាប់នៅដែលនឹងធ្វើចាប់ផ្ដើមថ្ងៃស្អែកទៅ។

បាទ ឥឡូវនេះ អង្គសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយៗអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ស្រី ថន ហើយនិងអាចបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-552។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។ ហើយ

អង្គជំនុំជម្រះសូមអរគុណចំពោះសាក្សី។ ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅពេលនេះមិនទាន់ចប់នៅឡើយទេ ហើយអង្គជំនុំជម្រះនឹងកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ នាពេលនេះលោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្នាក់នៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ រួមទាំងសាក្សីបម្រុងត្រឡប់ទៅកាន់កន្លែងស្នាក់នៅវិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ រួមទាំងសាក្សីបម្រុងសម្រាប់ថ្ងៃស្អែកមកកាន់ អ.វ.ត.ក នេះដើម្បីសាក្សីទី១ គឺចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ហើយនិងសាក្សីបម្រុងគឺទុករង់ចាំ នៅកន្លែងរង់ចាំសម្រាប់សាក្សីដើម្បីត្រៀមបន្តកិច្ចដំណើរការនីតិវិធីនៅពេល នៅថ្ងៃស្អែកទៀត។ ហើយសូមអញ្ជើញមេធាវីប្រឹក្សាសាក្សីមកចូលរួមផង។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ទៅត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ នួន ជា និង ខៀវ សំផន ត្រឡប់មកចូលរួមសវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*